ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education


# និក្ខេបបទ

## ទស្សនៈរបស់មាតាបិតាសិស្ស ចំពោះតួនាទីរបស់ខ្លួន ក្នុងការចូលរួមចំណែកជួយការអប់រំ និងការសិក្សារបស់កូនៗ នៅមធ្យមសិក្សាទុតិយភូមិ

## ( ករណីសិក្សា នៅរាជធានីភ្នំពេញ )

PERSPECTIVES OF PARENTS ON THEIR ROLE IN CONTRIBUTING TO THE EDUCATION AND THE EDUCATION OF THEIR CHILDREND IN HIGH SCHOOL

( CASE STUDY IN PHNOM PENH )


**និស្សិតឈ្មោះ  អ៊ឹម សៀន** IM SEAN


**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល**

**ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩**

**ឯកទេសៈ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០២០-២០២២**

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

## ទស្សនៈរបស់មាតាបិតាសិស្ស ចំពោះតួនាទីរបស់ខ្លួន ក្នុងការចូលរួម ចំណែកជួយការអប់រំ និងការសិក្សារបស់កូនៗ នៅមធ្យមសិក្សាទុតិយភូមិ (ករណីសិក្សា នៅរាជធានីភ្នំពេញ)។

PERSPECTIVES OF PARENTS ON THEIR ROLE IN CONTRIBUTING TO THE EDUCATION AND THE EDUCATION OF THEIR CHILDREND IN HIGH SCHOOL ( CASE STUDY IN PHNOM PENH )

និស្សិតឈ្មោះ  អ៊ឹម សៀន/ IM SEAN

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល

ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩

ឯកទេសៈ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០២០-២០២២

គ្រូណែនាំគោលៈ   បណ្ឌិត  នី រដ្ឋា
គ្រូណែនាំរងៈ      បណ្ឌិត  ឈិញ ស៊ីថា

# សេចក្តីអះអាងរបស់បេក្ខជន

ខ្ញុំបាទ សូមបញ្ជាក់អះអាងថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា **«ទស្សនៈរបស់មាតាបិតាសិស្ស ចំពោះតួនាទីរបស់ខ្លួន ក្នុងការចូលរួមចំណែកជួយការអប់រំ និងការសិក្សារបស់កូនៗ នៅមធ្យមសិក្សាទុតិយភូមិ» (ករណីសិក្សា នៅរាជធានីភ្នំពេញ)**។

ដើម្បីបំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ គឺពិតជាបានមកពីការសិក្សាស្រាវជ្រាវ ដោយរូបខ្ញុំបាទផ្ទាល់ ដែលមានឯកសារជំនួយពី ក្រសួងអប់រំ យុវជននិងកីឡា និងមានឯកសារពាក់ព័ន្ធនានាជាច្រើនទៀត។ ខ្ញុំបាទ សូមអះអាងថារាល់សេចក្តីដកស្រង់ ឬការបញ្ចូលខ្លឹមសារទាំងឡាយដែលត្រូវបានយកមកប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ពិតជាមានសុំការអនុញ្ញាតពីអ្នកនិពន្ធឬមានចុះក្នុងបញ្ជីឯកសារយោងយ៉ាងច្បាស់លាស់។ ការស្រាវជ្រាវនេះគឺពិតជាបានចងក្រងនៅក្នុងការសរសេរនិក្ខេបបទ ដោយរូបខ្ញុំផ្ទាល់ពិតប្រាកដមែន។

ថ្ងៃអាទិត្យ ១៣កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២២

**ហត្ថលេខា**



**អ៊ឹម សៀន**

# លិខិតបញ្ជាក់ពីគ្រូណែនាំ

**បណ្ឌិត នី រដ្ឋា** ជាគ្រូណែនាំគោល

**បណ្ឌិត ឈិញ ស៊ីថា** ជាគ្រូណែនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក **អ៊ឹម សៀន** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ ពិតជាបាន សរសេរនិក្ខេបបទស្រាវជ្រាវស្តីពី «**ទស្សនៈរបស់មាតាបិតាសិស្ស ចំពោះតួនាទីរបស់ខ្លួន ក្នុងការចូលរួមចំណែកជួយការអប់រំ និងការសិក្សារបស់កូនៗ នៅមធ្យមសិក្សាទុតិយភូមិ**» **(ករណីសិក្សា នៅរាជធានីភ្នំពេញ)** ពិតប្រាកដមែន។

ថ្ងៃអាទិត្យ ១៣កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២២

**គ្រូណែនាំគោល**

**បណ្ឌិត នី រដ្ឋា**

ប្រធានការិយាល័យសិក្សា នៃវិទ្យាស្ថានជាតិអប់រំ

**គ្រូណែនាំរង**

**បណ្ឌិត ឈិញ ស៊ីថា**

អ្នកស្រាវជ្រាវ

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ [illegible]

(ការងារសម្ងាត់)

**លិខិតឧទ្ទេសនាម**

យោង៖ ផែនការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ និងទី១០ ឆ្នាំសិក្សា២០២១-២០២២ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមាននាមខាងក្រោម ត្រូវបានចាត់តាំងជា គណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៩ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២-លោក | ថៃ ហាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៣-លោកបណ្ឌិត | អាន វីប្រាំ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤-លោកបណ្ឌិត | ឡាយ សុវិទ្ធា | នាយកដ្ឋានគោលនយោបាយ | សមាជិក |
| ៥-លោកបណ្ឌិត | សោន ផ្លែះ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-លោកបណ្ឌិត | ឈន ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោកបណ្ឌិត | លី គឹមឡុង | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ៨-លោកបណ្ឌិត | ឈិញ នីដា | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ៩-លោកបណ្ឌិត | អ៊ុំ ចាន់ចំណាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោកបណ្ឌិត | កាង ស៊ុងនាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោក | ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោក | លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោក | ចាន់ រ៉ាដា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោកបណ្ឌិត | មឿន ពិនណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥-លោកបណ្ឌិត | គួយ សុគន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៦-លោកស្រីបណ្ឌិត | ម៉ឺយ សុគា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៧-លោក | ប៉ុ ប៊ុន្នន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៨-លោកស្រី | នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | សៀ សុផា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០.លោក | ចាប់ សន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១.លោក | ម៉ុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២២.លោកស្រី | សេង សុជា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣.លោក | ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤.លោកស្រី | សុខ វណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៥.លោកស្រី | ឯម សុកាលក្សី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

[illegible]
www.moeys.gov.kh

លោក លោកស្រី ដូចមាននាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតពីថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។/.

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០២២
ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

កន្លែងទទួល៖
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាព ពាក់ព័ន្ធក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡាដែលពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ

# លិខិតថ្លែងអំណរគុណ

ការសិក្សាស្រាវជ្រាវមួយនេះ សម្រេចបានដល់គោលដៅប្រកបដោយភាពជោគជ័យ ព្រោះមានការចូលរួមយ៉ាងសកម្មពីគ្រប់មជ្ឈដ្ឋានគ្រប់ភាគីពាក់ព័ន្ធនានា ដែលបានចូលរួមផ្តល់ឱកាសជួយសម្របសម្រួល និងជួយជ្រោមជ្រែងយ៉ាងយកចិត្តទុកដាក់បំផុតតាំងពីពេលចាប់ផ្តើមរហូតដល់ទីបញ្ចប់។

ខ្ញុំបាទ សូមថ្លែងអំណរគុណ និងអរគុណជាអតិបរមាចំពោះឯកឧត្តមបណ្ឌិត នាយកវិទ្យាស្ថានជាតិអប់រំ ដែលបានយកចិត្តទុកដាក់ ដល់រូបខ្ញុំក៏ដូចជានិស្សិតដែលបានទទួលការបណ្តុះបណ្តាល នៃវិទ្យាស្ថានជាតិអប់រំក្នុងរយៈពេល២ឆ្នាំកន្លងទៅ។

ខ្ញុំបាទសូមថ្លែងអំណរគុណ និងដឹងគុណយ៉ាងជ្រាលជ្រៅ ដល់គណៈកម្មការគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ លោកបណ្ឌិតសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ព្រមទាំងបុគ្គលិក នៃវិទ្យាស្ថានជាតិអប់រំ ទាំងអស់ ដែលលោក លោកស្រី បានយកចិត្តទុកដាក់ និងចំណាយពេលវេលាដ៏មមាញឹក ជួយសម្របសម្រួលសម្រាប់ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩នេះ ដោយមិនគិតពីការនឿយហត់ឡើយ។ ជាពិសេសក្នុងការណែនាំគ្រប់បែបយ៉ាង និងផ្តល់នូវចំណេះដឹងថ្មីៗជាច្រើនដល់ រូបខ្ញុំបាទ។

លើសពីនេះជាពិសេស ខ្ញុំបាទសូមគោរពថ្លែងអំណរគុណ និងដឹងគុណយ៉ាងជ្រាលជ្រៅបំផុត ដល់ **លោកបណ្ឌិត នី រដ្ឋា** ជាគ្រូណែនាំគោល និង**លោកបណ្ឌិត ឈិញ ស៊ីថា** ជាគ្រូណែនាំរង ដែលលោកទាំងពីរនាក់បានជួយជ្រោមជ្រែងផ្តល់អនុសាសន៍ណែនាំគំនិតល្អៗ កែលម្អរាល់ចំណុចខ្វះខាតទាំងឡាយ ទាំងពាក្យពេចន៍ ឃ្លាប្រយោគ អក្ខរាវិរុទ្ធ និងផ្តល់កម្លាំងចិត្ត បច្ចេកទេស វិធីសាស្ត្រនានា ក្នុងការរៀបរៀងនិក្ខេបបទនេះ។ លោកបណ្ឌិតទាំងពីរ បានផ្តល់ជាឯកសារដែលទាក់ទងនឹងប្រធានបទ ព្រមទាំងជួយបង្ហាញទិសដៅដល់រូបខ្ញុំបាទ រហូតការសិក្សាស្រាវជ្រាវទទួលបានជោគជ័យជាស្ថាពរ។

សូមថ្លែងអំណរគុណដល់មិត្តភក្តិរួមជំនាន់ទី៩ ទាំងអស់គ្នាដែលតែងតែជួយជាគំនិតល្អៗ បទពិសោធន៍និងចំណេះដឹងលើមុខវិជ្ជានានា ដែលខ្ញុំបាទទទួលបាន ពីការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅវិទ្យាស្ថានជាតិអប់រំ បានផ្តល់នូវចំណេះដឹងដ៏មានតម្លៃ និងមានសារៈសំខាន់ សម្រាប់ខ្លួនខ្ញុំផ្ទាល់ និងជួយជំរុញការងារនៅក្នុងការអភិវឌ្ឍនៅវិទ្យាល័យ ដែលខ្ញុំបាទកំពុងតែបំពេញការងាររាល់ថ្ងៃ ឲ្យកាន់តែប្រសើរឡើងថែមទៀត។

ស្នាដៃនេះផងដែរខ្ញុំបាទ សូមថ្លែងអំណរគុណដល់ ឪពុកម្តាយបង្កើត ឪពុកម្តាយក្មេក ភរិយា និងបងប្អូនប្រុសស្រីទាំងអស់ ដែលបានផ្តល់នូវពេលវេលា ប្រាក់កាស តែងតែជំរុញ និងលើកទឹកចិត្តឲ្យខ្ញុំបានបន្តការសិក្សារហូតបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនេះជាស្ថាពរ។

ជាទីបញ្ចប់ខ្ញុំសូមប្រសិទ្ធពរជ័យ សិរីមង្គលបវរមហាប្រសើរ ជូនចំពោះ ឯកឧត្តម លោក លោកស្រី ដែលជាសាស្ត្រាចារ្យនៅវិទ្យាស្ថានជាតិអប់រំទាំងអស់ មិត្តរួមថ្នាក់ ក្រុមគ្រួសារ ជាពិសេសភរិយា និងកូនប្រុស ស្រី ជាទីស្រឡាញ់ ទាំងពីរនាក់ របស់ខ្ញុំ ជួបតែពុទ្ធពរទាំង៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ**!

# មូលន័យសង្ខេប


ការអប់រំមាននាទីយ៉ាងសំខាន់បំផុតក្នុងការអភិវឌ្ឍធនធានមនុស្ស និងជាឆ្អឹងខ្នងនៃការអភិវឌ្ឍប្រទេសជាតិ ជាពិសេសការអប់រំប្រកបដោយគុណភាព និងមានប្រសិទ្ធភាពខ្ពស់។ ជាមួយគ្នានេះដែរ ក្រសួងអប់រំ យុវជន និងកីឡា បានស្វែងរកយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ តាមរយៈការសហការជាមួយដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធ ជាពិសេសសហការជាមួយនិងមាតាបិតាសិស្ស ដែលជាកម្លាំងចលករុញច្រាន និងជំរុញកូនៗឲ្យទៅសាលារៀនបានរាល់ថ្ងៃ និងបានចប់ចុងចប់ដើមរហូតមានការងារធ្វើសមរម្យ។ ការស្រាវជ្រាវស្ដីពី **«ទស្សនៈរបស់មាតាបិតាសិស្សចំពោះតួនាទីរបស់ខ្លួន ក្នុងការចូលរួមចំណែកជួយការអប់រំ និងការសិក្សារបស់កូនៗ នៅមធ្យមសិក្សាទុតិយភូមិ»** គឺមានគោលបំណងសំខាន់២គឺ៖ (១) ស្វែងយល់ពីទស្សនៈរបស់មាតាបិតាសិស្ស ចំពោះតួនាទីរបស់ខ្លួន ក្នុងការចូលរួមចំណែកជួយការអប់រំ និងការសិក្សារបស់កូនៗ នៅមធ្យមសិក្សាទុតិយភូមិ និង (២) ស្វែងរកពីឧបសគ្គនានារបស់មាតាបិតាសិស្ស ចំពោះតួនាទីរបស់ខ្លួន ក្នុងការរួមចំណែកជួយការអប់រំ និងការសិក្សារបស់កូនៗ នៅមធ្យមសិក្សាទុតិយភូមិ។

អ្នកសិក្សាស្រាវជ្រាវក៏បាន រៀបចំឧបករណ៍ស្រាវជ្រាវតាមបែបបរិមាណវិស័យបែបស្ទាបស្ទង់មតិ និងការយល់ឃើញរបស់អ្នកចូលរួម។ ការចុះប្រមូលទិន្នន័យ គឺធ្វើឡើងចំពោះវិទ្យាល័យគោលដៅចំនួន៥ ក្នុង៥ខណ្ឌ របស់រាជធានីភ្នំពេញ។ ចំនួនអ្នកចូលរួមជាក់ស្ដែងរួមមាន មាតាបិតាសិស្សចំនួន ៦២នាក់ លោកគ្រូ អ្នកគ្រូ ចំនួន៣៧នាក់ និងសិស្សានុសិស្សចំនួន១២៣នាក់ សរុបរួមគឺមានចំនួន២២២នាក់។

- លទ្ធផលស្រាវជ្រាវសម្រាប់សំណួរទី១ ដែលនិយាយអំពីដំណើរការចំពោះតួនាទីក្នុងការចូលរួមចំណែកអប់រំកូនរបស់មាតាបិតាស្ថិតក្នុងកម្រិតល្អ (**M = ៣.៦៦, S.D = 0.៥0**)។
- លទ្ធផលស្រាវជ្រាវសម្រាប់សំណួរទី២ ដែលនិយាយពីឧបសគ្គរាំងនៃការចូលរួម និងបញ្ហាប្រឈមនានាគឺ (**M = ២.៥៦, S.D = 0.៦៨**) ស្ថិតក្នុងកម្រិត ខ្សោយ។

យើងអាចវាយតម្លៃបានថា ការសិក្សាស្រាវជ្រាវនេះ អាចយកទៅប្រើប្រាស់ក្នុងគោលបំណងពង្រឹងចំណេះដឹងដល់សិស្ស និងជាព័ត៌មានសម្រាប់មាតាបិតា ក្នុងការចូលរួមផងដែរ។

**ABSTRACT**

Education plays a very important role in the development of human resources and is the backbone of the development of the nation, especially high quality and effective education. At the same time, the Ministry of Education, Youth and Sports seeks strategies to reform the education sector through cooperation with development partners and stakeholders, especially with parents of students, who are the driving force to push and encourage children to go to school. The day will end until there is a decent job. Research on **"Perspections of Parents on their role in contributing to education and the education of their children in high school "** There are two main purposes: (1) Understand the views of parents on their role in contributing to the education and education of their children in high school; and (2) explore the barriers of parents to their role in contributing to the education and Children's education in high school.

The researchers also developed quantitative research tools, field surveys, and participants' perceptions. The data collection was conducted for 5 target high schools in 5 districts of Phnom Penh. The actual number of participants included 62 parents, 37 teachers and 123 students, a total of 222 people.

- The research results for the first question, which deals with the process for the role of parents in educating their children are at a good level ( **M** = **3.66** , **SD** = **0.50** ).
- The research results for the second question about barriers to participation and challenges were ( **M** = **2.56** , **SD** = **0.68** ). In range Weak.

We can assess that this research can be used to enhance the knowledge of students and information for parents to participate.

# មាតិកា

**ចំណងជើង** **ទំព័រ**


សេចក្ដីអះអាងរបស់បេក្ខជន ........ i

លិខិតបញ្ជាក់ពីគ្រូណែនាំ ........ ii

លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ ........ iii

លិខិតថ្លែងអំណរគុណ ........ iv

មូលន័យសង្ខេប ........ vi

**Abstract** vii

........

ជំពូក១ ៖ សេចក្ដីផ្ដើម ........ 1

១.១ លំនាំបញ្ហានាំនៃការស្រាវជ្រាវ ........ 1

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ 5

១.៣ គោលបំណងនៃការស្រាវជ្រាវ ........ 6

១.៤ សំណួរនៃការស្រាវជ្រាវ ........ 6

១.៥ សារៈសំខាន់នៃការស្រាវជ្រាវ ........ 7

១.៦ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ ........ 7

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ 8

ជំពូក ២ ៖ ការរំលឹកទ្រឹស្ដី ........ 10

២.១ សេចក្ដីផ្ដើម ........ 10

២.២ និយមន័យ និងពាក្យគន្លឹះ........ 10

ក) និយមន័យ «មាតាបិតា» ........ 10

ខ) ការចូលរួមចំណែករបស់មាតាបិតា........ 11

២.៣ ដំណើរការចំពោះតួនាទីក្នុងការចូលរួមចំណែកអប់រំកូនរបស់មាតាបិតា................... 13
២.៣.១ ការតាមដានការសិក្សារៀនសូត្ររបស់កូន............................ 13
២.៣.២ ការរួមចំណែកពីមាតាបិតានៅសាលារៀន............................ 14
២.៣.៣ ការជំរុញ និងការលើកទឹកចិត្ត........................................... 15
២.៣.៤ ភាពជាដៃគូរវាងសាលារៀន និងគ្រួសារ ............................. 16
២.៣.៥ ការចូលរួមរបស់ឪពុកម្តាយចំពោះការអប់រំរបស់កូន.............. 17
២.៤ ឥទ្ធិពលនៃការចូលរួមរបស់មាតាបិតាលើសមិទ្ធផលការសិក្សា............ 18
២.៤.១ ការទំនាក់ទំនងរវាងមាតាបិតា ការចូលរួម និងការលើកទឹកចិត្តសិស្ស................................................................................................ 19
២.៤.២ ការបង្កើតទំនាក់ទំនងជាប់លាប់រវាងមាតាបិតាសិស្ស និងគ្រូបង្រៀន ជាកត្តាល្អជួយកែតម្រូវចំណុចខ្វះខាត និងបណ្តុះគំនិតល្អដល់កូនៗ.... 21
២.៤.៣ កត្តាទំនាក់ទំនងរវាងសាលារៀន និងគ្រួសារ.......................... 22
២.៤.៤ សារៈសំខាន់នៃការចូលរួមរបស់មាតាបិតា............................ 23
២.៥ តួនាទី និងសារៈសំខាន់នៃការអប់រំ.................................................. 24
២.៦ លក្ខណៈទាំង១០ របស់ឪពុកម្តាយ ដែលធ្វើឲ្យកូនទទួលបានជោគជ័យ 25
២.៧ តាមដានការសិក្សារៀនសូត្ររបស់សិស្ស......................................... 28
២.៨ គន្លឹះអប់រំកូនៗរបស់ជនជាតិជប៉ុន ដែលឪពុកម្តាយគ្រប់រូបគួរស្វែងយល់................................................................................................ 29
២.៩ ការស្រាវជ្រាវផ្តោតសំខាន់ទៅលើទស្សនៈរបស់មាតាបិតា និងការសិក្សារបស់កូនៗ.. 30
២.១០ អត្ថប្រយោជន៍នៃការចូលរួមរបស់មាតាបិតា .................................. 31

២.១១ កំហុសឆ្គងទាំង ៦យ៉ាងរបស់ឪពុកម្តាយដែលរារាំងភាពជោគជ័យរបស់កូនៗ. 32
ជំពូក៣ ៖ វិធីសាស្ត្រស្រាវជ្រាវ........................................................................................ 35
៣.១ គម្រោងវិភាគ........................................................................................ 35
៣.២ ការប្រមូលទិន្នន័យ........................................................................................ 35
៣.៣ ឧបករណ៍ស្រាវជ្រាវ........................................................................................ 36
៣.៣.១ កម្រិតចង្អុលបង្ហាញ........................................................................................ 38
៣.៣.២ កម្រងសំណួរ........................................................................................ 39
៣.៤ ការជ្រើសរើសភាគសំណាក........................................................................................ 40
៣.៥ ការវិភាគទិន្នន័យ........................................................................................ 41
ជំពូក ៤៖ លទ្ធផល និងការពិភាក្សា........................................................................................ 42
៤.១ ព័ត៌មានមូលដ្ឋានអ្នកចូលរួម........................................................................................ 43
៤.២ លទ្ធផលស្រាវជ្រាវ........................................................................................ 43
៤.២.១ ទស្សនៈរបស់មាតាបិតាសិស្ស លើតួនាទីរបស់ខ្លួន ក្នុងការចូលរួម និងការសិក្សារបស់កូន........................................................................................ 43
៤.២.២ បញ្ហាប្រឈមក្នុងការចូលរួមរបស់មាតាបិតា........................................................................................ 71
៤.៣ ការពិភាក្សា........................................................................................ 77
៤.៣.១ ការពិភាក្សាទៅលើលទ្ធផលស្រាវជ្រាវ ផ្នែកទី១........................................................................................ 77
៤.៣.២ ការពិភាក្សាទៅលើលទ្ធផលស្រាវជ្រាវ ផ្នែកទី២........................................................................................ 77
ជំពូក ៥ ៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ........................................................................................ 79
៥.១ សង្ខេបលទ្ធផល........................................................................................ 79

៥.២ ការពិភាក្សា.................................................................................... 80

៥.៣. សំណូមពរ ...................................................................................... 81

៥.៤ ការសិក្សាស្រាវជ្រាវបន្ត...................................................................... 83

ឯកសារយោង.......................................................................................... 84

ឧបសម្ព័ន្ធ ក.......................................................................................... 87

ឧបសម្ព័ន្ធ ខ.......................................................................................... 90

ឧបសម្ព័ន្ធ គ.......................................................................................... 106

ឧបសម្ព័ន្ធ ឃ.......................................................................................... 112

ឧបសម្ព័ន្ធ ង.......................................................................................... 116

# ជំពូក ១

# សេចក្តីផ្តើម

# ជំពូក ១

# ១ សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ទស្សនៈរបស់មាតាបិតាសិស្ស ចំពោះតួនាទីរបស់ខ្លួន ក្នុងការចូលរួមចំណែកជួយការអប់រំ និងការសិក្សារបស់កូនៗ និងអ្នកពាក់ព័ន្ធផ្សេងទៀត លើវិស័យអប់រំ គឺជាផ្នែកមួយយ៉ាងសំខាន់ដើម្បីបង្កើនល្បឿនការអប់រំឱ្យឆ្លើយតបទៅនឹងគោលនយោបាយ យុទ្ធសាស្ត្រ ឬបញ្ញត្តិជាសកលដែលប្រទេសភាគច្រើនលើសកលលោក ប្រឹងប្រែងពង្រឹង និងលើកកម្ពស់លើវិស័យនេះ។ ការពង្រឹងទៅលើទំនាក់ទំនងរវាងគ្រួសារ និងសហគមន៍ ជាមួយនឹងប្រព័ន្ធអប់រំ គឺជាកត្តាមួយដែលជំរុញ នឹងជះឥទ្ធិពលទៅដល់លទ្ធផលនៃការអប់រំរបស់សិស្សទៅថ្ងៃអនាគត ក៏ដូចជាគ្រួសារ ឬសហគមន៍ផ្ទាល់ ដែលនេះជាកត្តាសំខាន់មួយ ក្នុងការជួយអភិវឌ្ឍសហគមន៍ផ្ទាល់របស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយទស្សនៈរបស់មាតាបិតាសិស្ស ចំពោះតួនាទីក្នុងការរួមចំណែកជួយការអប់រំ និងការសិក្សារបស់កូនៗ នៅតែជាកង្វល់ដែល បណ្តាអង្គការមិនមែនរដ្ឋាភិបាល និងរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំង ដើម្បីធ្វើយ៉ាងណា ឱ្យអ្នកដែលពាក់ព័ន្ធទាំងឡាយ យល់ពីសារៈសំខាន់នៃការចូលរួមរបស់ពួកគេ (Sovannara, 2011)។

រាជរដ្ឋាភិបាលកម្ពុជា បានចងក្រងច្បាប់ស្តីពីការអប់រំរបស់ប្រទេសកម្ពុជាបានអនុម័តនៅចុងឆ្នាំ ២០០៧ ដែលច្បាប់នេះបានបញ្ជាក់យ៉ាងច្បាស់អំពីសារៈសំខាន់នៃការចូលរួមរបស់មាតាបិតា អ្នកអាណាព្យាបាល សហគមន៍ និងអ្នកដែលពាក់ព័ន្ធទាំងឡាយលើវិស័យអប់រំ ដោយគិតចាប់តាំងពីថ្នាក់ក្រសួងអប់រំ យុវជន និងកីឡា រហូតដល់ថ្នាក់មូលដ្ឋាន (សាលារៀន) ដែលមានតួនាទីក្នុងការសម្របសម្រួលឱ្យពួកគេបានចូលរួមចំណែក និងជួយជំរុញ ធ្វើយ៉ាងណាឱ្យការអប់រំប្រកបដោយគុណភាព ស្លេរភាព និងភាពស្មើភាពគ្នា។ ក្នុងច្បាប់អប់រំ មាត្រា ២៩ បានចែងថា ៖ រដ្ឋត្រូវបើកទូលាយឱ្យមានការចូលរួមរបស់អ្នកពាក់ព័ន្ធទាំងអស់ មានជាអាទិ ផ្នែក សាធារណៈ ផ្នែកឯកជន អង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍នៅក្នុងដំណើការនៃការអភិវឌ្ឍ ការតាក់តែង ការតាមដាន វាយតម្លៃលើការអនុវត្តការលើកសំណើឱ្យពិនិត្យឡើងវិញ និងសំដៅកែលម្អ គោលនយោបាយ គោលការណ៍ផែនការ និងយុទ្ធសា

ស្រ្តជាតិអប់រំ។ រដ្ឋលើកទឹកចិត្ត និងគាំទ្រដល់ស្ថាប័នឯកជន ដើម្បីបង្កើនភាពជាដៃគូក្នុងការផ្តល់សេវាអប់រំគ្រប់ប្រភេទ និងគ្រប់កម្រិត។

ពិតមែនហើយដំណើរការនៃការអភិវឌ្ឍសាលារៀន ត្រូវបានពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្តតួនាទីរបស់ភាគីពាក់ព័ន្ធនីមួយៗ។ នៅត្រង់ចំណុចនេះសំដៅទៅលើមាតាបិតាសិស្សតែម្តង ដើម្បីឱ្យពួកគាត់មានការយកចិត្តទុកដាក់ជាមួយកូនៗ ក៏ដូចជាជួយតាមដានការសិក្សារបស់កូននៅពេលកូនចេញពីសាលាផងដែរ។ ដូចជាមានការលើកឡើងពីការអប់រំដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្ស ហើយក៏ជាឆ្អឹងខ្នងនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិផងដែរ។ ការអប់រំគ្រប់ទម្រង់ទាំងក្នុងប្រព័ន្ធមិនផ្លូវការ និងក្រៅផ្លូវការ គឺជាការណែនាំដ៏សំខាន់មួយ ដើម្បីធានាបាននូវការអប់រំប្រកបដោយគុណភាព និងសមធម៌ និងរួមបញ្ចូលការលើកកម្ពស់ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ ការសិក្សាពេញមួយជីវិតក្លាយជាប្រធានបទដ៏សំខាន់សម្រាប់ការអប់រំ ហើយវាក៏ជាឧបករណ៍អប់រំដ៏មានប្រយោជន៍មួយផងដែរ ដើម្បីទទួលបានសិទ្ធិសេរីភាព និងសុភមង្គល និងឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារដែលកំពុងកើនឡើង។ ការសិក្សាពេញមួយជីវិតអាចកំណត់ថាជាដំណើរការសិក្សាក្នុងការអប់រំផ្លូវការ មិនផ្លូវការ និងក្រៅផ្លូវការក្នុងជីវិតទាំងមូលរបស់មនុស្សគ្រប់រូប ដើម្បីអភិវឌ្ឍចំណេះដឹង ជំនាញ និងអាកប្បកិរិយា និងការរស់នៅជាមួយគ្នាដោយសន្តិភាព និងសុខដុមរមនា។ ការសិក្សាពេញមួយជីវិតមិនទុកនរណាម្នាក់នៅពីក្រោយឡើយ ហើយផ្តល់លទ្ធភាពទទួលបានសម្រាប់ទាំងអស់គ្នា ជាពិសេសក្រុមដែលងាយរងគ្រោះនូវឱកាសសិក្សានៅក្នុងចំណុចចាប់ផ្តើមណាមួយ។ នៅក្នុងបរិបទនៃសកលភាវូបនីយកម្មក្នុងសតវត្សទី២១ និងការប្រកួតប្រជែងក្នុងតំបន់ និងសកលជាមួយនឹងនិន្នាការសង្គម សេដ្ឋកិច្ច នយោបាយ បរិស្ថាន វប្បធម៌ ឧស្សាហកម្ម និងបច្ចេកវិទ្យា បុគ្គលទាំងអស់ត្រូវក្លាយជាអ្នកសិក្សាពេញមួយជីវិត។ ក្នុងន័យនេះ គោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិតត្រូវបានបង្កើតឡើងដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរដែលបានរៀបរាប់ខាងលើ និងដើម្បីបង្កើនសក្តានុពលនៃការអភិវឌ្ឍធនធានមនុស្សឆ្ពោះទៅរកការសម្រេចបានប្រទេសដែលមានចំណូលមធ្យមកម្រិតទាបនៅឆ្នាំ២០៣០ ដល់ប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៥០ ប្រកបដោយនិរន្តរភាព។ គោលនយោបាយជាតិបង្កប់នូវយុទ្ធសាស្រ្ត ផែនការសកម្មភាព តាម

ដាន និងវាយតម្លៃ និងអនុវត្តគោលការណ៍ជាយន្តការគាំទ្រសម្រាប់ការអភិវឌ្ឍធនធានមនុស្សក្នុងសង្គម និងឆ្លើយតបទៅនឹងតម្រូវការបុគ្គល សង្គម និងតម្រូវការទីផ្សារ(រាជរដ្ឋាភិបាលកម្ពុជា ២០១៩)។

បើយើងក្រឡេកទៅមើលពិភពលោកនាពេលបច្ចុប្បន្ន ក៏ដូចជាប្រទេសក្នុងតំបន់អាស៊ាន យើងឃើញថា កម្ពុជាបានឈានដល់ដំណាក់កាលថ្មីមួយទៀតនៃការអភិវឌ្ឍវិស័យអប់រំ ឆ្លើយតបនឹងបរិបទតំបន់ សកលលោក ដែលមានមហិច្ឆតានិងវិសាលភាពធំទូលាយជាងមុន សំដៅលើកកម្ពស់គុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងការសិក្សាពេញមួយជីវិត ក្នុងក្របខណ្ឌទូលំទូលាយ គ្របដណ្តប់លើគ្រប់ប្រភេទ និងកម្រិតនៃការអប់រំ ជាពិសេស ស្របនឹងទស្សនវិស័យអភិវឌ្ឍន៍កម្ពុជាជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ ២០៣០ និងប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ សមិទ្ធផលអប់រំ និងឧត្តមានុវត្តន៍ជាច្រើនដែលកម្ពុជាទទួលបានពីការអនុវត្តគោលដៅអភិវឌ្ឍន៍សហវត្សរ៍ និងផែនការអប់រំសម្រាប់ទាំងអស់គ្នា គឺជាមូលដ្ឋានដ៏សំខាន់ ដើម្បីឈានទៅសម្រេចការអប់រំក្នុងបរិបទឆ្នាំ២០៣០ខាងមុខ។ វិស័យអប់រំ មានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្សឱ្យមានចំណេះដឹង និងសមត្ថភាពខ្ពស់ ភាពច្នៃប្រឌិត ស្មារតីសហគ្រិនភាព នវានុវត្តន៍ និងប្រកបដោយសីលធម៌ខ្ពស់ ដើម្បីរួមចំណែកលើកកម្ពស់ការអភិវឌ្ឍឧស្សាហកម្ម ដែលជួយបង្កើនកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាបន្ន តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រឹងភាពប្រកួតប្រជែង និងលើកកម្ពស់ផលិតភាព។ ក្នុងន័យនេះ ការអប់រំសម្រាប់ឆ្នាំ២០៣០ ផ្តោតជាសំខាន់លើការផ្តល់សេវាប្រកបដោយគុណភាព សមធម៌ បរិយាបន្ន សម្រាប់អប់រំកុមារតូច បឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា រួមទាំងការអប់រំ បច្ចេកទេស និងវិជ្ជាជីវៈ ជាពិសេសការសិក្សាពេញមួយជីវិតដើម្បីបង្កើនប្រសិទ្ធភាព គុណភាព ផលិតភាពការងារ ស្របតាមយុគសម័យបច្ចេកវិទ្យា ក្នុងការបង្កើនសេដ្ឋកិច្ច និងសុខដុមជីវិតបុគ្គល និងសង្គម។ ការអនុវត្តផែនទីបង្ហាញផ្លូវនេះឱ្យទទួលបានជោគជ័យ តម្រូវឱ្យមានការប្រឹងប្រែងរួមគ្នារវាង ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ វិស័យឯកជន សង្គមស៊ីវិល និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់។ វត្ថុបំណងនៃផែនទីបង្ហាញផ្លូវនេះនឹងសម្រេចបានតាមរយៈផែនការយុទ្ធសាស្ត្រវិស័យអប់រំរយៈពេលមធ្យមទៅតាមដំណាក់កាលនីមួយៗ (ក្រសួងអប់រំ យុវជន និងកីឡា ២០១៩)។

ការទំនាក់ទំនងគឺពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការចូលរួមក្នុងវិស័យអប់រំ រាប់តាំងពីថ្នាក់ក្រសួងរហូតដល់សាលារៀន។ ដោយមើលឃើញពីតម្រូវការចាំបាច់ក្នុងការអនុវត្តតួនាទីរបស់បុគ្គលិក ជាមន្ត្រីរាជការ ក្នុងក្របខណ្ឌក្រសួង អប់រំ យុវជន និងកីឡា ទើបក្រសួងអប់រំ យុវជន និងកីឡា បានចងក្រងជាសៀវភៅយុទ្ធសាស្ត្រស្នូល នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នេះឡើងដើម្បីទុកជាទុនដល់បុគ្គលិកសិក្សាអប់រំទាំងអស់យល់ដឹងបន្ថែមទៀតទៅលើភារកិច្ច និងតួនាទីរបស់ខ្លួន។ សៀវភៅយុទ្ធសាស្ត្រស្នូល នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤។ បានបញ្ជាក់ថា «ការបង្កើតល្បឿនអភិបាលកិច្ចតាមរយៈការធ្វើវិមជ្ឈការអំណាចទៅមូលដ្ឋាន ក្នុងគោលបំណងធ្វើឱ្យសេវាសាធារណៈអាចបម្រើផលប្រយោជន៍ប្រសើរបំផុតសម្រាប់ប្រជាជន និងការកសាងជាតិ»។ របាយការណ៍អភិវឌ្ឍសកលលោកឆ្នាំ២០០៤ ស្តីពីសេវាសាធារណៈ របស់ធនាគារពិភពលោក បានបង្ហាញថា ការឆ្លើយតបនឹងតម្រូវការអប់រំតាមរយៈការសម្រេចចិត្តពីថ្នាក់កណ្តាលតែឯងគឺមិនអាចឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការរៀនសូត្ររបស់សិស្សបានឡើយ ដូចនេះវិស័យអប់រំត្រូវផ្ទេរអំណាចទៅសាលារៀន មាតាបិតាសិស្ស និងសហគមន៍ក្នុងការអនុវត្តសេចក្តីសម្រេចចិត្ត ដើម្បីដោះស្រាយតម្រូវការសិក្សារៀនសូត្រឱ្យបានទាន់ពេលវេលា (ក្រសួងអប់រំ យុវជន និងកីឡា ២០២១)។

ដើម្បីសិក្សារៀនសូត្រស្វែងយល់ពីកិច្ចការនេះ នៅចន្លោះឆ្នាំ២០១៧-២០២០ ក្រសួងអប់រំ យុវជន និងកីឡា តាំងពីថ្នាក់ដឹកនាំគោលនយោបាយ មន្ត្រីថ្នាក់ក្រសួង រួមជាមួយទីប្រឹក្សាក្រសួង និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ គណៈគ្រប់គ្រងសាលារៀន សហគមន៍ មាតាបិតាសិស្ស និងអាជ្ញាធរមូលដ្ឋាន បានផ្តោតថាមពលក្នុងការអនុវត្តឱ្យសម្រេចស្តង់ដាសាលារៀនមានប្រសិទ្ធភាព និងបានអនុវត្តកិច្ចការដែលបានព្រមព្រៀងគ្នា នៅក្នុងសេចក្តីណែនាំស្តីពីការគ្រប់គ្រងតាមសាលារៀន ក៏ដូចជារក្សានូវការផ្លាស់ប្តូរ ព្រមទាំងភាពបត់បែនរបៀបធ្វើការងារជារៀងរាល់ឆ្នាំ ដើម្បីសម្រេចបានវត្ថុបំណងខាងលើ (ក្រសួងអប់រំ យុវជន និងកីឡា ២០២១)។

ទស្សនៈយល់ឃើញរបស់មាតាបិតា មួយចំនួនបានផ្តោតទៅលើគុណភាពនៃការអប់រំចំណេះទូទៅជាការចាំបាច់ដែលធ្វើឱ្យអ្នកសិក្សា ជាពិសេសកូនៗរបស់ពួកគាត់មានការរីកចម្រើនចំណេះដឹង និងសីលធម៌

បុគ្គលិកលក្ខណៈល្អ ដោយលើកកម្ពស់សមត្ថភាពខាងផ្លូវចិត្ត បញ្ញា កាយ ឱ្យចេះប្រើចំណេះដឹង និងបំណិនជាមូលដ្ឋាន។ ការអប់រំមធ្យមសិក្សា សំដៅលើកម្រិតវិទ្យាល័យ ឬថ្នាក់មធ្យមសិក្សាទុតិយភូមិពីថ្នាក់ទី១០ ដល់ទី១២ ត្រូវបានបណ្តុះបណ្តាលបុគ្គលិកលក្ខណៈពេញលេញដោយពង្រីកវិសាលភាពចំណេះដឹង បំណិនការអប់រំវិជ្ជាជីវៈ ការអប់រំសីលធម៌ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីបន្តទៅឧត្តមសិក្សា ឬ បណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈឬចូលរួមក្នុងជីវភាពសង្គម (រាជរដ្ឋាភិបាល ២០០៧)។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

មាតាបិតាមានតួនាទីយ៉ាងសំខាន់ ក្នុងការណែនាំអប់រំកូនឱ្យក្លាយជាមនុស្សល្អ ក៏ដូចជាគ្រូទី១របស់សិស្ស ដែលបានបង្ហាត់កូន ឱ្យចេះដើរ និយាយ រាប់លេខ អក្សរ និងចេះគូសវាស។ បណ្តុះមូលដ្ឋានផ្នែកបញ្ញា ស្មារតី សតិអារម្មណ៍ អភិវឌ្ឍប្រព័ន្ធតម្លៃ សីលធម៌ អាកប្បកិរិយារបស់កូនមុនពេលចូលសាលា និងក្រោយពេលចេញពីសាលា។ ប៉ុន្តែទោះជាយ៉ាងនេះក្តី មានមាតាបិតាមួយចំនួនពឹងផ្អែកទាំងស្រុងទៅលើសាលារៀន ពួកគាត់យល់ថាការអប់រំកូនៗរបស់ពួកគាត់គឺជាបន្ទុកនិងតួនាទីរបស់សាលារៀនហើយក៏មានមាតាបិតាខ្លះមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការជួយកូនដែរ ដូចជាពួកគាត់មិនមានពេលវេលាគ្រប់គ្រាន់ ចំណេះដឹងមានកម្រិត ជីវភាពខ្វះខាតជាដើម។ ដូចនេះពួកគាត់មិនសូវយល់ដឹងស៊ីជម្រៅនូវ ខ្លឹមសារមេរៀននិងពិបាកពន្យល់កូន (Chhorn, 2020)។

បច្ចុប្បន្នមានទស្សនៈមួយចំនួនបានលើកឡើងពីក្នុងមជ្ឈដ្ឋានសង្គមផ្តោតការយកចិត្តទុកដាក់លើលទ្ធផលសិក្សារបស់កូនៗតាមរយៈការវិនិយោគ ការអប់រំកូនជាមួយសាលាដែលមានបង់ថ្លៃឈ្នួលខ្ពស់។ មាតាបិតារំពឹងថាការអប់រំកុមារ(កូនៗ)ជាកាតព្វកិច្ចរបស់សាលារៀន ដូចមានទស្សនៈលើកឡើងថា ពេលកូនរៀនពូកែគឺមកពីពូជពង្សគេល្អ តែលទ្ធផលការសិក្សាមិនល្អគឺមកពីគ្រូបង្រៀនទៅវិញ។ យោងតាមការសង្កេតជាក់ស្តែង មាតាបិតាតែងតែផ្តល់លទ្ធភាពឱ្យកូនរៀនជាលក្ខណៈបំប៉នជាមួយគ្រូក្រៅម៉ោងជាជាងពួកគាត់ចំណាយពេលជួយបង្រៀន ឬតាមដានការសិក្សារបស់កូន។ ម្យ៉ាងទៀត ទំនាក់ទំនងរវាងមាតាបិតានិងសាលារៀនជារឿងសំខាន់ ប៉ុន្តែទំនាក់ទំនងនេះមិនទាន់ផ្តោតឱ្យចំទៅលើការផ្តល់ព័ត៌មានស៊ី

ជម្រៅលើកិច្ចសហការដើម្បីធ្វើឱ្យការសិក្សានិងការអប់រំទាន់ពេលវេលានិងប្រសើរឡើងទេ។ ជាលទ្ធផលនៃការជួយមិនទាន់ពេលវេលាអាចធ្វើឱ្យសិស្សខាតបង់ឱកាសកែលម្អ និងអភិវឌ្ឍសមត្ថភាពតាមកម្រិតនឹងឈានទៅដល់ការបោះបង់ការសិក្សាទៀតផង។ មាតាបិតាភាគច្រើនយល់ថា សាលាផ្តល់ព័ត៌មានដល់មាតាបិតាពេលដែលសិស្សមានអវិជ្ជមាននៃកំហុសជាជាងផ្តល់ព័ត៌មានអំពីកាលវិភាគសាលា ឬការអនុវត្តនៅក្នុងថ្នាក់រៀនរបស់សិស្ស។ ជាក់ស្តែងតាមការសិក្សាស្រាវជ្រាវមួយចំនួនបានបង្ហាញឱ្យឃើញថា ការមិនចូលរួមរបស់មាតាបិតាដោយសារការបាក់បែកគ្រួសារ មាតាបិតាប្រើហិង្សា គ្រួសារមានជីវភាពលំបាក ការមិនឱ្យតម្លៃទៅលើការសិក្សារបស់កូនៗ ចំណេះដឹងរបស់មាតាបិតាមិនគ្រប់គ្រាន់។ មាតាបិតាដែលមានជីវភាពសមរម្យ និងមានចំណេះដឹងអាចចូលរួមក្នុងការអប់រំកូន ជាងមាតាបិតាដែលមានជីវភាពខ្វះខាតនិងចំណេះដឹងតិចតួច។ មាតាបិតាខ្លះពុំមានពេលវេលាគ្រប់គ្រាន់ក្នុងការចូលរួមចំពោះការអប់រំកូនទេ ពួកគាត់ជាប់រវល់មុខរបរឬការងារ (Chhorn, 2020)។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងចំនួន២គឺ៖

(១) ស្វែងយល់ពីទស្សនៈរបស់មាតាបិតាសិស្ស ចំពោះតួនាទីរបស់ខ្លួន ក្នុងការចូលរួមចំណែកជួយការអប់រំ និងការសិក្សារបស់កូនៗ នៅមធ្យមសិក្សាទុតិយភូមិ។

(២) ស្វែងរកពីឧបសគ្គនានារបស់មាតាបិតាសិស្ស ចំពោះតួនាទីរបស់ខ្លួន ក្នុងការចូលរួមចំណែកជួយការអប់រំ និងការសិក្សារបស់កូនៗ នៅមធ្យមសិក្សាទុតិយភូមិ។

## ១.៤ សំណួរស្រាវជ្រាវ

(១) តើមាតាបិតា គ្រូបង្រៀន និងសិស្សានុសិស្ស មានទស្សនៈយល់ឃើញ កម្រិតណា ចំពោះតួនាទីរបស់មាតាបិតា ក្នុងការចូលរួមចំណែកជួយការអប់រំ និងការសិក្សារបស់កូនៗ នៅមធ្យមសិក្សាទុតិយភូមិ?

(២) តើមាន បញ្ហាប្រឈមអ្វីខ្លះ ដែលតែងតែរាំង ដល់ការចូលរួមរបស់មាតាបិតាទៅលើការអប់រំ និងការសិក្សារបស់កូនៗ នៅមធ្យមសិក្សាទុតិយភូមិ?

## ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

លទ្ធផលនៃការស្រាវជ្រាវនេះនឹងផ្តល់ព័ត៌មានផងដែរអំពីអត្ថប្រយោជន៍ក្នុងការរួមចំណែកជួយការអប់រំ និងការសិក្សារបស់កូនៗ ចំពោះតួនាទីរបស់មាតាបិតាសិស្ស ដែលជាបទពិសោធន៍ និងជា ចំណេះដឹងសម្រាប់មាតាបិតាសិស្សដទៃទៀត សម្រាប់លោកគ្រូ អ្នកគ្រូ និងសាលារៀន ក្នុងន័យបង្កើនកិច្ច សហការណ៍រវាងមាតាបិតា និងសាលារៀនឱ្យកាន់តែមានភាពល្អប្រសើរ។ លទ្ធផលនៃការស្រាវជ្រាវនេះមានសារៈសំខាន់ដូចខាងក្រោម៖

- ជាឯកសារដ៏មានសារៈសំខាន់ ក្នុងការស្វែងយល់បន្ថែមទៀតសម្រាប់សិស្ស ក៏ដូចជាអ្នកសិក្សាស្រាវជ្រាវបន្តទៀត។
- បញ្ជ្រាបជាព័ត៌មានដល់មាតាបិតាសិស្ស ឲ្យមានការយល់ដឹងបន្ថែមទៀត ពីគុណប្រយោជន៍ចំពោះតួនាទីក្នុងការរួមចំណែកជួយការអប់រំ និងការសិក្សារបស់កូនៗ ក្នុងការសិក្សានៅក្នុងកម្រិតវិទ្យាល័យ។

## ១.៦ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះធ្វើឡើងនៅវិទ្យាល័យចំនួន៥ នៅក្នុងរាជធានីភ្នំពេញ។ ការសិក្សាស្រាវជ្រាវផ្តោតលើប្រធានបទ «ទស្សនៈរបស់មាតាបិតាសិស្ស ចំពោះតួនាទីក្នុងការរួមចំណែកជួយការអប់រំ និងការសិក្សារបស់កូនៗ នៅកម្រិតវិទ្យាល័យ» (ករណីសិក្សា នៅរាជធានីភ្នំពេញ)។ ការសិក្សាស្រាវជ្រាវនេះគឺបានកំណត់យក វិទ្យាល័យហ៊ុន សែន ចាក់អង្រែ វិទ្យាល័យជា ស៊ីម បឹងកេងកង វិទ្យាល័យពងទឹក វិទ្យាល័យទឹកល្អក់ និងវិទ្យាល័យហ៊ុន សែន បុរី១០០ខ្នង ដែលស្ថិតក្នុងរាជធានីភ្នំពេញ ធ្វើជាភាគសំណាកក្នុងការស្រាវជ្រាវ។ ការជ្រើសរើសវិទ្យាល័យទាំង៥ នៅក្នុងរាជធានីភ្នំពេញ មកធ្វើការស្រាវជ្រាវនេះដោយផ្អែកទៅលើទីតាំងភូមិសាស្ត្រ និងរបាយប្រជាជន កម្រិតជីវភាពក្នុងការរស់នៅប្រចាំថ្ងៃ។ ដើម្បីងាយស្រួលក្នុងការរៀបចំចងក្រងនូវកម្រងសំណួរសម្រាប់ចុះប្រមូលទិន្នន័យពី មាតាបិតាសិស្ស លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការស្រាវជ្រាវនេះចែកចេញជា ៥ជំពូករួមមាន៖

**ជំពូក១៖ សេចក្តីផ្តើម**

នៅក្នុងជំពូកសេចក្តីផ្តើមនេះ អ្នកសិក្សាស្រាវជ្រាវបានលើកឡើង៧ចំណុចសំខាន់ៗ ដែលមានតាមលំដាប់លំដោយដូចជា៖ លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

**ជំពូក២៖ រំលឹកទ្រឹស្តី**

នៅក្នុងជំពូក២នេះ គឺផ្តោតសំខាន់ទៅលើនិយមន័យ និងទ្រឹស្តីមួយចំនួនរបស់អ្នកស្រាវជ្រាវមុនៗ ឬជាទស្សនៈយល់ឃើញរបស់គិតិបណ្ឌិតអ្នកប្រាជ្ញ របស់អ្នកនិពន្ធរៀមច្បងគ្រប់ជំនាន់ដែលផ្សារភ្ជាប់ទៅនឹងប្រធានបទនៃការស្រាវជ្រាវ ដើម្បីធ្វើការគាំទ្រ និងផ្ទៀងផ្ទាត់លទ្ធផលការសិក្សានេះ ដែលជារួម មានដូចជាដំណើរការនៃ តួនាទីក្នុងការរួមចំណែកជួយការអប់រំ និងការសិក្សារបស់កូនៗ កត្តាជះឥទ្ធិពលដល់ការចូលរួមរបស់មាតាបិតា និងយុទ្ធសាស្ត្រក្នុងការជំរុញនិងលើកទឹកចិត្តមាតាបិតាក្នុងការសិក្សានិងអប់រំរបស់កូន។ រាល់ទ្រឹស្តីរបស់អ្នកសិក្សាស្រាវជ្រាវមុនៗ ដែលពាក់ព័ន្ធនឹងប្រធានបទនេះត្រូវបានលើកឡើងដើម្បីធ្វើជាគំនិត និងឆ្លុះបញ្ចាំងទៅនឹងការរកឃើញថ្មីៗ នៅក្នុងស្នាដៃស្រាវជ្រាវនេះផងដែរ។

ជំពូក៣៖ វិធីសាស្ត្រស្រាវជ្រាវ

ក្នុងជំពូកនេះផងដែរ អ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញនូវការជ្រើសរើសសំណាក ឧបករណ៍ស្រាវជ្រាវ រចនាសម្ព័ន្ធនៃកម្រងសំណួរ ការប្រមូលទិន្នន័យ និងការវិភាគទិន្នន័យដែលប្រមូលបាន។

**ជំពូក៤៖ លទ្ធផល និងការពិភាក្សា**

លទ្ធផលនៃការស្រាវជ្រាវ នឹងត្រូវបានយកមកបកស្រាយ និងពិភាក្សាយ៉ាងក្បោះក្បាយ ដើម្បីរកឱ្យឃើញនូវចំណុចល្អ និងចំណុចដែលត្រូវធ្វើឱ្យប្រសើរឡើងវិញនៅក្នុងស្ថានភាពជាក់ស្តែងរបស់សាលារៀននីមួយៗ។

នៅក្នុងជំពូកនេះ អ្នកសិក្សាធ្វើការបកស្រាយ និងវិភាគទៅលើចំណុច៣ធំៗគឺ ១)ទស្សនៈរបស់មាតាបិតាសិស្ស ចំពោះតួនាទីក្នុងការរួមចំណែកជួយការអប់រំ និងការសិក្សារបស់កូនៗ ២)កត្តាដែលជះឥទ្ធិពលចំពោះតួនាទីក្នុងការរួមចំណែកជួយការអប់រំ របស់មាតាបិតាទៅលើការអប់រំកូនៗ និង ៣)សកម្មភាពមួយចំនួនដែលមាតាបិតាត្រូវចូលរួមក្នុងការអប់រំកូនៗ។

**ជំពូក៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ**

នេះជាផ្នែកដែលអ្នកស្រាវជ្រាវ ធ្វើការសន្និដ្ឋានទៅលើចំណុចទាំងអស់ដែលបានយកមកវិភាគ ព្រមទាំងលើកឡើងនូវសំណូមពរមួយចំនួនក្នុងគោលបំណងលើកកម្ពស់ទស្សនៈរបស់មាតាបិតាសិស្ស ចំពោះតួនាទីក្នុងការរួមចំណែកជួយការអប់រំ និងការសិក្សារបស់កូនៗ។ ធ្វើការសង្ខេបលម្អិតឡើងវិញ អំពីលទ្ធផលនៃការវិភាគ និងការបកស្រាយទិន្នន័យដែលបានពីការចុះប្រមូលទិន្នន័យនៅតាមវិទ្យាល័យគោលដៅទាំង៥នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ។ ជាមួយគ្នានេះដែរ ការសន្និដ្ឋាននិងលើកសំណូមពរទៅលើចំណុចខ្វះខាតមួយចំនួនដែលជាបញ្ហាប្រឈមនៃការរួមចំណែករបស់មាតាបិតាក្នុងការជួយការអប់រំ និងសិក្សារបស់កូនៗ សម្រាប់អ្នកសិក្សាក្រោយៗ ដើម្បីធ្វើការបំពេញបន្ថែមទៅលើកិច្ចការស្រាវជ្រាវបន្ត។

# ជំពូក ២

# ការរំលឹកទ្រឹស្តី

# ជំពូក ២

# ការរំលឹកទ្រឹស្តី

## ២.១ សេចក្តីផ្តើម

អ្នកសិក្សាស្រាវជ្រាវ បានសិក្សាលើឯកសារមួយចំនួនដែលទាក់ទងទៅនឹងទស្សនៈរបស់មាតាបិតាសិស្ស ចំពោះតួនាទីក្នុងការរួមចំណែកជួយការអប់រំ និងការសិក្សារបស់កូនៗ តាមរយៈការសិក្សាលើឯកសារទាំងនោះ អ្នកសិក្សាស្រាវជ្រាវអាចទាញយកនូវគន្លឹះមួយចំនួនដើម្បីបង្កើតគោលគំនិតទ្រឹស្តីដើម្បីជាគន្លឹះនិងការបង្កើតកម្រងសំណួរសម្រាប់ការធ្វើសម្ភាសន៍ សិស្ស លោកគ្រូ អ្នកគ្រូ និងគណៈគ្រប់គ្រងសាលារៀន (Sovannara, 2011)។

## ២.២ និយមន័យ និងពាក្យគន្លឹះ

### ក.និយមន័យ «មាតាបិតា»

ដើម្បីឱ្យការបកស្រាយទៅលើប្រធានបទនេះមានភាពជាក់លាក់និងងាយយល់ អ្នកសិក្សាធ្វើការពន្យល់ពាក្យ «មាតាបិតា» គឺជាទេវតាប្រចាំផ្ទះរបស់កូន ជាទេវតាថែរក្សាកូនទាំងយប់ទាំងថ្ងៃ។ ពេលព្រលប់ ពេលយប់ ពេលអធ្រាត្រ មាតាបិតាកំពុងអស់កម្លាំង កំពុងងងុយក្តី កំពុងសម្រាន្តលង់លក់ក្តី កំពុងក្តៅក្តី កំពុងរងាក្តី ទោះជាកំពុងឈឺខ្លួនឯងក្តី កាលបើកូនតូចស្រែកយំឡើង មាតាបិតារមែងស្ទុះស្ទា បើកំពុងលង់លក់ក៏ភ្ញាក់ក្រញាងមកឱបកូន មកបោសអង្អែលយកចិត្តកូន...។ មាតាបិតាប្រុងភ្នែក ប្រុងត្រចៀក ប្រុងសព្វគ្រប់ ប្រុងទាំងយប់ ប្រុងទាំងថ្ងៃ ដើម្បីរក្សាកូនស្ងួនសម្លាញ់ដែលជាសាច់ឈាមរបស់ខ្លួន ទោះជាទេវតាដោយកំណើតមានកិច្ចរក្សានូវលោកនេះ ក៏គង់មានពេលភ្លេចក្នុងកិច្ចរក្សាដែរ ប៉ុន្តែមាតាបិតាមិនធ្លាប់ភ្លេចកូន និងមិនបានបោះបង់កូនឡើយ គឺលោកទាំងពីរតែងគ្រប់គ្រងរក្សាឱ្យកូនបានសុខរហូតមក (សារង្ស ២០១៩)។

ដូច្នោះមាតាបិតាសំដៅលើឪពុកម្តាយ ឬអ្នកអាណាព្យាបាលស្របច្បាប់ ឬបុគ្គលដទៃទៀតដែលជំនួសឱ្យមាតាបិតា ដូចជាលោកយាយ លោកតា ឪពុកម្តាយចុងដែលកូនរស់នៅក្នុងបន្ទុកគ្រួសារជាមួយ

គ្នា ឬបុគ្គលផ្សេងទៀតដែលជាអ្នកទទួលខុសត្រូវស្របច្បាប់ចំពោះសុខមាលភាពរបស់កូន។ មាតាបិតាមានន័យស្មើនឹងឪពុកម្តាយដែរ។ មាតាបិតាមានន័យថាជាអ្នកផ្តល់រូបរាងកាយ អារម្មណ៍ បញ្ញាស្មារតីដល់កូន។ ពួកគាត់ជាអ្នកទទួលខុសត្រូវក្នុងការថែរក្សា សុវត្ថិភាព និងសុខុមាលភាពកូនៗ ព្រមទាំងអប់រំបង្ហាត់បង្រៀនកូនពីអ្វីដែលខុសនិងត្រូវ វិន័យ និងជួយកូនឱ្យសម្រេចបាននូវសក្តានុពលពួកគេ (Chhorn, 2020)។

## ខ.ការចូលរួមចំណែករបស់មាតាបិតា

ចំណុចនេះអាចសន្និដ្ឋានបានថា ការចូលរួមចំណែករបស់មាតាបិតា មិនមាននិយមន័យច្បាស់លាស់ ដូចនៅក្នុងអក្សរសិល្ប៍នោះទេ។ មានន័យថា ការចូលរួមចំណែករបស់មាតាបិតាសិស្សគឺជា «ការវិនិយោគរបស់ឪពុកម្តាយ» ឬអ្នកនៅថែទាំក្នុងការអប់រំកូនរបស់ពួកគេ។ ជាជម្រើស Christen et al (1992) បានបញ្ជាក់ពីរបៀបដែលឪពុកម្តាយដើរតួនាទីក្នុងការអប់រំកូនរបស់ពួកគេ ទាំងការទាក់ទងទៅនឹងផ្ទះ និងការទាក់ទងនឹងសាលារៀន។ ការរួមចំណែករបស់មាតាបិតាសិស្សគឺជាការអន្តរាគមន៍របស់មាតាបិតាសិស្ស ក្នុងការអប់រំកូន ដើម្បីអាចទទួលបានព័ត៌មានអំពីការលូតលាស់ផ្នែកសិក្សាកូនរបស់ពួកគេ ការរួមចំណែកនៅពេលដែលគេកំណត់ការចូលរួមរបស់មាតាបិតាCrozier(1999)។ ការរួមចំណែកពីក្រុមគ្រួសារ និងសហគមន៍ជាញឹកញាប់មានន័យថា ការជួយដល់គោលដៅដែលកំណត់ដោយមាតាបិតា (អ្នកគ្រប់គ្រង និងគ្រូបង្រៀន) ដែលឆ្លុះបញ្ចាំងពីតម្លៃ និងអាទិភាពរបស់សាលាប៉ុណ្ណោះ(Jordan et al.,2001,p10)។ Barge and Loges(2003) បានកំណត់ថាទស្សនៈ និងវិធីសាស្ត្ររបស់គ្រូ សិស្ស និងការរួមចំណែករបស់មាតាបិតាគឺខុសគ្នា។ ពួកគេបានរកឃើញថា សម្រាប់ការចូលរួមរបស់មាតាបិតា ឬអាណាព្យាបាលសំដៅទៅលើ៖ ការត្រួតពិនិត្យជាប្រចាំលើកិច្ចការផ្ទះរបស់សិស្សដោយមាតាបិតា។ មាតាបិតាបានរាយការណ៍ថា វាចាំបាច់ណាស់ក្នុងការធ្វើឱ្យប្រាកដថាកូនរបស់ពួកគេបានធ្វើកិច្ចការផ្ទះរបស់ពួកគេទាំងស្រុង និងដើម្បីជួយពួកគេនៅពេលចាំបាច់។ ការបង្កើតទំនាក់ទំនងបុគ្គលជាមួយគ្រូ មាតាបិតាបានគិតថា ប្រសិនបើពួកគេមានទំនាក់ទំនងគ្រប់គ្រាន់ជាមួយគ្រូ ហើយគ្រូបង្រៀនឃើញថាពួកគេយកចិត្តទុកដាក់ចំពោះកូនរបស់គេនោះការប្រព្រឹត្តរបស់គ្រូចំពោះកូនកាន់តែប្រសើរ។ ទាញយកអត្ថប្រយោជន៍

ពីកម្មវិធីសិក្សានៅសាលា ជាពិសេស មាតាបិតាដែលមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការជួយកូនចំពោះកិច្ចការផ្ទះ ឬកិច្ចការដែលទាក់ទងនឹងកម្មវិធីសិក្សាផ្សេងទៀត បញ្ជាក់ពីសារៈសំខាន់នៃការចូលរួមនេះ។ ធ្វើឱ្យប្រសើរឡើងនូវកិច្ចសហការគាំទ្រនៅក្នុងសហគមន៍។ យោងតាមរបាយការណ៍របស់មាតាបិតា ការអភិវឌ្ឍក្នុងសហគមន៍ដើរតួនាទីយ៉ាងសំខាន់ក្នុងសមិទ្ធផលអប់រំរបស់សិស្ស។ ដូចដែល Barge and Loges(2003) បានរកឃើញសម្រាប់ការរួមចំណែករបស់មាតាបិតាសិស្សមានន័យថា៖

- ជាជំនួយឪពុកម្តាយជាមួយកិច្ចការផ្ទះ

- ការលើកទឹកចិត្តពីឪពុកម្តាយ

- ទំនាក់ទំនងរវាងឪពុកម្តាយ និងសាលារៀន

វាច្បាស់ណាស់ថា ការរួមចំណែករបស់មាតាបិតា គឺការចូលរួមលើគ្រប់ទិដ្ឋភាពនៃការអប់រំកូន និងការអភិវឌ្ឍតាំងពីចាប់កំណើតរហូតដល់ពេញវ័យ។ ការរួមចំណែករបស់មាតាបិតា គឺមានន័យថាការចូលរួមរបស់មាតាបិតាដោយពាក់ព័ន្ធលើការរៀនសូត្ររបស់សិស្សជាប្រចាំ និងសកម្មភាពផ្សេងៗទៀតនៅក្នុងសាលារៀនដោយជានាថា៖

- មាតាបិតាជាអ្នកដើរតួសំខាន់ក្នុងការជួយសង្គ្រោះកូនរបស់គាត់

- មាតាបិតាត្រូវបានលើកទឹកចិត្តឱ្យចូលរួមយ៉ាងសកម្មលើការអប់រំកូនក្នុងសាលារៀន

- មាតាបិតាជាដៃគូរពេញលេញលើការអប់រំកូន ហើយត្រូវបានរួមបញ្ចូលដូចជា៖ ការសម្រេចចិត្តសមស្រប និងជាគណៈកម្មការផ្តល់ប្រឹក្សាដើម្បីជួយសង្គ្រោះការអប់រំរបស់កូន (Javarov,2015)។

ជាលទ្ធផល ការចូលរួមរបស់មាតាបិតា ពុំមាននិយមន័យណាមួយពិតប្រាកដ ជាសកលអំពីការចូលរួមរបស់មាតាបិតា ឬអ្នកអាណាព្យាបាលដែលបញ្ជាក់ពីភាពចាំបាច់នោះទេ។ និយមន័យមួយចំនួនរួមបញ្ចូលទាំងការចូលរួមកាន់តែធំឡើងអំពីជីវិតនៅក្នុងការសិក្សា ទន្ទឹមនឹងអ្នកដទៃទៀតបានផ្តោតអារម្មណ៍ទៅលើការចូលរួមកាន់តែកើនឡើងចំពោះដំណើរការរៀនរបស់កុមារនីមួយៗ រហូតមកដល់ពេលនេះ អ្នកឯទៀតបានរួមបញ្ចូលគ្រួសារចូលទៅក្នុងដំណើរការរៀនសូត្រ តាមរយៈការអប់រំមនុស្សពេញវ័យ និងការធ្វើជាមាតាបិតា ក្រោយពីសកម្មភាពរៀននៅសាលាចប់។ សាលារៀនឈានមុខមួយចំនួន បានឱ្យគ្រួសារ

ចូលរួមពាក់ព័ន្ធទៅនឹងអភិបាលកិច្ចនិងដំណើរការធ្វើផែនការ ការកសាងភាពជាម្ចាស់ដ៏ទូលំទូលាយនៃគោលដៅសមិទ្ធផលរបស់សិស្ស។ ម៉្យាងវិញទៀតការចូលរួម របស់មាតាបិតា កើតឡើងនៅពេលដែលពួកគាត់ចូលរួមយ៉ាងសកម្មជិតដល់ ដោយមានធនធាន និងប្រកបដោយការទទួលខុសត្រូវក្នុងការលើកស្ទួយ និងអភិវឌ្ឍន៍សុខមាលភាពរបស់សហគមន៍ពួក គេ Family Strengthening Policy Center (២០០៤) (Sovannara, 2011) ។

## ២.៣ ដំណើរការចំពោះតួនាទីក្នុងការចូលរួមចំណែកអប់រំកូនរបស់មាតាបិតា

### ២.៣.១ ការតាមដានការសិក្សារៀនសូត្ររបស់កូន

ការអប់រំមិនមែនជាបន្ទុករបស់សាលារៀនតែម្នាក់ឯងទេ ប៉ុន្តែជាការចូលរួមចំណែករបស់សហគមន៍ និងមាតាបិតាផងដែរ។ ដូចនេះមាតាបិតាត្រូវ៖

១.ជួយអប់រំកូនបន្ថែម និងជំរុញឱ្យខំរៀនសូត្រ និងបង្កលក្ខណៈទាំងសម្ភារៈនិងពេលពេលវេលាជាពិសេសកូនស្រី។

២.ទំនាក់ទំនងជាមួយលោកគ្រូ អ្នកគ្រូឱ្យបានញឹកញាប់ដោយផ្ទាល់មាត់ និងលោកនាយកសាលារៀន ដើម្បីកាត់បន្ថយអត្រាត្រួតថ្នាក់ និងករណីសិស្សបោះបង់ការសិក្សា។

៣.ចូលរួមប្រជុំដើម្បីទទួលព័ត៌មានពីសាលារបស់កូនចៅ។

៤.ជួយផ្តល់មតិយោបល់ ដែលមានប្រយោជន៍ដល់សាលារៀន ជាពិសេសជាមួយគណៈគ្រប់គ្រងសាលា។

៥.ជួយផ្តល់បទពិសោធន៍ដល់ការបង្រៀនសិស្ស។

៦.ជួយឧបត្ថម្ភដល់កុមារជួបការលំបាក។

៧.ជួយអប់រំផ្លូវចិត្ត អាកប្បកិរិយា និងសីលធម៌ សុជីវធម៌ដល់សិស្ស។

៨.ជួយផ្តល់ជំនាញបច្ចេកទេស ក្នុងការអប់រំវិជ្ជាជីវៈដល់សិស្ស

៩.តាមដានត្រួតពិនិត្យការសិក្សារបស់កូននៅសាលារៀន និងជួយបង្រៀននៅផ្ទះ។

១០.ជួយឧបត្ថម្ភ និងផ្តល់នូវមូលដ្ឋានសម្ភារៈដែលមាននៅក្នុងមូលដ្ឋាន ដើម្បីបម្រើដល់សកម្មភាពរៀន និងបង្រៀនដល់សិស្ស ដូចជា សម្ភារៈសម្រាប់ផលិត សម្ភារៈឧបទ្ទេស។ល។

(ក្រសួងអប់រំ យុវជន និងកីឡា ២០១៣)

### ២.៣.២ ការរួមចំណែកពីមាតាបិតានៅសាលារៀន

ដើម្បីបញ្ជាក់អំពីកិច្ចការធ្វើរួមគ្នា គឺគណៈកម្មការ នាយកគ្រប់គ្រង និងបុគ្គលិកសាលារៀនតាំងចិត្តបង្កើតជាកិច្ចការផ្សេងៗសម្រាប់ទាក់ទាញការរួមចំណែកពីមាតាបិតាតាមទំហំ និងគុណភាពត្រឹមត្រូវដើម្បីបង្កើតជាដៃគូយ៉ាងស័ក្តិសិទ្ធវវាងសាលារៀន និងតាមផ្ទះ តាមរយៈ...

១.ការទាក់ទាញពីមាតាបិតា/អ្នកគ្រប់គ្រងនៃសិស្សសំរាប់បង្កើតរួមគ្នាអំពីគម្រោងការណ៍ ដើម្បីផ្តល់ជាកម្មវិធីផ្សេងៗសំរាប់ជួយបង្កើតគុណភាពផ្នែកសិក្សានៅតាមសាលារៀន ដែលរាប់បញ្ចូលមាតាបិតាជាអ្នកជួយសើរើ និងស្វែងរកមធ្យោបាយបង្កើនភាពលូតលាស់។

២.ធ្វើការពិគ្រោះជាបន្តបន្ទាប់ជាមួយមាតាបិតា/អ្នកគ្រប់គ្រងនៃសិស្សអំពីបញ្ហាផ្សេងៗ ដែលសាលារៀននិងមាតាបិតា/អ្នកគ្រប់គ្រងនៃសិស្សអាចធ្វើបានអំពីភាពលូតលាស់ទៅមុខសំរាប់សិស្ស និងសាលារៀន។

៣.ផ្តល់ជំនួយផ្សេងៗចាំបាច់ ដើម្បីជួយសាលារៀនអំពីរបៀបរៀបចំ និងធ្វើតាមគម្រោងការណ៍ សំរាប់នាំភាពស័ក្តិសិទ្ធចំពោះការរួមចំណែកពីមាតាបិតា/ក្រុមគ្រួសារ ដែលជួយបង្កើនភាពលូតលាស់ផ្នែកសិក្សាសម្រាប់សិស្ស និងសាលារៀន។

៤.ផ្តល់ជំនួយទៅកាន់ការប្រឹងប្រែងរបស់មាតាបិតា/អ្នកគ្រប់គ្រងនៃសិស្សរបស់ពួកគាត់រៀងៗខ្លួនឱ្យយល់និងរៀនទាន់កម្រិតខ្នាតគំរូសិក្សា និងការប្រឡងតេស្ត ទូទៅពីរដ្ឋ។

៥.បង្កើនគុណភាពខ្ពស់សំរាប់ការរួមចំណែកពីមាតាបិតា និងផ្តល់ឱកាសសំរាប់មាតាបិតា/អ្នកគ្រប់គ្រងនៃសិស្សពង្រឹងសមត្ថភាពរបស់ពួកគាត់រៀងៗខ្លួនអំពីផ្នែកអប់រំ និងប្រើអក្សរ ដើម្បីជួយជាស់តឿនសិស្សរបស់ពួកគាត់ឱ្យបានរៀនគ្រប់ផ្នែកសិក្សា និងចិត្តគំនិត រួមទាំងការរៀបចំនៅក្នុងផ្ទះជាកន្លែងមួយដ៏សំខាន់សំរាប់ធ្វើកិច្ចការផ្ទះ(Homework) បង្កើនគោលគំនិតខ្ពស់ និងដោះស្រាយបញ្ហាផ្សេងៗដោយខ្លួនឯង។

៦.ធ្វើការបញ្ជាក់ថា ព័ត៌មានទាក់ទងការប្រជុំ និងកម្មវិធីផ្សេងៗនៅតាមសាលារៀន និងសំរាប់មាតាបិតា គឺនឹងផ្ញើជូនមាតាបិតាឱ្យបានសមស្របត្រឹមត្រូវមែនតាមរយៈបង្ហាញជាភាសាកំណើត ដែលពួកគាត់យល់នៅពេលណាមានសិស្សប្រើភាសាផ្សេងនៅផ្ទះក្រៅពីភាសាអង់គ្លេស។

៧. បង្ហាត់មាតាបិតា/អ្នកគ្រប់គ្រងនៃសិស្ស និង គ្រូបង្រៀនឲ្យចេះបង្កើនជាដៃគូរវាងផ្ទះ និងសាលារៀន ដើម្បីជួយសិស្សឲ្យមានភាពលូតលាស់ និង បង្កើនទំនាក់ទំនងទៅមករវាងគ្នាយ៉ាងស្និទ្ធស្នាលជាភាសា ដែលមាតាបិតាទាំងអស់អាចងាយយល់ និងផ្តល់ជាក្រដាសកិច្ចសន្យា រវាងសាលារៀន និងផ្ទះ ដែលបញ្ជាក់មុខងារទទួលខុសត្រូវស្មើគ្នារវាងបុគ្គលិកសាលារៀន មាតាបិតា និង សិស្សអំពីការបង្កើតភាពលូតលាស់ផ្នែកសិក្សាសំរាប់សិស្ស។

៨. ផ្តល់កម្មវិធីហ្វឹកហ្វឺនទៅកាន់គ្រូបង្រៀន អ្នកផ្តល់ឱវាទ នាយកសាលា និង បុគ្គលិកផ្សេងៗ តាមរយៈទទួលយោបល់ពីមាតាបិតាអំពីរបៀបធ្វើទំនាក់ទំនង និង ការបង្កើតកម្មវិធីស័ក្តិសិទ្ធិសំរាប់បង្កើនដៃគូរវាងមាតាបិតា និង សាលារៀន។

៩. ចាត់ចែង និងរក្សាមជ្ឈមណ្ឌលមាតាបិតា (ស្របតាមសមត្ថភាពថវិកា) ជាកន្លែងផ្តល់ថ្នាក់បង្ហាត់អក្សរ កិច្ចការសំរាប់យកទៅធ្វើនៅតាមផ្ទះ និង កម្មវិធីណែនាំសំរាប់មាតាបិតាតាមសេចក្តីត្រូវការអំពីរបៀបជួយសិស្សរបស់ពួកគាត់ឲ្យរៀនប្រកប (Longbeachunifiedschooldistrict, 2017)។

### ២.៣.៣ ការជំរុញ និងការលើកទឹកចិត្ត

ការជំរុញ និងលើកទឹកចិត្តរបស់ឪពុកម្តាយ ឬលោកគ្រូ អ្នកគ្រូពិតជាមានឥទ្ធិពលដល់ការសិក្សារបស់ កូនឱ្យកាន់តែប្រសើរឡើង។ យោងតាមទ្រឹស្តីនៃការអប់រំកុមាររបស់លោក Rechard ការលើកទឹកចិត្តគឺជា ការជំរុញនរណាម្នាក់ឱ្យចង់ធ្វើអ្វីមួយ។ ការលើកទឹកចិត្តចែកជាពីរ គឺការលើកទឹកចិត្តខាងក្រៅ និងការ លើកទឹកចិត្តខាងក្នុង (Richard M. Ray&Edward , 2000) ។ កុមារត្រូវការជា ចាំបាច់នូវការជំរុញ និងលើកទឹកចិត្តពីមនុស្សធំដែលនៅជុំវិញខ្លួនពួកគេ ជាពិសេសគឺឪពុកម្តាយ (Bando, 2013)។ គ្រូនិងឪពុកម្តាយ ទទួលខុសត្រូវក្នុងការគាំទ្រ ផ្តល់ការលើកទឹកចិត្តដល់កុមារ នៅពេលដែលពួកគេបំពេញកិច្ចការសាលា។ សកម្មភាពចូលរួមរបស់ឪពុកម្តាយជះឥទ្ធិពលដល់សមិទ្ធផល សិក្សារបស់សិស្សតាមរយៈការបង្កើតគំរូ ការជំរុញលើកទឹកចិត្ត និងការណែនាំបង្ហាត់បង្រៀន (Dampsey, 2001)។ ការជំរុញ និងការផ្តល់រង្វាន់ចំពោះការខិតខំប្រឹងប្រែងធ្វើការផ្ទះ ទទួលស្គាល់និងផ្តល់ ការគាំទ្រផ្នែកស្មារតី ដល់ការ

អនុវត្ត សមត្ថភាពការខិតខំប្រឹងប្រែងរបស់កូន។ សិស្សម្នាក់ៗមានតម្រូវការផ្ទាល់ខ្លួនខុសៗគ្នានៅពេលឪពុកម្ដាយផ្ដល់នូវតម្រូវការនិងការលើកទឹកចិត្តសមស្រប ពួកគេនឹងទទួល បានអត្ថប្រយោជន៍ដ៏ច្រើន (Hong and Lee, 2012)។ ឧទាហរណ៍ សិស្សងាយនឹងធុញថប់ ឬរឹងទទឹង នឹងការសិក្សាត្រូវបានទទួលប្រយោជន៍ពីការត្រួតពិនិត្យ និងតាមដានពីឪពុកម្ដាយ ដូចសិស្សដែលចូលចិត្តរៀនសូត្រដែរ។ ចំណែកឯ (Ball &Blachman, 1991) បានបង្ហាញថាការចូលរួមរបស់ឪពុកម្ដាយ អាចលើកទឹកចិត្តដល់កូនៗ នូវសមិទ្ធផលជាច្រើនតាមមធ្យោបាយផ្សេងៗ។ ការជំរុញ និងការលើកទឹកចិត្ត របស់ឪពុកម្ដាយចំពោះការសិក្សារបស់កូនមានសារៈសំខាន់ណាស់មិនថាការលើកទឹកចិត្តផ្នែកសម្ភារៈឬក៏ស្មារតីទេ។ ក្នុងការលើកទឹកចិត្តកូនឪពុកម្ដាយត្រូវប្រើវិធីសាស្ត្រដូចជា ឪពុកម្ដាយពិភាក្សាជាញឹកញាប់អំពីសារៈសំខាន់នៃការអប់រំដល់កូន នាំកូនធ្វើលំហាត់ឬកិច្ចការផ្ទះ នាំកូនអានសៀវភៅ និទានរឿងឲ្យពួកគេស្ដាប់ និងនាំពួកគាត់ដើរកម្សាន្តជាដើម។ ឪពុកម្ដាយលើកទឹកចិត្តកូនតាមរយៈការសរសើរនូវអ្វីដែលគេធ្វើបានល្អប្រសើរ ធ្វើជាគំរូល្អដល់កូន ផ្ដល់អាហារ ដែលមានតុល្យភាព និងថែទាំសុខភាពកុមារឱ្យបានល្អ ផ្ដល់រង្វាន់ដល់ពួកគេផ្ដល់ឱកាសឲ្យពួកគាត់មានភាពម្ចាស់ការ ផ្ដល់ក្ដីស្រលាញ់ដល់ពួកគាត់ជាដើម (Chhorn, 2020)។

### ២.៣.៤ ភាពជាដៃគូរវាងសាលារៀន និងគ្រួសារ

ភាពជាដៃគូរវាងគ្រួសារនិងសាលារៀនគឺជាផ្នែកមួយសំខាន់ក្នុងការផ្លាស់ប្ដូរព័ត៌មានរវាងឪពុកម្ដាយ និងសាលារៀន គ្រូ ទាក់ទងទៅនឹងការសិក្សារបស់កុមារ ហើយក៏ជាផ្នែកមួយនៃការត្រួតពិនិត្យតាមដាន លទ្ធផលសិក្សា និងឥរិយាបថរបស់កុមារផងដែរ ដែលនាំឲ្យឪពុកម្ដាយ និងគ្រូជួយកុមារទាន់ពេលវេលា។ យោងតាមការសិក្សាស្រាវជ្រាវជាច្រើន បានបង្ហាញឲ្យឃើញថា ភាពជាដៃគូរវាងគ្រួសារ និងសាលារៀនបានផ្ដល់មកនូវអត្ថប្រយោជន៍ជាច្រើនសម្រាប់សិស្ស និងគាំទ្រប្រព័ន្ធអប់រំទាំងមូល ដែលក្នុងនោះរួមមានធ្វើឱ្យប្រសើរឡើងនូវឥរិយាបថរបស់សិស្ស បង្កើនសកម្មភាពក្នុងថ្នាក់ កាត់បន្ថយអត្រាបោះបង់ការសិក្សា កាត់បន្ថយអត្រាត្រួតថ្នាក់ និងធ្វើឱ្យសិស្សមានការគោរពខ្លួនឯងខ្ពស់។ ឪពុកម្ដាយពេញចិត្តនឹងការទំនាក់ទំនងជាមួយសាលារៀនកាន់តែខ្លាំង កូនរបស់ពួកគាត់ទទួលបានភាពជោគជ័យរឹតតែខ្លាំង (Sylvie Normandeau and Isabell Nadon, 2020)។ ទំនាក់ទំនងរវាងឪពុកម្ដាយ និងគ្រូ គឺអាស្រ័យទៅលើ

ឥរិយាបថ របស់គ្រូផងដែរ។ ឥរិយាបថរបស់គ្រូ គឺមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការអនុវត្ត សកម្មភាពអប់រំ ប្រកបដោយជោគជ័យ (Sha, 2016)។ គ្រូបង្រៀន គឺជាកត្តាកំណត់ខ្ពស់បំផុតទី២ ក្នុងការអភិវឌ្ឍបុគ្គលិកលក្ខណៈបន្ទាប់ពីឪពុកម្ដាយ។ គ្រូជាគំរូរបស់សិស្ស គ្រូក៏ជាអ្នកផ្ដល់ព័ត៌មាន ហើយគ្រូជាអ្នកចំណាយពេលច្រើនជាងគេ បន្ទាប់ពីឪពុកម្ដាយ។ ទាំងនេះជាមូលហេតុដែលឥរិយាបថ និងអាកប្បកិរិយារបស់គ្រូមានឥទ្ធិពលទៅលើការអភិវឌ្ឍរបស់សិស្ស ថាពួកគាត់ទទួលបានជោគជ័យឬអត់ (Chhorn, 2020)។

### ២.៣.៥ ការចូលរួមរបស់ឪពុកម្ដាយចំពោះការអប់រំរបស់កូន

បើយោងតាមឯកសារដែលសរសេរឡើងដោយ Department for Children, School, and Family (2008) បានបញ្ជាក់ថា សិស្សភាគច្រើនមានអ្នកអប់រំពីរ ដែលជាមូលដ្ឋានដ៏សំខាន់សម្រាប់ជីវិតរបស់ពួកគេគឺ៖ ឪពុកម្ដាយ ឬអ្នកអាណាព្យាបាល និងលោកគ្រូ អ្នកគ្រូ។ Department for Children, School, and Family (2008) ក៏បានបញ្ជាក់ដែរថា ឪពុកម្ដាយ គឺជាអ្នកអប់រំដំបូង ចាប់តាំងពីកុមារចាប់កំណើតរហូតទាល់តែកុមារចាប់ផ្ដើមចូលរៀននៅឆ្នាំដំបូង ហើយពួកគាត់នៅតែមានឥទ្ធិពលសំខាន់ទៅលើការសិក្សារបស់កូន ទាំងសាលារៀន ទាំងឪពុកម្ដាយ ដើរតួនាទីយ៉ាងសំខាន់។ ពុំមានការយល់ស្របជាសកលណាមួយស្ដីពីការចូលរួមរបស់មាតាបិតា ឬ អ្នកអាណាព្យាបាលទៅលើការអប់រំនោះទេ។ មានទម្រង់នៃការចូលរួមជាច្រើនតាមរយៈការសិក្សានេះ ដូចជាការគ្រប់គ្រង ការជួយរៀបចំថ្នាក់ ឬបន្ទប់រៀនក្នុងកំឡុងពេលបើក ឬបិទបវេសនកាល ការអានសៀវភៅនៅផ្ទះ ការបង្រៀន សិល្បៈ ចម្រៀង តូរ្យតន្ត្រី កំណាព្យ ឬក៏ការចូលរួមជួយបង្រៀនកូន ធ្វើកិច្ចការនៅផ្ទះដែលលោកគ្រូ អ្នកគ្រូដាក់ឱ្យធ្វើ។

ការចូលរួមរបស់មាតាបិតា ឬអ្នកអាណាព្យាបាល ត្រូវបានគេបែងចែកជាពីរចំណុចសំខាន់ៗគឺ៖

- ការចូលរួមរបស់មាតាបិតា ឬអ្នកអាណាព្យាបាល នៅសាលារៀន។
- ការចូលរួមរបស់មាតាបិតា ឬអ្នកអាណាព្យាបាល ក្នុងការអប់រំរបស់កុមារតាមផ្ទះ ។

នៅក្នុងយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលប្រទេសអង់គ្លេសសម្រាប់ការចូលរួមរបស់ឪពុកម្ដាយ ត្រូវបានបង្កើតឡើងតាំងពីឆ្នាំ១៩៩៧ មកម្ល៉េះដែលផ្ដោតលើកត្តាសំខាន់ៗចំនួន៣គឺ :

១. ការផ្តល់ព័ត៌មានដល់ឪពុកម្តាយ ២. ការផ្តល់និងទទួលយកនូវមតិយោបល់របស់ឪពុកម្តាយជុំវិញការអភិវឌ្ឍសាលារៀន និងកម្មវិធីសិក្សាក្នុងការលើកកម្ពស់ការអប់រំ ៣. លើកទឹកចិត្តដល់ឪពុកម្តាយ ឬអ្នកអាណាព្យាបាលឱ្យមានការចូលរួម (Sovannara, 2011) ។

ចំណុចនេះអាចសន្និដ្ឋានបានថា ការចូលរួមរបស់មាតាបិតាសិស្សក្នុងការពិនិត្យតាមដានសាលារៀន និងថ្នាក់រៀនមានសារៈសំខាន់ណាស់ដើម្បីបំពេញចន្លោះខ្វះខាតនៃការពិនិត្យតាមដានរបស់នាយកសាលារៀននិងគ្រូបង្រៀន។ មានខ្លឹមសារ៣ ដែលទាក់ទងនឹងការពិនិត្យតាមដានដោយមាតាបិតាសិស្សដូចខាងក្រោម៖

១) ខ្លឹមសារសម្រាប់អប់រំមាតាបិតានិងសិស្ស ២) ការបំប៉នមាតាបិតា និងសិស្ស ៣) ការអនុវត្តការពិនិត្យតាមដាន។ សកម្មភាពគ្រោងអនុវត្តដែលបានឯកភាពគឺគ្រាន់តែបានដឹងរវាងមាតាបិតានិងសិស្ស និងគណៈកម្មការគ្រប់គ្រងសាលារៀនបានហើយ មិនចាំបាច់ឱ្យគ្រូបង្រៀនដឹងពីឈ្មោះសិស្ស ឬមាតាបិតាទេ។ គណៈកម្មការគ្រប់គ្រងសាលារៀនជូនព័ត៌មានគ្រូបង្រៀនទាំងអស់នៅដើមឆ្នាំសិក្សាថា មានសកម្មភាពពិនិត្យតាមដានដែលធ្វើដោយសហគមន៍នេះ។ សិស្សនិងមាតាបិតាអាចពិភាក្សាគ្នា ថាតើអ្នកណាធ្វើកិច្ចការនៅអាទិត្យនេះ ឬអាទិត្យក្រោយ ឬមួយ នៅខែនេះ ឬនៅខែក្រោយ។ មិនមានការចាំបាច់សរសេរផែនការនេះនៅក្នុងក្រដាសទេ ដោយសារការសរសេរនៅលើក្រដាសមិនជាតម្រូវការចាំបាច់ទេ និងកិច្ចការនេះមិនចាំបាច់ប្រកាសផ្សព្វផ្សាយជាសាធារណៈទេ (ក្រសួងអប់រំ យុវជន និងកីឡា ២០១៨)។

## ២.៤ ឥទ្ធិពលនៃការចូលរួមរបស់មាតាបិតាលើសមិទ្ធផលការសិក្សា

ឥទ្ធិពលនៃការចូលរួមរបស់មាតាបិតាលើសមិទ្ធផលសិក្សារបស់សិស្សត្រូវបានទទួលស្គាល់ដោយគ្រូបង្រៀន អ្នកគ្រប់គ្រង និងអ្នកបង្កើតគោលនយោបាយ ដែលចាត់ទុកការចូលរួមរបស់មាតាបិតាជាផ្នែកសំខាន់មួយនៃកំណែទម្រង់ និងគំនិតផ្តួចផ្តើមអប់រំថ្មី។ លទ្ធផលបានបង្ហាញថាទំនាក់ទំនងរវាងការចូលរួមរបស់មាតាបិតានិងសមិទ្ធផលសិក្សាគឺមានភាពវិជ្ជមាន ដោយមិនគិតពីនិយមន័យនៃការចូលរួមរបស់មាតាបិតាឬរង្វាស់នៃសមិទ្ធផលនោះទេ។ លើសពីនេះ ការរកឃើញបានបង្ហាញថា ទំនាក់ទំនងនេះគឺខ្លាំងបំផុត ប្រសិនបើការចូលរួមរបស់មាតាបិតាត្រូវបានកំណត់ថាជាការរំពឹងទុករបស់មាតាបិតាសម្រាប់

សមិទ្ធផលសិក្សារបស់កូនៗរបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ ឥទ្ធិពលនៃការចូលរួមរបស់មាតាបិតាលើសមិទ្ធផលសិក្សារបស់សិស្សគឺខ្សោយបំផុត ប្រសិនបើការចូលរួមរបស់មាតាបិតាត្រូវបានកំណត់ថាជាជំនួយកិច្ចការផ្ទះ។ ជាចុងក្រោយ ទំនាក់ទំនងរវាងការចូលរួមរបស់មាតាបិតានិងសមិទ្ធផលសិក្សាត្រូវបានរកឃើញថាមានភាពស៊ីសង្វាក់គ្នានៅទូទាំងកម្រិតថ្នាក់ និងក្រុមជនជាតិផ្សេងគ្នាៗ។ ទោះជាយ៉ាងណាក៏ដោយ ភាពខ្លាំងនៃទំនាក់ទំនងនោះបានប្រែប្រួលអាស្រ័យលើប្រភេទនៃការវាយតម្លៃដែលប្រើដើម្បីវាស់ស្ទង់សមិទ្ធផលរបស់សិស្ស (S.Wilder, 2014)។

## ២.៤.១ ការទំនាក់ទំនងរវាងមាតាបិតា ការចូលរួម និងការលើកទឹកចិត្តសិស្ស

ការចូលរួមរបស់មាតាបិតាមានមូលដ្ឋានស្រាវជ្រាវដ៏ត្រឹមត្រូវដែលបញ្ជាក់ពីអត្ថប្រយោជន៍សក្តានុពលជាច្រើនដែលវាអាចផ្តល់ជូនក្នុងការអប់រំ។ ទោះជាយ៉ាងណាក៏ដោយ ការលើកទឹកចិត្តរបស់សិស្សដែលជាលទ្ធផលនៃការចូលរួមរបស់ឪពុកម្តាយទើបតែត្រូវបានស៊ើបអង្កេតថ្មីៗនេះ។ គោលបំណងនៃអត្ថបទនេះគឺដើម្បីបង្ហាញពីរបៀបនៃការចូលរួមរបស់ឪពុកម្តាយទាក់ទងនឹងការលើកទឹកចិត្តរបស់សិស្ស។ ការសិក្សារបស់សិស្សចាប់ពីថ្នាក់បឋមសិក្សាដល់វិទ្យាល័យបង្ហាញពីទំនាក់ទំនងដ៏មានអត្ថប្រយោជន៍រវាងការចូលរួមរបស់មាតាបិតា និងការបង្កើតការ លើកទឹកចិត្តដូចខាងក្រោម៖ ការចូលរួមរបស់សាលា ការលើកទឹកចិត្តផ្នែកខាងក្នុង ខាងក្រៅ សមត្ថភាពយល់ឃើញ ការគ្រប់គ្រង ការយល់ឃើញ ការគ្រប់គ្រងខ្លួនឯង ការតម្រង់ទិសគោលដៅជំនាញ និងការលើកទឹកចិត្តក្នុងការអាន ពីការសំយោគរបស់មាតាបិតានៅក្នុង អក្សរសិល្ប៍បំរែបំរួល និងការលើកទឹកចិត្ត យើងផ្តល់ជូននូវការពន្យល់ដ៏មានសក្តានុពលសម្រាប់ទំនាក់ទំនងរបស់ពួកគេ។ ការណែនាំ សម្រាប់ផ្នែកនៃការស្រាវជ្រាវបន្តត្រូវបានបង្ហាញផងដែរ។ អ្នកស្រាវជ្រាវបានសន្និដ្ឋានថា ការចូលរួមរបស់ឪពុកម្តាយជាទូទៅ ផ្តល់អត្ថប្រយោជន៍ដល់ការសិក្សារបស់កុមារ និងមនុស្ស វ័យជំទង់ និងជោគជ័យក្នុងការសិក្សា (Hoover-Dempsey and Sandler, 1997)។ ការសិក្សាកម្មវិធីនៅដើមឆ្នាំ កុមារភាព បឋមសិក្សា មធ្យមសិក្សា និងវិទ្យាល័យ បង្ហាញថាការខិតខំប្រឹងប្រែង ធ្វើឱ្យប្រសើរឡើងនូវលទ្ធផលសិស្សកាន់តែមានប្រសិទ្ធភាពនៅពេលដែលគ្រួសារសកម្មពាក់ព័ន្ធ (Henderson and Berla, 1994)។ Greenwood និង Hickman (1991) បានដកស្រង់ការសិក្សាជា

ច្រើនដែលផ្តោតលើថ្នាក់បឋម ដែលបានរកឃើញ ទំនាក់ទំនងរវាងការចូលរួមរបស់មាតាបិតា និងអថេរសិស្សដូចជា សមិទ្ធផលសិក្សា អារម្មណ៍នៃសុខុមាលភាព ការចូលរួម អាកប្បកិរិយារបស់សិស្ស ការធ្វើកិច្ចការផ្ទះ ការធ្វើកិច្ចការក្នុងថ្នាក់ និងសេចក្តីប្រាថ្នានៃការអប់រំ។ ការចូលរួមរបស់មាតាបិតាក៏ទាក់ទងជាវិជ្ជមានទៅនឹងសមិទ្ធផល ការសិក្សារបស់សិស្សវិទ្យាល័យផងដែរ (Paulson, 1994; Steinberg et al., 1992; Trusty, 1996) ពេលវេលាដែល បានចំណាយលើកិច្ចការផ្ទះ (Keith et al., 1986; Trusty, 1996) កាត់បន្ថយកម្រិតនៃការបោះបង់ការសិក្សានៅវិទ្យាល័យ (Rumberger et al , 1990) ។ អថេរដូចជាពេលវេលាចំណាយលើកិច្ចការផ្ទះ ការរក្សាសាលារៀន និងសេចក្តីប្រាថ្នានៃការអប់រំ សុទ្ធតែបង្ហាញពីរបៀប សិស្សជាច្រើនឱ្យតម្លៃលើការអប់រំ និងថាតើពួកគេមានការលើកទឹកចិត្តយ៉ាងណាដើម្បីទទួលបានជោគជ័យក្នុងការ សិក្សា។ ទោះជាយ៉ាងណាក៏ដោយ ការលើកទឹកចិត្តសិស្ស ជាលទ្ធផលរបស់មាតាបិតាក្នុងការចូលរួមទើបតែត្រូវបានស្វែងយល់នាពេលថ្មីៗនេះ។ ដើម្បីបង្ហាញពីប្រភេទជាក់លាក់មួយចំនួននៃការចូលរួមរបស់មាតាបិតាដែលទាក់ទង ដល់ការលើកទឹកចិត្តរបស់សិស្ស។ សេចក្តីសន្និដ្ឋាន ដកស្រង់ចេញពីអត្ថបទដែលបានពិនិត្យ បង្ហាញថាការចូលរួមរបស់ឪពុកម្តាយគឺទាក់ទងទៅនឹងការលើកទឹកចិត្តខាងក្រោមៈ ការចូលរួមរបស់សាលា ការលើកទឹកចិត្តខាងក្នុង ខាងក្រៅ ស្វ័យភាព ការគ្រប់គ្រងខ្លួនឯង ការតម្រង់ទិសគោលដៅដែលមានជំនាញ និងការលើកទឹកចិត្តក្នុងការអាន (P.Willems និង Marie F.Doan 2005)។

### ២.៤.២ ការបង្កើតទំនាក់ទំនងជាប់លាប់រវាងមាតាបិតាសិស្ស និងគ្រូបង្រៀនជាកត្តាល្អជួយកែតម្រូវចំណុចខ្វះខាត និងបណ្តុះគំនិតល្អដល់កូនៗ

តាមការចុះផ្សាយរបស់គេហទំព័រ (Fresh News, 2007) ការផ្សារភ្ជាប់ទំនាក់ទំនង រវាងមាតាបិតាសិស្ស និងគ្រូបង្រៀន គឺជាចំណុចដ៏ល្អមួយ ដែលអាចឱ្យដឹងពីចំណុចល្អ ចំណុចខ្វះខាតរបស់កូនៗអ្នកបាន និងជំរុញធ្វើយ៉ាងណាឱ្យពួកគេទទួលបាននូវចំណេះដឹងកាន់តែប្រសើរ មានក្រមសីលធម៌ និងសុជីវធម៌ល្អ ក្នុងការរស់នៅក្នុងសង្គម នេះបើតាមលោកស្រី ប៊ុន ណារី អគ្គនាយិកាសាលា New gateway International School។ លោកស្រី បានបន្តថា អាស្រ័យដូច្នេះហើយទើបសាលា New gateway International School តែងតែរៀបចំកម្មវិធី ជំនួបរវាងមាតា បិតា អាណាព្យាបាលសិស្ស និងគ្រូបង្រៀន

ដើម្បីផ្សារភ្ជាប់ទំនាក់ទំនងឱ្យកាន់តែប្រសើរឡើង។ លោកស្រី ប៊ុន ណារី បានថ្លែងឲ្យដឹងថា សាលារៀនបានរៀបចំកម្មវិធីជំនួបនេះ ឡើងដើម្បីផ្លាស់ប្តូរយោបល់គ្នាពីការរីកចម្រើន និងចំណុចដែលត្រូវរួមគ្នាយកចិត្តទុកដាក់ កែលម្អលើកង្វះខាតមួយចំនួនរបស់កូនៗធ្វើយ៉ាងណាឱ្យពួកគេទទួលបានចំណេះដឹង សីលធម៌ សុជីវធម៌ ក្នុងការរស់នៅប្រកបដោយភាពថ្លៃថ្នូរ និងពង្រឹងការអប់រំឱ្យមានការអភិវឌ្ឍកម្រិតខ្ពស់ផងដែរ។ សាលាមានកាតព្វកិច្ចមិនត្រឹមតែបង្រៀនសិស្សឱ្យចេះទន្ទេញ សរសេរ និងយល់ដឹងតាមទ្រឹស្តីនៅក្នុងមេរៀន និងសៀវភៅប៉ុណ្ណោះទេ តែបានជួយកែប្រែឥរិយាបថ និងរបៀបរបបដែលមិនល្អ អសីលធម៌គឺជាបន្ទុកចាំបាច់របស់សាលា។ លោកគ្រូ អ្នកគ្រូមានកាតព្វកិច្ចមុនគេក្នុងការណែនាំ អប់រំ និងរិះរកវិធានការផ្សេងៗដើម្បីធ្វើឱ្យប្រសើរឡើងនូវទម្លាប់ល្អ ទម្លាប់ឧស្សាហ៍ព្យាយាម យកចិត្តទុកដាក់ ក្នុងការសិក្សារៀនសូត្រ និងមានសីលធម៌ល្អ។ លោកស្រីអគ្គនាយិកាបានថ្លែងបញ្ជាក់ទៀតថា «ការទទួលជោគជ័យក្នុងការអប់រំបុត្រធីតា មិនអាចពឹងផ្អែកតែលើសាលារៀនទាំងស្រុងនោះទេ គឺត្រូវទាមទារឱ្យមានការសហការយ៉ាងសកម្ម និងយកចិត្តទុកដាក់ខ្ពស់ជាពិសេស តាមដានការសិក្សារបស់កូនៗ ពីសំណាក់មាតាបិតា និងអាណាព្យាបាលសិស្សគ្រប់រូប ដោយមិនអាចខ្វះបាន។ ការចូលរួមរបស់មាតាបិតា អ្នកអាណាព្យាបាលក្នុងការអប់រំជាកត្តាសំខាន់បំផុត និងទទួលបាននូវលទ្ធផលយ៉ាងល្អប្រសើរ ដូចជាសិស្សទទួលបានលទ្ធផលល្អ ក្នុងការសិក្សា អត្រាការប្រឡងជាប់ខ្ពស់ ព្រមទាំងសិស្សទាំងអស់អាចជៀសឆ្ងាយពីគ្រឿងញៀន គ្រឿងស្រវឹង និងសកម្មភាពក្មេងទំនើងជាដើម»។ សូមបញ្ជាក់ថា កម្មវិធីជំនួបរវាងមាតាបិតាអាណាព្យាបាលសិស្ស ជាមួយគ្រូបង្រៀន ទទួលបានលទ្ធផលគួរជាទីមោទនៈ ដោយមានការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់មាតាបិតាសិស្ស ជាមួយសាលាដើម្បីផ្លាស់ប្តូរយោបល់ និងធ្វើយ៉ាងណាឱ្យការសិក្សា របស់កូនៗទទួលបានជោគជ័យខ្ពស់ និងក្លាយជាបុគ្គលល្អ ក្នុងសាលា ក្នុងគ្រួសារ និងក្នុងសង្គមជាតិ (News, 2017)។

### ២.៤.៣ កត្តាទំនាក់ទំនងរវាងសាលារៀន និងគ្រួសារ

គ្រួសារជាកោសិកាធ្វើសកម្មភាពដោយសេចក្តីស្រឡាញ់ និងការគោរព។ ហើយវាគ្របដណ្តប់លើការយល់ដឹង ការស្រឡាញ់ ការលះបង់ការមើលថែទាំកុមារ( Emerllahu, Dali,2001)។ ដូច្នេះតាម

របៀបនេះ ការបង្កើតឱ្យមានបរិយាកាសគ្រួសារ ដែលរស់នៅ សើច លេង និងអភិវឌ្ឍកុមារ។ (Claudia&Eberhard Muhlan,2008)។ ការបដិសេធនូវទិសដៅតែមួយនៃឥទ្ធិពលរបស់ឪពុកម្តាយចំពោះការអភិវឌ្ឍកូនរបស់ពួកគេ ដោយជំនួសវា ដោយអន្តរកម្មខ្លាំងនៃកត្តាបីដូចជាៈ កុមារ ឪពុកម្តាយ និងបរិយាកាសសង្គមកាន់តែទូលំទូលាយ។ អន្តរកម្មនេះត្រូវបានគេមើលឃើញថាជាឥទ្ធិពល និងដំណើរការទៅវិញទៅមកដែលផ្លាស់ប្តូរពីឪពុកម្តាយទៅកូន និងវិធីផ្សេងទៀតនៅជុំវិញ ដែលកត្តាបែបនេះបង្កឱ្យមានកត្តាជាច្រើនដែលតាមមធ្យោបាយមួយ ឬមធ្យោបាយផ្សេងទៀតអាចជះឥទ្ធិពលដល់ការអភិវឌ្ឍ និងការអប់រំរបស់កុមារ។ អារម្មណ៍វិជ្ជមាន និងអវិជ្ជមាន មាតាបិតាប្រកាន់ជំហរយ៉ាងសំខាន់នៅពេលនិយាយអំពីការអភិវឌ្ឍ និងការអប់រំកូនគេទាំងមូល ដោយសារឪពុកម្តាយខ្លួនឯងជាអ្នកយកចិត្តទុកដាក់លើការអភិវឌ្ឍរាងកាយ និងបញ្ញារបស់កុមារ រហូតទាល់តែពួកគេទទួលបានឯករាជ្យ និងត្រៀមខ្លួនប្រឈមមុខនិងបញ្ហាប្រឈមនានា ក្នុងសង្គមដែលពួកគេរស់នៅ។ ដោយហេតុផលទាំងនេះ សាលាគរុកោសល្យ និងអ្នកចិត្តសាស្រ្ត ក៏ដូចជាអ្នកស្រាវជ្រាវផ្សេងទៀត សង្កត់ធ្ងន់ក្នុងន័យអំណះអំណាង តួនាទីរបស់ឪពុកម្តាយក្នុងការអភិវឌ្ឍកូនចៅ ដោយផ្តោតលើការអភិវឌ្ឍបុគ្គលិកលក្ខណៈក្នុងគ្រួសារ។ ជាញឹកញាប់ត្រូវបានគេមើលឃើញពីទស្សនៈនៃកត្តាអន្តរកម្មបី ឬវិមាត្រដូចជាៈ ១)សុភមង្គលរបស់ឪពុកម្តាយ ឬការរីករាយចំពោះសមិទ្ធផលរបស់កូនៗ របស់ពួកគេ។ ២)តម្រូវការនិងភាពតានតឹងដែលដាក់តួនាទីមាតាបិតានៅក្នុងដំណើរការ។ ៣)អារម្មណ៍ទាក់ទងនិងសមត្ថភាពរបស់មាតបិតាចំពោះកូនរបស់ពួកគេ ការអភិវឌ្ឍរួមជាមួយ ការអប់រំ សម្រាប់ជីវិតនៅក្នុងគ្រួសារចាប់ផ្តើមជាមួយនឹងថ្ងៃដំបូងនៃជីវិតរបស់កុមារ។ វាមានជាចម្បងនៃការទទួលបានបទពិសោធន៍ ដែលជាធម្មតាត្រូវបានប៉ះពាល់ដោយការរៀនសូត្រឥតឈប់ឈរ។ (Lakinska,Divna,2006) ក្នុងន័យនេះ ឪពុកម្តាយ ក៏ដូចជាក្រុមគ្រួសារទាំងមូល ដើរតួនាទីជាអ្នកដឹកនាំផ្ទាល់ ក៏ដូចជាអ្នកគាំទ្រក្នុងការអនុវត្តការអប់រំរបស់កូនៗ។ ដោយសារចំណុចនេះ គឺកត្តាស្នូលមួយនៃឥទ្ធិពល វាអាចត្រូវបានគេមើលឃើញថាជាមូលដ្ឋានគ្រឹះដែលមិនមានមន្ទិលថាមានឥទ្ធិពលកាន់តែខ្លាំងលើការអភិវឌ្ឍទាំងមូល និងការបង្កើតបុគ្គលិកលក្ខណៈរបស់មនុស្ស (Terova, 2016)។

### ២.៤.៤ សារៈសំខាន់នៃការចូលរួមរបស់មាតាបិតា

ការចូលរួមរបស់មាតាបិតាដើរតួយ៉ាងសំខាន់ក្នុងការអប់រំរបស់សិស្ស ហើយគុណសម្បត្តិរបស់វាសម្រាប់សិស្សមានច្រើន (Veynes, 2003, 2007)។ ជាឧទាហរណ៍ ការចូលរួមរបស់មាតាបិតាមានឥទ្ធិពលវិជ្ជមានទៅលើភាពជោគជ័យក្នុងការសិក្សា SURFÜRSJ (Fan & Chen, 2001; Jeynes, 2003; Jordan et al., 2001; Gonzalez-piendaet al., 2002; Henderson & Mapp, 2002)។ ជាពិសេសការចូលរួមរបស់មាតាបិតាមានឥទ្ធិពលលើពិន្ទុតេស្តរបស់សិស្សច្រើនជាង **GPA (ពិន្ទុមធ្យម)** (Jeynes, 2003)។ យោងទៅតាម Shaver and Walls (1998) សិស្សដែលមានកម្រិតខ្ពស់នៃ ការចូលរួមរបស់មាតាបិតាគឺមានភាពល្អប្រសើរក្នុងការអាន និងគណិតវិទ្យាជាងសិស្សដែលមានកម្រិតទាបនៃការចូលរួមរបស់ មាតាបិតា។ លើសពីនេះ Gonzalez-peinda et al. (2002) បានកំណត់ថា ការចូលរួមរបស់មាតាបិតាធ្វើឱ្យមានការរួមចំណែកជាវិជ្ជមានដល់សមិទ្ធផលសិក្សារបស់សិស្ស ដោយមិនប៉ះពាល់ដល់គំនិតខ្លួនឯងក្នុងការសិក្សារបស់ពួកគេ ដែលមានសារៈសំខាន់យ៉ាងខ្លាំងក្នុងភាពជោគជ័យក្នុងការសិក្សា។ សូម្បីតែ Hara និង Burke (1998) បានអះអាងថាគន្លឹះក្នុងការធ្វើឱ្យប្រសើរឡើងនូវសមិទ្ធិផលសិក្សារបស់កុមារគឺជម្រុញ ការចូលរួមរបស់មាតាបិតា។ ផ្ទុយទៅវិញ Bobbett et al (1995) បានរកឃើញថាឥទ្ធិពលនៃការចូលរួមរបស់មាតាបិតា មានលើសមិទ្ធផលសិក្សារបស់សិស្សគឺមិនសំខាន់ទេ។ អ្នកស្រាវជ្រាវខ្លះថែមទាំងបានកំណត់ថានៅពេលដែលឪពុកម្តាយចូលរួម ជាមួយកិច្ចការផ្ទះរបស់សិស្ស និងទំនាក់ទំនងជាមួយសាលា វាជះឥទ្ធិពលអវិជ្ជមានដល់ភាពជោគជ័យក្នុងការសិក្សារបស់សិស្ស ដោយការថយចុះពិន្ទុតេស្តរបស់ពួកគេ (Izzo et al., 1999; Shumow& Miller, 2001)។ លើសពីនេះទៀត Cooper et al(2000) បានរកឃើញថា ការចូលរួមដោយផ្ទាល់របស់មាតាបិតា ជាពិសេសប៉ះពាល់អវិជ្ជមានដល់សមិទ្ធផលសិក្សា របស់សិស្ស។ នៅពេលដែលឪពុកម្តាយចូលរួម ពួកគេបានរួមចំណែកដល់ការអភិវឌ្ឍផ្លូវចិត្ត និងអាកប្បកិរិយារបស់កូនពួកគេ សុខុមាលភាព ជំនាញសង្គម (Javarov,2015)

## ២.៥ តួនាទី និងសារៈសំខាន់នៃការអប់រំ

ការអប់រំពិតជាមានសារៈសំខាន់ខ្លាំងណាស់ចំពោះមនុស្សគ្រប់រូប ទោះបីជាការអប់រំប្រព្រឹត្តទៅក្នុងលក្ខខណ្ឌណាក៏ដោយ ដូចជាការអប់រំក្នុងប្រព័ន្ធ សំដៅដល់ដំណើរការសិក្សាដែលមានលក្ខណៈជាប្រព័ន្ធ និងហ្មត់ចត់ មានរចនាសម្ព័ន្ធរៀបរយ និងតាមលំដាប់ថ្នាក់។ ការអប់រំក្នុងប្រព័ន្ធផ្តល់ឱ្យដោយគ្រឹះស្ថានសិក្សាដែលមានអជ្ញាប័ណ្ណអប់រំត្រឹមត្រូវ ឬដែលមានការទទួលខុសស្គាល់គុណភាពអប់រំស្របតាមលក្ខខណ្ឌផ្នែកច្បាប់និងនីតិវិធីដែលមានចែងក្នុងច្បាប់។ ការអប់រំក្រៅប្រព័ន្ធ សំដៅដល់សកម្មភាពអប់រំដែលមានការរៀបចំមានលក្ខណៈជាប្រព័ន្ធដែលធ្វើឡើងនៅក្រៅក្របខ័ណ្ឌនៃកម្មវិធីអប់រំក្នុងប្រព័ន្ធ ដើម្បីផ្តល់ការសិក្សាមួយចំនួនដែលបានជ្រើសរើស។ ការអប់រំក្រៅប្រព័ន្ធគ្របដណ្តប់លើកម្មវិធីអប់រំជាច្រើន ដូចជា អក្ខរកម្ម បំណិនជីវិត បំណិនការងារ ការអប់រំមូលដ្ឋាន សម្រាប់អ្នកសិក្សាដែលមិនចូលសិក្សានៅគ្រឹះស្ថានសិក្សាក្នុងប្រព័ន្ធ ដែលមានលក្ខណៈជាការសិក្សាបន្ត និងការសិក្សាកម្រិតសមមូលសម្រាប់ការបញ្ចូលទៅក្នុងកម្មវិធីអប់រំក្នុងប្រព័ន្ធ ឬជាការអប់រំអស់មួយជីវិត។ អ្នកសិក្សាក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធមានសិទ្ធិសុំ និងទទួលបាននូវការធ្វើតេស្តវាយតម្លៃកម្រិតសមមូលចំពោះការអប់រំរបស់ខ្លួនពីអាជ្ញាធរអប់រំមានសមត្ថកិច្ចដូចមានចែងក្នុងច្បាប់នេះ។ ការអប់រំមិនផ្លូវការ សំដៅដល់ដំណើរការស្វ័យសិក្សា ឬការសិក្សាដោយខ្លួនឯង និងជាដំណើរការសិក្សាអស់មួយជីវិត តាមការចាប់អារម្មណ៍ សក្តានុពលការត្រៀមខ្លួនជាស្រេច និងឱកាសដែលមានហើយដែលអ្នកសិក្សាទទួលនិងបង្កើនផ្ទុំចំណេះដឹង ជំនាញឥរិយាបថ និងគំនិតបានមកពីបទពិសោធន៍ប្រចាំថ្ងៃពីការងារ ការសំដែងនិងពីជីវិតផ្ទាល់ និងជាការសិក្សាតាមរយៈមនុស្ស សង្គម មជ្ឈដ្ឋានជុំវិញប្រព័ន្ធសារព័ត៌មាន ព្រមទាំងប្រភពចំណេះដឹង ឬប្រភពព័ត៌មានផ្សេងទៀតនៅពេលណា និងនៅទីកន្លែងណាផ្សេងទៀតក៏ដោយក្រៅពីកម្មវិធីអបរំក្នុងប្រព័ន្ធ និងកម្មវិធីអបរំក្រៅប្រព័ន្ធ។ អ្នកសិក្សាមានសិទ្ធិសុំនិងទទួលការធ្វើតេស្តវាយតម្លៃកម្រិតសមមូល ចំពោះការអប់រំរបស់ខ្លួនពីអាជ្ញាធរអប់រំមានសមត្ថកិច្ចដូចមានចែងក្នុងច្បាប់នេះ។ ការអប់រំសម្រាប់ទាំងអស់គ្នា សំដៅដល់ចលនារបស់ពិភពលោក ដើម្បីឱ្យកុមារ យុវជន និងជនពេញវ័យគ្រប់រូប មានសិទ្ធិទទួលផលប្រយោជន៍ពីការអប់រំបានយ៉ាងពេញលេញ និងប្រកបដោយគុណភាព ។ ការអប់រំមានគុណភាព សំដៅ

ដល់ការអប់រំមួយ ដែលបំពេញបានសេចក្តីត្រូវការនៃការសិក្សាជាមូលដ្ឋាន និងបន្តអស់មួយជីវិតរបស់អ្នកសិក្សា (រាជរដ្ឋាភិបាលកម្ពុជា ២០០៧)។

## ២.៦ លក្ខណៈទាំង១០ របស់ឪពុកម្តាយ ដែលធ្វើឲ្យកូនទទួលបានជោគជ័យ

លក្ខណៈទាំង១០ របស់ឪពុកម្តាយ ដែលធ្វើឲ្យកូនទទួលបានជោគជ័យ រាល់ម្តាយឪពុកគ្រប់រូបសុទ្ធតែចង់ឲ្យកូនរបស់ពួកគេ ជៀសឲ្យឆ្ងាយពីបញ្ហា និងយកចិត្តទុកដាក់លើការរៀនសូត្រឲ្យបានពូកែដើម្បីអនាគតល្អពេលធំពេញវ័យ។ យ៉ាងណាមិញ មិនមានរូបមន្តណាមួយដែលកំណត់ សម្រាប់ឲ្យកុមារទទួលបានជោគជ័យនោះទេ តែអ្នកស្រាវជ្រាវផ្នែកចិត្តសាស្ត្រ បានចង្អុលបង្ហាញពីកត្តាដែលទាក់ទងនឹងភាពជោគជ័យមួយចំនួន របស់ពួកគេផងដែរ។ វាមិនចម្លែកទេ ព្រោះភាគច្រើនគឺសុទ្ធតែមកពីកត្តា មាតាបិតា។ ខាងក្រោមនេះជាអ្វី ដែលឪពុកម្តាយរបស់ក្មេងទទួលបានជោគជ័យ៖

**១. ពួកគេឲ្យកូនចេះធ្វើការងារ៖** កុមារដែលរស់នៅ ចេះធ្វើការងារបន្តិចបន្តួច (ឧ: ជួយបោសជូត លាងចាន ជាដើម-ល-) នឹងអាចក្លាយជា បុគ្គលចេះសហការយ៉ាងល្អ ជាមួយអ្នករួមការងាររបស់ពួកគេ នាពេលអនាគត ព្រោះពួកគេយល់អារម្មណ៍ការធ្វើផ្ទាល់ ថាវាពិបាកជាងការដែលយើងគ្រាន់តែមើលឃើញ។

**២. ពួកគេបង្រៀនកូនពីទំនាក់ទំនងសង្គម៖** អ្នកស្រាវជ្រាវពីសាកលវិទ្យាល័យរដ្ឋ Pennsylvania និងសាកលវិទ្យាល័យ រដ្ឋ Duke សហរដ្ឋអាមេរិក បានសិក្សាលើកុមារជាង៧០០នាក់ មកពីទូទាំងសហរដ្ឋ អាមេរិកតាំងពីសាលាមត្តេយ្យ ដល់អាយុ ២៥ឆ្នាំ និងបានរកឃើញ ការជាប់ទាក់ទងគ្នារវាងទំនាក់ទំនងសង្គមរបស់ពួកគេ ជាក្មេងមតេយ្យ និងភាពជោគជ័យ របស់ពួកគេក្រោយជាមនុស្សពេញវ័យ។ ការសិក្សាអស់រយៈពេល ២០ឆ្នាំនេះ បានបង្ហាញថាកុមារដែលមានសមត្ថភាពរាប់អាន ជាមួយមិត្តភក្តិរបស់ពួកគេ ដោយគ្មានការរើសអើង ចេះជួយគ្នា យល់ពីអារម្មណ៍គ្នា និងដោះស្រាយបញ្ហាបានដោយខ្លួនឯង ទំនងជាអាចរៀនដល់កម្រិតថ្នាក់មហាវិទ្យាល័យ និងមានសមត្ថភាពធ្វើការពេញម៉ោង នៅអាយុ ២៥ឆ្នាំ ជាងអ្នកដែលមិនសូវមានទំនាក់ទំនងសង្គម។ ការសិក្សានេះបានបង្ហាញថា ការជួយកូនឲ្យអភិវឌ្ឍន៍ នូវជំនាញ

ទំនាក់ទំនងសង្គម ជាផ្នែកមួយដែលសំខាន់បំផុតដែលយើងអាចធ្វើទៅបាន ដើម្បីរៀបចំអនាគតកូនៗ អោយបានល្អ។

**៣. ពួកគេមានការរំពឹងទុកខ្ពស់លើកូនរបស់ខ្លួន៖** ទិន្នន័យបានពីការស្ទង់មតិថ្នាក់ជាតិ រកឃើញថា ការសង្ឃឹម ឬរំពឹងទុករបស់ឪពុកម្តាយ មានឥទ្ធិពលយ៉ាងធំធេង ទៅលើភាពជោគជ័យរបស់កូនៗ។ នៅពេលដែលឪពុកម្តាយរំពឹងថា អនាគតរបស់កូនពួកគេ នឹងត្រូវចូលសិក្សាមហាវិទ្យាល័យ, ពួកគេនឹងគ្រប់គ្រង ក៏ដូចជាតម្រង់ទិសកូន ឲ្យឆ្ពោះទៅរកគោលដៅនោះ ដោយមិនគិតពីប្រាក់ចំណូល និងទ្រព្យសម្បត្តិផ្សេងទៀតឡើយ។ ហេតុនេះទើបកូនៗ រស់នៅខិតខំប្រឹងប្រែង ដើម្បីសំរេចសេចក្តីរំពឹងទុក របស់មាតាបិតា។

**៤. ពួកគេមានទំនាក់ទំនងល្អជាមួយគ្នា៖** កុមារនៅក្នុងគ្រួសារ ប្រភេទដែលមានជម្លោះញឹកញាប់ ឬទាំងការលែងលះគ្នា មានបញ្ហាការវិវត្តខ្លួន អាក្រក់ជាងកុមារដែលមានឪពុកម្តាយ រស់នៅចុះសម្រុងគ្នា។ ការប៉ះទង្គិចគ្នារវាងឪពុកម្តាយ មុនពេលការលែងលះ បានប៉ះពាល់ដល់កុមារ នូវគំនិតនិងឥរិយាបថអវិជ្ជមានខណៈពេលដែលជម្លោះ ក្រោយការលែងលះគ្នាមានឥទ្ធិពលយ៉ាងខ្លាំង លើការប្រែប្រួល និងការលូតលាស់របស់កុមារ។

**៥. ពួកគេមានការអប់រំខ្ពស់៖** អ្នកជំនាញខាងចិត្តវិទូ បានរកឃើញថាម្តាយ ដែលបានបញ្ចប់វិទ្យាល័យ ឬមហាវិទ្យាល័យភាគច្រើន សុទ្ធតែធ្វើការចិញ្ចឹមបីបាច់កូន ឲ្យបានរៀនខ្ពង់ខ្ពស់ដូចគ្នាដែរ។ កុមារដែលកើតចេញពី ម្តាយវ័យជំទង់ (អាយុ ១៨ ឆ្នាំ ឬក្មេងជាងនេះ) ហាក់ដូចជាមិនសូវបានរៀន បញ្ចប់វិទ្យាល័យ ឬមហាវិទ្យាល័យដូចក្មេងដទៃទេ។

**៦. ពួកគេបង្រៀន គណិតវិទ្យាទៅកូនតាំងពីតូច៖** ការវិភាគកុមារ៣៥,០០០នាក់ ចូលសាលានៅទូទាំងសហរដ្ឋអាមេរិក កាណាដា និងប្រទេសអង់គ្លេស បានរកឃើញថាការបង្ហាត់ជំនាញគណិតវិទ្យា ជាគ្រឹះអោយបានកាន់តែឆាប់សំរាប់កុមារ អាចក្លាយទៅជាគុណប្រយោជន៍ដ៏ធំ។ ការចាប់ផ្តើមជាមួយនឹងចំណេះដឹង

នៃលេខ ស្គាល់លំដាប់លេខ និងគ្រឹះគណិតវិទ្យាផ្សេងទៀត មិនត្រឹមតែធ្វើឲ្យកុមារពូកែជំនាញគណិតវិទ្យា នាពេលអនាគតទេ កុមារនឹងមានភាពប៉ិនប្រសប់ក្នុងការអាននាពេលអនាគតទៀតផង។

**៧. ពួកគេធ្វើការអភិវឌ្ឍ ទំនាក់ទំនងជាមួយកូនៗ៖** កុមារដែលបានទទួល "ការថែទាំល្អ" ក្នុងរយៈពេលបីឆ្នាំដំបូង មិនត្រឹមតែធ្វើបានល្អ ក្នុងការសិក្សាក្នុងវ័យកុមារភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានទំនាក់ទំនងល្អ និងសម្រេចបានការសិក្សាកម្រិតខ្ពស់ ក្នុងខ្ទង់វ័យ ៣០ឆ្នាំរបស់ពួកគេ។ ឪពុកម្តាយ ដែលជាអ្នកមើលថែដ៏ល្អ ឆ្លើយតបទៅនឹងសញ្ញារបស់កូន "បានត្រឹមត្រូវនិងឆាប់រហ័ស" និង "ផ្តល់មូលដ្ឋានសុវត្ថិភាព" លើចិត្តគំនិតកុមារ ដើម្បីរុករកអ្វីថ្មីៗផងដែរ។

**៨. ពួកគេមិនសូវមានភាពតានតឹងក្នុងអារម្មណ៍៖** ស្ត្រេសរបស់ម្តាយឪពុក ជាពិសេសនៅពេលដែលពួកគេមានសម្ពាធធ្ងន់ធ្ងរ ដោយសារតែការងារ បន្ទាប់មកព្យាយាមរកពេលវេលា មកលេងជាមួយនឹងកូន ដែលនេះនឹងផ្តល់ផលប៉ះពាល់ ដល់កូនរបស់ពួកគេទៅវិញ។ នេះជាការរីករាលដាលផ្លូវចិត្ត ឬបាតុភូតផ្លូវចិត្តដែលមនុស្ស "ចាប់យកអារម្មណ៍" ពីមួយទៅមួយ ដូចជាឆ្លងជំងឺផ្តាសាយយ៉ាងដូច្នេះដែរ។ ការស្រាវជ្រាវបានបង្ហាញថា ប្រសិនបើមិត្តភក្តិរបស់អ្នក សប្បាយចិត្ត ភាពរីករាយនោះនឹងឆ្លងមកកាន់អ្នក។ តែប្រសិនបើពួកគេកើតទុក្ខ ភាពអាប់អួរនោះក៏នឹងផ្ទេរមកអ្នកផងដែរ។ ដូច្នេះប្រសិនបើឪពុកម្តាយ មានអារម្មណ៍អស់កម្លាំង ឬមានបញ្ហាខកចិត្ត លើអ្វីមួយនោះ អារម្មណ៍ទាំងនេះអាចនឹងផ្ទេរទៅកូនផងដែរ។

***៩. ការងាររបស់ម្តាយ៖*** យោងតាមការស្រាវជ្រាវ គេបានបង្ហាញថា កុមារដែលលូតលាស់ឡើង ជាមួយម្តាយដែលធ្វើការនៅខាងក្រៅផ្ទះ ទទួលបានផលប្រយោជន៍គួរឲ្យកត់សំគាល់។ ការសិក្សានេះបានរកឃើញថា កូនស្រីរបស់ម្តាយដែលធ្វើការងារខាងក្រៅ បានទៅសាលារៀនកម្រិតខ្ពស់ ភាគច្រើនមានការងារតួនាទីជាអ្នកគ្រប់គ្រង និងរកប្រាក់កម្រៃបានច្រើន។ ក្នុងនោះ បើធៀបទៅនឹងក្មេងស្រីដទៃ ដែលមានស្ត្រីជាម្តាយជាមេផ្ទះមាន ២៣% ប៉ុណ្ណោះ។ "គំរូ" នេះហើយគឺជាសញ្ញាបង្ហាញ ដល់កូនរបស់អ្នកនូវរបៀបដែលអ្នកប្រកាន់ឥរិយាបទ នូវអ្វីដែលអ្នកធ្វើសកម្មភាពដែលអ្នកចូលរួម និងអ្វីដែលអ្នកមានជំនឿ។

**១០. ពួកគេមានស្ថានភាពសង្គមសេដ្ឋកិច្ចខ្ពស់៖** គម្លាតរវាងគ្រួសារដែលមានប្រាក់ចំណូលទាប និងខ្ពស់ គឺមានទំហំធំប្រហែលពី ៣០% ទៅ ៤០%។ គេបានកត់សម្គាល់ឃើញថា ឪពុកម្ដាយដែលមានប្រាក់ចំណូលខ្ពស់ ភាគច្រើនមានកូនគ្រប់ពិន្ទុប្រឡងចូលសាកលវិទ្យាល័យ (ខ្មែរអ្នកអប់រំ ២០២២)។

## ២.៧ តាមដានការសិក្សារៀនសូត្ររបស់សិស្ស

ការអប់រំមិនមែនជាបន្ទុកសាលារៀនតែម្នាក់ឯងទេ ប៉ុន្តែជាការចូលរួមចំណែករបស់សហគមន៍ និងមាតាបិតាផងដែរ។ ដូច្នេះមាតាបិតាត្រូវ៖

- ជួយអប់រំកូនបន្ថែម និងជុំរិញឲ្យខិតខំរៀនសូត្រ និងបង្កលក្ខណៈទាំងសម្ភារ និងពេលវេលាពិសេសកូនស្រី។
- ទំនាក់ទំនងជាមួយលោកគ្រូ/អ្នកគ្រូឲ្យបានញឹកញាប់ដោយផ្ទាល់មាត់ ឬតាមលិខិត និងលោកនាយកសាលារៀន ដើម្បីកាត់បន្ថយអត្រាត្រួតថ្នាក់ និងករណីសិស្សបោះបង់ការសិក្សា។
- ចូលរួមប្រជុំដើម្បីទទួលព័ត៌មានពីការសិក្សារបស់កូនចៅ។
- ជួយផ្តល់មតិយោបល់ ដែលមានប្រយោជន៍ដល់សាលារៀន ជាពិសេសជាមួយគណៈគ្រប់គ្រងសាលារៀន។
- ជួយផ្តល់បទពិសោធដល់ការបង្រៀនសិស្ស
- ជួយឧបត្ថម្ភដល់កុមារលំបាក
- ជួយអប់រំផ្លូវចិត្ត អាកប្បកិរិយា និងការអប់រំវិជ្ជាជីវៈដល់កុមារ។
- ជួយផ្តល់ជំនាញបច្ចេកទេស ក្នុងការអប់រំវិជ្ជាជីវៈដល់កុមារ

## ២.៨ គន្លឹះអប់រំកូនៗរបស់ជនជាតិជប៉ុន ដែលឪពុកម្តាយគ្រប់រូបគួរស្វែងយល់

យោងតាមអត្ថបទដែលបានដកស្រង់ពី (AMS, 2021) ជប៉ុនបានក្លាយជាប្រទេសជាប់ចំណាត់ថ្នាក់លេខ១ លើពិភពលោកស្តីអំពីការអប់រំកូនបានល្អ កុមារមានសុខភាពល្អនិងមានសុជីវធម៌ល្អ។ ជនជាតិជប៉ុនបានអប់រំកូនពីបំណិនជីវិត ការសិក្សា សុជីវធម៌ និងផ្តល់ឯករាជដល់កូនតាំងពីកុមារភាព។ ខាងក្រោមនេះជាចំណុចដែលឪពុកម្តាយបង្រៀនឬអប់រំកូនរបស់ប្រជាជនជប៉ុន។

**១. ភាពស្និទ្ធស្នាលរវាងម្តាយឪពុកនិងកូនៗ៖** ពួកគេតែងតែយកចិត្តទុកដាក់ និងផ្តល់ដំបូន្មានល្អៗដល់កូន។ ឪពុកម្តាយមិនប្រើអំពើហិង្សានៅពេលកូនធ្វើខុស ឬមានកំហុសដោយចេតនាណាមួយ។ ពួកគេតែងពន្យល់ពីហេតុផលនិងប្រាប់ពីលទ្ធផលដែលកូនបានធ្វើ។ មុនកូនមានអាយុប្រាំឆ្នាំ ឪពុកម្តាយតែងផ្តល់ឱកាសឱ្យកូនធ្វើអ្វីដែលពួកគេចង់ធ្វើ។ ទន្ទឹមគ្នានេះ ដើម្បីបង្ហាញពីការយកចិត្តទុកដាក់ ភាពកក់ក្តៅដល់កូន ឪពុកម្តាយតែងគេងឱបកូនៗជារៀងរាល់យប់ដោយក្តីស្រឡាញ់។

**២. កុមារត្រូវបានបញ្ជូនទៅសាលារៀននៅអាយុប្រាំមួយឆ្នាំ៖** ឪពុកម្តាយត្រូវបញ្ជូនកូនទៅសាលារៀនចាប់ពីអាយុប្រាំមួយឆ្នាំនៅសាលារដ្ឋ។ ប្រព័ន្ធអប់រំជប៉ុនបង្រៀនឱ្យកុមារធ្វើការដោយភាពស្មើគ្នា ពួកគេបង្រៀនពីរបៀបរស់នៅប្រកបដោយសុជីវធម៌ សីលធម៌ អាកប្បកិរិយា និងវិន័យ ដើម្បីឱ្យកុមារចេះលត់ដំខ្លួនតាំងពីតូច។ នៅក្នុងសាលារៀនកុមារធ្វើការងារសម្អាត ឬអនាម័យដោយខ្លួនឯងរៀងៗខ្លួន ទាំងនៅក្នុងបន្ទប់រៀននិងក្នុងបន្ទប់ទឹក ដើម្បីជាការឆ្លុះបញ្ចាំងពីទំនួលខុសត្រូវរបស់កុមារ។

**៣. ឪពុកម្តាយយកចិត្តទុកដាក់ខ្លាំងលើអារម្មណ៍កូនៗ៖** ដើម្បីរស់នៅប្រកបដោយសមូហភាពវាជារឿងសំខាន់សម្រាប់កុមារដែលឪពុកម្តាយត្រូវបង្រៀនឱ្យចេះគោរពនិងចេះយោគយល់ពីអារម្មណ៍អ្នកដទៃ សូម្បីតែវត្ថុមានជីវិត។ ឪពុកម្តាយជនជាតិជប៉ុនលើកទឹកចិត្តនិងមិនជម្រុះឱ្យកូនៗរៀនខ្មាសឡើយ។

**៤.ឪពុកម្តាយធ្វើជាគម្រូល្អដល់កូន៖** ឪពុកម្តាយតែងតែគោរពនិងផ្តល់តម្លៃដល់កូនជានិច្ច។ គ្រប់សកម្មភាពទាំងអស់ ឪពុកម្តាយបង្រៀនកូនដោយវិធីសាស្ត្រងាយៗ ប៉ុន្តែមានប្រសិទ្ធភាពខ្ពស់។ ឧទាហរណ៍៖ បង្រៀន

ឱ្យកូនចេះរៀបចំវត្ថុលេងឱ្យមានរបៀប និងបង្រៀនកូនឱ្យប្រើភាសាទន់ភ្លន់ជានិច្ច។ ការធ្វើបែបនេះការបង្ហាញពីគំរូភាព អត់ធ្មត់ ព្យាយាម និងកម្លាំងចិត្ត។

**៥. វិធីចម្អិនអាហារប្លែកៗឱ្យកូនៗ៖** ឪពុកម្តាយមិនបង្ខំឱ្យកូនៗពួកគេញុំាអាហារច្រើនទេ តែពួកគេទម្លាប់ចម្អិនអាហារនិងតុបតែងចេញជារូបភាពផ្សេងៗដែលទាក់ចិត្តកូនឱ្យចង់ញុំាអាហារ។ រឿងដែលសំខាន់មួយទៀត គឺពួកគេបង្រៀនឱ្យកូនៗទម្លាប់ញុំាត្រីច្រើនជាងសាច់ផ្សេងៗ ពីព្រោះត្រីមានប្រូតេអ៊ីននិងធ្វើឱ្យពួកគេមានសុខភាពល្អ។

**៦. បង្រៀនកូនៗឱ្យចេះចម្អិនអាហារដោយខ្លួនឯង៖** កុមារទាំងអស់អាចរៀនពីវិធីចម្អិនអាហារដោយខ្លួនឯងនិងមានភាពច្នៃប្រឌិតខ្ពស់និងស្គាល់ពីតម្លៃនៃអាហារ។ ជាក់ស្តែងនៅសាលារៀនកុមារក៏តម្រូវឱ្យមានការរៀនចម្អិនម្ហូប ដើម្បីឱ្យពួកគេចេះពីវិធីរក្សាអនាម័យក្នុងការចម្អិនម្ហូបផង។ គួរបញ្ជាក់ផងដែរថាប្រទេសជប៉ុនបានឈរនៅលំដាប់កំពូលដែលប្រជាជនមានសុខភាពល្អជាងគេនៅលើពិភពលោក រួមទាំងកុមារផងដែរ (AMS, 2021) ។

## ២.៩ ការស្រាវជ្រាវផ្តោតសំខាន់ទៅលើទស្សនៈរបស់មាតាបិតា និងការសិក្សារបស់កូនៗ

ការស្រាវជ្រាវនេះមានគោលបំណងស្វែងយល់ពីទស្សនៈរបស់មាតាបិតាសិស្ស ចំពោះតួនាទីក្នុងការរួមចំណែកជួយការអប់រំ និងការសិក្សារបស់កូនៗ ។ ការស្រាវជ្រាវនេះក៏ចង់ដឹងថា ហេតុអ្វីបានជាតួនាទីមាតាបិតា ចាំបាច់ត្រូវរួមចំណែកក្នុងការជួយការអប់រំ និងការសិក្សារបស់កូនៗ បានត្រឹមកម្រិតដែលពួកគាត់បានចូលរួមកន្លងមក។ ការប្រមូលទិន្នន័យ សម្រាប់ការសិក្សាស្រាវជ្រាវនេះ គឺធ្វើឡើងតាមរយៈទិន្នន័យដែលមានស្រាប់របស់អ្នកសិក្សាស្រាវជ្រាវពីមុនៗមក នៅក្នុងប្រទេសផ្សេងៗ និងប្រទេស កម្ពុជា។ អ្នកសិក្សាស្រាវជ្រាវក៏បាន រៀបចំឧបករណ៍និងឯកសារចាំបាច់មួយចំនួនសម្រាប់ចុះទៅដល់កន្លែងដើម្បីប្រមូលទិន្នន័យផងដែរ។ សម្រាប់ការស្រាវជ្រាវបន្ត គឺឆ្លុះបញ្ចាំងពីស្ថានភាពបម្រែបម្រួលពី ទស្សនៈរបស់មាតាបិតាសិស្ស ចំពោះតួនាទីក្នុងការរួមចំណែកជួយការអប់រំ និងការសិក្សារបស់កូនៗ នៅក្នុងប្រទេសកម្ពុជាពីមួយឆ្នាំទៅមួយឆ្នាំ ជាពិសេសនៅក្នុងរាជធានីភ្នំពេញ។ បើតាមលទ្ធផលនៃការស្រាវជ្រាវ

តាមរយៈទិន្នន័យដែលមានស្រាប់ទាំងនោះ ទម្រង់នៃការរួមចំណែករបស់មាតាបិតា ដើម្បីធ្វើឱ្យជីវិតសិក្សារបស់កូនប្រកបទៅដោយអំណោយផលល្អមានចំណុចមួយចំនួន ដែលបានរកឃើញ ដែលក្នុងនោះមានដូចជា ការចិញ្ចឹមបីបាច់ថែរក្សាកូន ការប្រាស្រ័យទាក់ទងជាមួយសាលារៀន ការធ្វើជាអ្នកស្ម័គ្រចិត្តក្នុងកិច្ចការសាលារៀន ជាជំនួយការសិក្សារបស់កូនៗនៅផ្ទះ ការធ្វើការសម្រេចចិត្ត ការធ្វើជាអ្នកជំរុញលើកទឹកចិត្តឱ្យមានការរំពឹងខ្ពស់ និងការចំណាយផ្សេងៗ។ ប៉ុន្តែទម្រង់ចំនួន២ ដែលអ្នកសិក្សា ស្រាវជ្រាវយល់ថាជាទម្រង់ដែលមានការលើកឡើងរបស់អ្នកសិក្សាស្រាវជ្រាវពីមុនៗមកច្រើនជាងគេ ហើយក៏អាចកើតមានឡើងច្រើនជាងគេនៅក្នុងប្រទេសកម្ពុជាផងដែរ។ ទម្រង់ទាំងពីរនេះ គឺការប្រាស្រ័យទាក់ទងជាមួយសាលារៀន និងការជួយការសិក្សារបស់កូនៗនៅផ្ទះ។ មាតាបិតា អាចទាក់ទងជាមួយលោកគ្រូ អ្នកគ្រូផ្ទាល់ ក្នុងការទទួលព័ត៌មានលំអិតអំពីកូនៗ ជាពិសេសទាក់ទងទៅនឹងភាពជឿនលឿន វត្តមានក្នុងការសិក្សា តម្រូវការរបស់សាលារៀន និងការចូលរួមសកម្មភាពផ្សេងៗរបស់សាលារៀន។ ការជួយកូនៗក្នុងការសិក្សានៅផ្ទះរួមមានការតាមដានការសិក្សា ការពិនិត្យមើលកិច្ចការសាលារបស់កូន ការស្តាប់ការអានរបស់កូន ការទិញសម្ភារសិក្សាសម្រាប់កូន ការរៀបចំចាត់ចែងពេលវេលា និងគ្រឿងបរិក្ខារសម្រាប់កូនរៀន ការកំណត់ពេលវេលាសម្រាប់កូនមើលទូរទស្សន៍ ស្តាប់តួរ្យតន្ត្រី និងការលេងល្បែងដែលទាក់ទងនឹងការអប់រំជាមួយកូនៗផងដែរ (Sovannara, 2011) ។

## ២.១០ អត្ថប្រយោជន៍នៃការចូលរួមរបស់មាតាបិតា

**ក. អត្ថប្រយោជន៍សម្រាប់សិស្ស** (Henderson, AT & Berla, N, 1994)។ 1.ពិន្ទុតេស្តខ្ពស់ 2.សមិទ្ធផលខ្ពស់ក្នុងការអាន 3.ការចូលរួមកាន់តែប្រសើរ និងធ្វើកិច្ចការផ្ទះកាន់តែច្រើន 4.អត្រាបញ្ចប់ការសិក្សាកាន់តែខ្ពស់ 5.ការចុះឈ្មោះចូលរៀនកាន់តែច្រើនក្នុងការអប់រំក្រោយមធ្យមសិក្សា 6.សិស្សបង្ហាញអាកប្បកិរិយាវិជ្ជមានកាន់តែច្រើន 7.អាកប្បកិរិយាអវិជ្ជមានរបស់សិស្ស ដូចជាការប្រើប្រាស់គ្រឿងស្រវឹង អំពើហិង្សា និងអាកប្បកិរិយាប្រឆាំង សង្គមថយចុះនៅពេលដែលការចូលរួមរបស់ឪពុកម្តាយកើនឡើង។

**ខ.អត្ថប្រយោជន៍សម្រាប់ឪពុកម្តាយ៖** 1.ទំនុកចិត្តកាន់តែច្រើននៅក្នុងសាលា 2.កាន់តែមានទំនុកចិត្ត លើខ្លួនឯងជាឪពុកម្តាយ និងសមត្ថភាពក្នុងការជួយកូនរបស់ពួកគេនៅផ្ទះ (Wherry, JH, 2003)។ 3.

លទ្ធភាពកាន់តែច្រើនដែលឪពុកម្តាយនឹងចុះឈ្មោះចូលរៀនបន្ត ដើម្បីជំរុញការសិក្សារបស់ពួកគេ (Wherry, JH, 2003)។ 4.សមត្ថភាពក្នុងការទំនាក់ទំនង និងបង្កើតបណ្តាញសង្គមដែលពួកគេអាចប្រើដើម្បីបង្កើតឱកាសសម្រាប់កូនៗ និងខ្លួនឯង។ 5.បង្កើតទំនាក់ទំនងជិតស្និទ្ធជាមួយសហគមន៍ និងអ្នកជិតខាងរបស់ពួកគេ។ 6.រៀនពីរបៀបមានឥទ្ធិពលលើការសម្រេចចិត្តដែលបានធ្វើឡើងនៅក្នុងសាលារៀននិងសហគមន៍របស់ពួកគេ (Henderson, AT & Berla, N., 1994) (Assembly, 2004)។

## ២.១១ កំហុសឆ្គងទាំង ៦យ៉ាងរបស់ឪពុកម្តាយដែលរារាំងភាពជោគជ័យរបស់កូនៗ

ការចិញ្ចឹមបីបាច់ថែរក្សាកូនជាកាតព្វកិច្ចរបស់មាតាបិតាគ្រប់ៗរូប តែវាមិនមែនជារឿងងាយស្រួលនោះទេ។ ក្រោយពេលមានបុត្រធីតា មាតាបិតាតែងតែមានការព្រួយបារម្ភពីអនាគតរបស់កូនៗហើយខិតខំស្វែងរកវិធីសាស្ត្រផ្សេងៗក្នុងការបង្ហាត់បង្រៀនពួកគេដើម្បីធានាថាពួកគេទទួលបាននូវភាពជោគជ័យទៅថ្ងៃអនាគត។ លោកអ្នកប្រាកដជាមានការនឿយហត់ ហើយមិនយូរមិនឆាប់វានឹងធ្វើឲ្យអ្នកមានអារម្មណ៍ថាធុញទ្រាន់ក្នុងការមើលថៃ និងអប់រំប្រៀនប្រដៅពួកគេ ដោយចៀសមិនផុតពីការមានកំហុសឆ្គងផ្សេងៗដោយអចេតនា។ ជាក់ស្តែងកំហុសឆ្គងមួយចំនួនដែលអាចជះឥទ្ធិពលមិនល្អដល់ភាពជោគជ័យ និងការអភិវឌ្ឍរបស់កូនៗរបស់អ្នកដូចជា៖

**១.បារម្ភហួងហែងខ្លាំងពេក៖** ឪពុកម្តាយគ្រប់ៗរូបតែងតែស្រលាញ់ថ្នាក់ថ្នមកូននិងហ៊ានធ្វើអ្វីៗគ្រប់យ៉ាងដើម្បីពួកគេ។ ប៉ុន្តែមាតាបិតាខ្លះទម្រើសកូនខ្លាំងជ្រុលពេកដោយមិនហ៊ានបណ្តោយឲ្យកូនធ្វើកិច្ចការងារអ្វីមួយដែលគ្មានជំនួយពីពួកគេឡើយ។ ឧ. ការធ្វើកិច្ចការផ្ទះដែលគ្រូដាក់ឲ្យ ការស្លៀកពាក់ ងូតទឹក...ឬការសម្រេចចិត្តក្នុងការងារតូចៗ។ ប្រសិនបើលោកអ្នកតែងតែឈរចាំមើលគ្រប់គ្រងកូនគ្រប់ពេលនោះ វាអាចជាមូលហេតុមួយដែលធ្វើឲ្យកូនគ្មានភាពឯករាជ្យ គ្មានភាពជឿជាក់លើខ្លួនឯង និងគ្មានជំហររឹងមាំ។ ហេតុនេះបានជាធ្វើឲ្យកូនរបស់លោកអ្នកប្រែក្លាយជាមនុស្សដែលមិនអាចសម្រេចការងារអ្វីមួយដោយខ្លួនឯងបានឡើយ។

**២.ចូលចិត្តប្រៀបធៀប៖** ឪពុកម្តាយខ្លះចូលចិត្តប្រៀបធៀបកូនរបស់ខ្លួនទៅនឹងកូនអ្នកដទៃ តែនេះមិនមែនជាចំណុចល្អក្នុងការអប់រំកូននោះទេ។ ការអប់រំបែបនេះអាចនឹងធ្វើឲ្យកុមារក្លាយជាមនុស្សម្នាក់ដែលមានសម្ពាធផ្លូវចិត្ត និងគិតច្រើន។ ពួកគេនឹងបាត់បង់នូវទំនុកចិត្តលើខ្លួនឯងថែមទាំងទទួលបាននូវអារម្មណ៍មួយថាខ្លួនឯងមានសមត្ថភាពមិនគ្រប់គ្រាន់ក្នុងការធ្វើកិច្ចការ និងមានភាពរារែកក្នុងការសម្រេចចិត្ត។ ទម្លាប់បែបនេះនឹងជះឥទ្ធិពលអាក្រក់ដល់ពួកគេទៅថ្ងៃអនាគត។

**៣.ស្រែកគំហកនិងប្រើអំពើហិង្សា៖** ការស្រែកគំហក និងប្រើអំពើហិង្សាអាចផ្តល់ផលប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់កុមារ។ ប្រសិនបើអ្នកមានទម្លាប់និយាយខ្លាំងៗ ឬស្រែកគំហកដាក់កូនអ្នកគួរកែទម្លាប់ទាំងនេះចេញព្រោះវាអាចធ្វើឲ្យក្មេងមានជំងឺបាក់ស្បាត ដែលអាចឈានទៅរកជំងឺបាក់ទឹកចិត្ត និងខ្លាចគេទៅថ្ងៃមុខ។

**៤.មិនធ្វើជាគំរូល្អ៖** ក្មេងងាយនឹងទទួលរងនូវឥទ្ធិពលពីមនុស្សធំតាមរយៈទង្វើ និងទម្លាប់របស់ពួកគេព្រមទាំងបរិស្ថាននៅជុំវិញខ្លួនរបស់ក្មេងផងដែរ។ ក្មេងមិនអាចបែងចែកដោយខ្លួនឯងថា ទង្វើណាជះឥទ្ធិពលល្អ ឬអាក្រក់ឡើយ។ ដោយឡែក កូនដែលពូកែកុហកជាលទ្ធផលបានពីប៉ាម៉ាក់ដែលពូកែកុហក។ មាតាបិតាដែលមិនបានដើរតួនាទីជាមេគ្រួសារ ឬមេផ្ទះដែលមានទំនួលខុសត្រូវនឹងមិនអាចមានឱកាសទទួលបានកូនដែលមានសមត្ថភាពអាចគ្រប់គ្រងការងារមួយប្រកបដោយទំនួលខុសត្រូវនោះទេ។

**៥.មិនចំណាយពេលវេលាជាមួយកូន៖** ក្មេងត្រូវការ ការថ្នាក់ថ្នម ភាពស្និទ្ធស្នាល និងទំនាក់ទំនងល្អពីមាតាបិតា ដើម្បីឲ្យការលូតលាស់ផ្នែកបញ្ញាស្មារតី និងសារពាង្គកាយបានល្អប្រសើរ។ ឪពុកម្តាយខ្លះមិនមានពេលវេលាគ្រប់គ្រាន់ក្នុងការនៅជាមួយកូននោះទេ ខ្លះទៀតទុកកូនចោលឲ្យលេងតែម្នាក់ឯង ឬមើលស្មាតហ្វូន...ទាំងនេះសុទ្ធតែជាមូលហេតុដែលធ្វើឲ្យកូនក្លាយជាក្មេងមិនចេះមាត់ក មិនសូវចូលចិត្តមានទំនាក់ទំនងជាមួយអ្នកដទៃ និងខ្វះភាពកក់ក្តៅ។ ហេតុដូចនេះ កូនរបស់អ្នកអាចនឹងក្លាយជាមនុស្សឯកោ និងពិបាកចូលចំណោមក្នុងសង្គមនៅពេលដែលពួកគេធំឡើង។

**៦.បិទសិទ្ធិសេរីភាពរបស់កូន៖** កុមារគ្រប់រូបទទួលបាននូវសិទ្ធិសេរីភាពក្នុងការសម្រេចចិត្តដោយគ្មានការគាបសង្កត់ពីមនុស្សពេញវ័យ។ ដោយឡែក មាតាបិតាមួយចំនួនតែងគិតថាកាលបើយើងបើកសិទ្ធិឲ្យកូនធ្វើអ្វីតាមចិត្ត នោះជាទម្លាប់មិនល្អដែលអាចធ្វើឲ្យកូនក្លាយជាក្មេងទម្រើស។ នេះជាទស្សនៈមួយដែលមិនត្រឹមត្រូវនោះទេក្មេងគួរតែទទួលបានសិទ្ធិនេះយ៉ាងពេញលេញដើម្បីឲ្យពួកគេក្លាយជាក្មេងដែលមានទំនុកចិត្តលើខ្លួនឯង។ ដូច្នេះ ប្រសិនបើលោកអ្នកមានទម្លាប់ក្នុងការចិញ្ចឹមកូនដូចដែលយើងបានរៀបរាប់ខាងលើ លោកអ្នកគួរតែព្យាយាមកែប្រែទម្លាប់ទាំងនេះចេញដើម្បីកាត់បន្ថយការរងសម្ពាធផ្លូវចិត្ត និងចៀសវាងការបង្កើតនូវទម្លាប់មិនល្អរបស់ក្មេង។ កុមារដែលមិនរងការប៉ះទង្គិចផ្លូវចិត្តនឹងអាចក្លាយជាមនុស្សពេញវ័យដែលមានភាពជោគជ័យក្នុងឆាកជីវិត (Healthytime, 2019)។

# ជំពូក ៣

# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូក ៣

# វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវស្តីពី **«ទស្សនៈរបស់មាតាបិតាសិស្ស ចំពោះតួនាទីរបស់ខ្លួន ក្នុងការចូលរួមចំណែកជួយការអប់រំ និងការសិក្សារបស់កូនៗ នៅមធ្យមសិក្សាទុតិយភូមិ» (ករណីសិក្សា នៅរាជធានីភ្នំពេញ)** គឺមានគោលបំណងសិក្សាពីការចូលរួមចំណែកជួយកូនក្នុងការសិក្សា របស់មាតាបិតាសិស្ស និងបញ្ហាប្រឈមក្នុងការចូលរួមចំណែករបស់ពួកគាត់ ដែលមានក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ។ នៅក្នុងនោះដែរ អ្នកស្រាវជ្រាវបាន ចុះប្រមូលនៅក្នុងវិទ្យាល័យចំនួន៥ ដែលស្ថិតនៅក្នុងខណ្ឌចំនួន៥ផ្សេងៗគ្នា វិទ្យាល័យហ៊ុន សែន ចាក់អង្រែ វិទ្យាល័យជាស៊ីម បឹងកេងកង វិទ្យាល័យពងទឹក វិទ្យាល័យទឹកល្អក់ និង វិទ្យាល័យហ៊ុន សែន បុរី១០០ខ្នង។ វិធីសាស្ត្រនៃការស្រាវជ្រាវគឺធ្វើឡើងតាមបែបបរិមាណវិស័យ។

## ៣.១ គម្រោងវិភាគ

ការស្រាវជ្រាវនេះរៀបចំឡើងដើម្បីសម្រេចគោលបំណងស្រាវជ្រាវចំនួនពីរគឺៈ (១) ស្វែងយល់ពីទស្សនៈរបស់មាតាបិតាសិស្ស ចំពោះតួនាទីរបស់ខ្លួន ក្នុងការរួមចំណែកជួយការអប់រំ និងការសិក្សារបស់កូនៗ នៅមធ្យមសិក្សាទុតិយភូមិ (២)ស្វែងរកពីឧបសគ្គនានារបស់មាតាបិតាសិស្ស ចំពោះតួនាទីរបស់ខ្លួន ក្នុងការរួមចំណែកជួយការអប់រំ និងការសិក្សារបស់កូនៗ នៅមធ្យមសិក្សាទុតិយភូមិ។

ដើម្បីសម្រេចបានវត្ថុបំណងស្រាវជ្រាវទាំងពីរខាងលើ អ្នកស្រាវជ្រាវបានកំណត់យកវិធីសាស្ត្រស្រាវជ្រាវតាមវិធីសាស្ត្របែបបរិមាណវិស័យ ដែលទិន្នន័យតាមបែបបរិមាណវិស័យ ប្រើប្រាស់ដើម្បីឆ្លើយតបទៅនឹងគោលបំណងទាំងពីរខាងលើនេះ។

## ៣.២ ការប្រមូលទិន្នន័យ

បន្ទាប់ពីទទួលបានលិខិតឧទ្ទេសនាមពីក្រសួងអប់រំ យុវជន និងកីឡា លេខ ២៣៤១ អយក.វជអ ចុះថ្ងៃសុក្រ ១៣រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០២២ ស្តីពីការចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៩ អ្នកស្រាវជ្រាវបានឆ្លងយោបល់ពីសំណាក់គ្រូណែនាំគោល និងគ្រូណែនាំរង និង

បានរៀបចំជាកម្រងសំណួរ ដើម្បីធ្វើការចុះប្រមូលទិន្នន័យ គឺ ចាប់ពីថ្ងៃទី០២ ខែឧសភា រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ ២០២២ តាមវិទ្យាល័យគោលដៅនីមួយៗ រួមមាន ៖ វិទ្យាល័យហ៊ុន សែន ចាក់អង្រែ វិទ្យាល័យជាស៊ីម បឹងកេងកង វិទ្យាល័យពងទឹក វិទ្យាល័យទឹកល្អក់ និងវិទ្យាល័យហ៊ុន សែន បុរី១០០ខ្នង ដែលស្ថិតក្នុង រាជធានីភ្នំពេញ ធ្វើជាភាគសំណាកក្នុងការស្រាវជ្រាវ។ ការជ្រើសរើសវិទ្យាល័យទាំង៥ នៅក្នុងរាជធានីភ្នំពេញ មកធ្វើការស្រាវជ្រាវនេះដោយផ្អែកទៅលើទីតាំងភូមិសាស្ត្រ និងរបាយប្រជាជន កម្រិតជីវភាពក្នុងការរស់នៅប្រចាំថ្ងៃ។

យោងទៅលើអាកាសធាតុ និងលក្ខខណ្ឌទីតាំងភូមិសាស្ត្រនៃសាលាគោលដៅនីមួយៗ នៅឆ្ងាយពីគ្នា ការចុះប្រមូលទិន្នន័យនេះ អ្នកស្រាវជ្រាវបានប្រើប្រាស់អស់រយៈពេល២១ថ្ងៃ គឺគិតចាប់ពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២២។

### ៣.៣ ឧបករណ៍ស្រាវជ្រាវ

ដើម្បីសម្រេចតាមគោលបំណងនៃការស្រាវជ្រាវ អ្នកសិក្សាស្រាវជ្រាវបានរៀបចំចងក្រង ជាកម្រងសំណួរចំនួន៣ ទៅតាមផ្នែកនីមួយៗដើម្បីងាយស្រួលក្នុងការប្រមូលទិន្នន័យ ព័ត៌មាន ដែលទាក់ទងទៅនិង មាតាបិតាសិស្ស លោកគ្រូ អ្នកគ្រូ និង សិស្សានុសិស្ស ដើម្បីងាយស្រួលក្នុងការជួយបំពេញកម្រងសំណួរ។ កម្រងសំណួរទាំងនេះ ត្រូវបានរៀបចំឡើងតាមបែបបរិមាណវិស័យ។ រាល់សំណួរជាទម្រង់បិទមានលក្ខណៈជាក់លាក់តាមលំដាប់លំដោយ និងមានសំណួរបន្ថែម បញ្ហាប្រឈមនិងសំណូមពរ តាមទម្រង់បើក។ ចំពោះកម្រងសំណួរទាំងបី ផ្តោតសំខាន់ទៅលើដំណើរការនៃការរួមចំណែករបស់ឪពុកម្តាយចំពោះការអប់រំរបស់កូន បញ្ហាប្រឈមដែលជះឥទ្ធិពលដល់ការរួមចំណែករបស់ឪពុកម្តាយចំពោះការអប់រំកូន និងយុទ្ធសាស្ត្រក្នុងការជួយជំរុញ និងលើកទឹកចិត្តឪពុកម្តាយឱ្យចូលរួមចំពោះការអប់រំរបស់កូន។ កម្រងសំណួរទាំង៣នេះ ត្រូវបានយកទៅប្រើដើម្បីប្រមូលព័ត៌មានពីវិទ្យាល័យគោលដៅទាំង៥ ដែលស្ថិតនៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ។ កម្រងសំណួរនីមួយៗចែកជាផ្នែក តាមមូលន័យដែលជាគោលបំណងនៃសិក្សាស្រាវជ្រាវ។

កម្រងសំណួរសម្រាប់មាតាបិតា ចែកជា ៣ផ្នែក៖ ផ្នែកទី១ ស្តីពីព័ត៌មានផ្ទាល់ខ្លួន ដោយសួរអំពីតួនាទីដែលត្រូវជា(ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាល) មុខរបរ កម្រិតនៃការសិក្សា ចំនួនម៉ោងធ្វើការក្នុង១ថ្ងៃ ចំនួនកូនសរុប និងកម្រិតថ្នាក់ដែលកូនកំពុងសិក្សាបច្ចុប្បន្ននៅមធ្យមសិក្សាទុតិយភូមិ។ ផ្នែកទី២ ស្តីពីទស្សនៈរបស់មាតាបិតាលើតួនាទី ក្នុងការចូលរួម និងការសិក្សារបស់កូន។ ផ្នែកនេះផ្តោតទៅលើដំណើរការចំពោះតួនាទីក្នុងការចូលរួមចំណែកអប់រំកូនរបស់មាតាបិតា។ ការរួមចំណែកពីមាតាបិតានៅសាលារៀន។ ឥទ្ធិពលនៃការចូលរួមរបស់មាតាបិតាលើសមិទ្ធផលការសិក្សា។ ការទំនាក់ទំនងរវាងមាតាបិតា ការចូលរួម និងការលើកទឹកចិត្តសិស្ស។ ការចូលរួមចំណែកលើការអប់រំកូន និងការទទួលខុសត្រូវរបស់មាតាបិតា។ ការត្រួតពិនិត្យ និងតាមដានការសិក្សារបស់កូន ការបង្ហាត់បង្រៀនកូន ការចូលរួមធ្វើកិច្ចការផ្ទះ បទពិសោធន៍របស់មាតាបិតា ក្នុងការអប់រំកូន។ ផ្នែកទី៣ ផ្តោតទៅលើឧបសគ្គរាំងនៃការចូលរួម និងបញ្ហាប្រឈមនានា។

កម្រងសំណួរសម្រាប់សិស្សានុសិស្ស មានបីផ្នែក៖ ផ្នែកទី១ ផ្តោតទៅលើព័ត៌មានផ្ទាល់ខ្លួនរបស់សិស្ស ទាក់ទងនិង ភេទ កម្រិតថ្នាក់ និងឈ្មោះវិទ្យាល័យដែលសិស្សកំពុងរៀន។ ផ្នែកទី២ ស្តីពីទស្សនៈរបស់មាតាបិតាលើតួនាទី ក្នុងការចូលរួម និងការសិក្សារបស់កូន។ ផ្នែកនេះផ្តោតទៅលើ ដំណើរការចំពោះតួនាទីក្នុងការចូលរួមចំណែកអប់រំកូនរបស់មាតាបិតា។ ការរួមចំណែកពីមាតាបិតានៅសាលារៀន។ ឥទ្ធិពលនៃការចូលរួមរបស់មាតាបិតាលើសមិទ្ធផលការសិក្សា។ ការទំនាក់ទំនងរវាងមាតាបិតា ការចូលរួម និងការលើកទឹកចិត្តសិស្ស។ ការចូលរូមចំណែកលើការអប់រំកូន និងការទទួលខុសត្រូវរបស់មាតាបិតា។ ការត្រួតពិនិត្យ និងតាមដានការសិក្សារបស់កូន ការបង្ហាត់បង្រៀនកូន ការចូលរួមធ្វើកិច្ចការផ្ទះ បទពិសោធន៍របស់មាតាបិតា ក្នុងការអប់រំកូន។ ចំណែកឯផ្នែកទី៣ លើកឡើងពីឧបសគ្គរាំងនៃការចូលរួម និងបញ្ហាប្រឈមនានា។

កម្រងសំណួរសម្រាប់លោកគ្រូ អ្នកគ្រូ ចំពោះកម្រងសំណួរនេះដែរ បានរៀបចំចងក្រងជាបីផ្នែកគឺសំខាន់ៗគឺ៖ ផ្នែកទី១ លើកឡើងពីព័ត៌មានផ្ទាល់ខ្លួនទាក់ទងទៅនឹង ភេទ អាយុ កម្រិតវប្បធម៌ ទីកន្លែងបម្រើការងារបច្ចុប្បន្ន បទពិសោធន៍បំពេញការងារ មុខវិជ្ជាកំពុងបង្រៀន និងកម្រិតថ្នាក់ដែលគាត់បង្រៀន។

ផ្នែកទី២ ស្តីពីទស្សនៈរបស់មាតាបិតាលើតួនាទី ក្នុងការចូលរួម និងការសិក្សារបស់កូន។ ផ្នែកនេះផ្តោតទៅលើ ដំណើរការចំពោះតួនាទីក្នុងការចូលរួមចំណែកអប់រំកូនរបស់មាតបិតា។ ការរួមចំណែកពីមាតាបិតានៅសាលារៀន។ ឥទ្ធិពលនៃការចូលរួមរបស់មាតាបិតាលើសមិទ្ធផលការសិក្សា។ ការទំនាក់ទំនងរវាងមាតាបិតា ការចូលរួម និងការលើកទឹកចិត្តសិស្ស។ ការចូលរួមចំណែកលើការអប់រំកូន និងការទទួលខុសត្រូវរបស់មាតាបិតា។ ការត្រួតពិនិត្យ និងតាមដានការសិក្សារបស់កូន ការបង្ហាត់បង្រៀនកូន ការចូលរួមធ្វើកិច្ចការផ្ទះ បទពិសោធន៍របស់មាតាបិតា ក្នុងការអប់រំកូន។ ផ្នែកទី៣ លើកឡើងពីឧបសគ្គរាំងនៃការចូលរួម និងបញ្ហាប្រឈមនានា។

### ៣.៣.១ កម្រិតចង្អុលបង្ហាញ

កម្រិតចង្អុលបង្ហាញនៃការសិក្សាស្រាវជ្រាវប្រធានបទខាងលើមានចំនួន ៥កម្រិត ដែលត្រូវយកមកប្រើប្រាស់និងវាស់វែង តាមបែប Likert Scale។ តួលេខ១ ដល់លេខ៥ ត្រូវបានប្រើប្រាស់ដើម្បីវាស់វែងសូចនាករវាយតម្លៃកម្រិតនៃការចូលរួមចំណែកជួយការអប់រំ និងការសិក្សារបស់កូនៗ របស់មាតាបិតា។ កម្រិតចង្អុលបង្ហាញនេះរាប់ពីទាបទៅខ្ពស់ ដូចខាងក្រោម៖

កម្រិត១ = មិនយល់ស្រប

កម្រិត២ = យល់ស្របតិចតួច

កម្រិត៣ = ពុំមានយោបល់

កម្រិត៤ = យល់ស្រប

កម្រិត៥ = យល់ស្របទាំងស្រុង

រូបមន្តខាងក្រោមត្រូវបានប្រើប្រាស់ ដើម្បីបកស្រាយការគណនាពិន្ទុមធ្យមភាគនៃសូចនាករនីមួយៗ៖

$$\frac{\text{ពិន្ទុខ្ពស់បំផុត} - \text{ពិន្ទុទាបបំផុត}}{\text{ចំនួនកម្រិតចង្អុលបង្ហាញ}} = \frac{5-1}{5} = 0.80$$

១.០០ ដល់ ១.៨០ មានន័យថា ខ្សោយណាស់

១.៨១ ដល់ ២.៦០ មានន័យថា ខ្សោយ

២.៦១ ដល់ ៣.៤០ មានន័យថា មធ្យម

៣.៤១ ដល់ ៤.២០ មានន័យថា ល្អ

៤.២១ ដល់ ៥.០០ មានន័យថា ល្អណាស់

### ៣.៣.២ កម្រងសំណួរ

អ្នកស្រាវជ្រាវបានប្រើប្រាស់កម្រងសំណួរបីប្រភេទ គឺកម្រងសំណួរសម្រាប់មាតាបិតាសិស្ស កម្រងសំណួរសម្រាប់លោកគ្រូ អ្នកគ្រូ និងកម្រងសំណួរសម្រាប់សិស្សានុសិស្ស។ ក្នុងកម្រងសំណួរទាំងអស់នេះ ចែកចែញជា៣ជំពូកធំៗ ដូចខាងក្រោម៖ **(មើលឧបសម្ព័ន្ធ...)**

ផ្នែកទី១ គឺជាព័ត៌មានទូទៅ ដែលសួរអំពី ភេទ អាយុ សិស្សថ្នាក់ទី... រៀននៅវិទ្យាល័យ ប្រកបមុខរបរ កម្រិតវប្បធម៌ ចំនួនម៉ោងធ្វើការក្នុង១ថ្ងៃ មានកូនសរុប បទពិសោធន៍បំពេញការងារ មុខវិជ្ជា ឯកទេស ទីកន្លែងការងារ និងកម្រិតថ្នាក់កំពុងបង្រៀន។

ផ្នែកទី២ គឺជាសំណួរទាក់ទងនឹងទស្សនៈរបស់មាតាបិតាសិស្ស លើតួនាទីរបស់ខ្លួន ក្នុងការចូលរួម និងការសិក្សារបស់កូន ដែលត្រូវបែងចែកជា៥ចំណុចទៀតគឺ ១-ដំណើរការចំពោះតួនាទីក្នុងការចូលរួមចំណែកអប់រំកូនរបស់មាតាបិតា (មាន៩សូចនាករ)។ ២-ការរួមចំណែកពីមាតាបិតានៅសាលារៀន (មាន១០សូចនាករ)។ ៣-ឥទ្ធិពលនៃការចូលរួមរបស់មាតាបិតាលើសមិទ្ធផលការសិក្សា (មាន១១សូចនាករ)។ ៤-ការទំនាក់ទំនងរវាងមាតាបិតា ការចូលរួម និងការលើកទឹកចិត្តសិស្ស (មាន៧សូចនាករ)។ និង ៥-ការចូលរួមចំណែកលើការអប់រំកូន និងការទទួលខុសត្រូវរបស់មាតាបិតា (មាន៤សូចនាករ)។

ផ្នែកទី៣ គឺជាសំណួរផ្តោតទៅលើឧបសគ្គរាំងនៃការចូលរួម និងបញ្ហាប្រឈមនានា (មាន១៣សូចនាករ)។

## ៣.៤ ការជ្រើសរើសភាគសំណាក

យោងតាមស្ថិតិនៅឆ្នាំ ២០២១ ទៅ ២០២២ នៃក្រសួងអប់រំយុវជន និងកីឡា នៅរាជធានីភ្នំពេញ មានវិទ្យាល័យសរុបចំនួន ១៥១ (មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ ឆ្នាំ ២០១៧ ២០១៨ )។ ក្នុងនោះដែរវិទ្យាល័យចំនួន៥ ត្រូវបានជ្រើសរើសចេញពីខណ្ឌចំនួន៥ ក្នុងចំណោមខណ្ឌទាំង១៤ នៅរាជធានីភ្នំពេញ ដោយជ្រើសរើសវិទ្យាល័យក្នុងខណ្ឌទាំង៥នោះ រួមមានដូចជា៖ ខណ្ឌបឹងកេងកង ខណ្ឌមានជ័យ ខណ្ឌទួលគោក និងខណ្ឌដង្កោ និងខណ្ឌសែនសុខ។ ការសិក្សាស្រាវជ្រាវនេះបានជ្រើសរើសភាគសំណាកឪពុកម្តាយសិស្សចំនួន៦២នាក់ សិស្សានុសិស្សចំនួន១២៣នាក់ និងលោកគ្រូ អ្នកគ្រូ ចំនួន ៣៧នាក់។ ការជ្រើសរើសំណាកតាមបែបងាយស្រួល (Convenience Sampling) សំណាកដែលត្រូវជ្រើសរើសមានលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់ដែលឆ្លើយតបទៅនឹងប្រធានបទ និងអាចផ្តល់ឲ្យនូវព័ត៌មានសមស្របបំផុតទាក់ទងនឹងប្រធានបទ (Creswell,2012)។ ដូចនេះអ្នកស្រាវជ្រាវបានធ្វើការសម្រេចចិត្តកំណត់យកវិទ្យាល័យទាំង៥ នៅក្នុងខណ្ឌទាំង៥ដូចខាងលើ។

*ភាគសំណាកតាមសាលាគោលដៅនីមួយៗ*

**តារាងភាគសំណាកតាមវិទ្យាល័យគោលដៅនីមួយៗ**

**ស្ថិតនៅក្នុងរាជធានីភ្នំពេញ**

| ល.រ | វិទ្យាល័យ | ខណ្ឌ | ភាគសំណាក | | | | | |
|---|---|---|---|---|---|---|---|---|
| | | | មាតាបិតា | | គ្រូ | | សិស្ស | |
| | | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | ហ៊ុន សែន ចាក់អង្រែ | មានជ័យ | ១៣ | ៩ | ១២ | ៣ | ៣៣ | ១៤ |
| ២ | ហ៊ុនសែន បុរី១០០ ខ្នង | សែនសុខ | ១២ | ៦ | ៦ | ៣ | ២៤ | ១៥ |
| ៣ | ជាស៊ីម បឹងកេងកង | បឹងកេងកង | ១២ | ៤ | ៦ | ១ | ២៤ | ១១ |
| ៤ | ពងទឹក | ដង្កោ | ១២ | ៤ | ៦ | ៣ | ២១ | ១២ |
| ៥ | ទឹកល្អក់ | ទួលគោក | ១៣ | ៧ | ៧ | ២ | ២១ | ១០ |
| **សរុប** | | | **៦២** | **៣០** | **៣៧** | **១២** | **១២៣** | **៦២** |

### ៣.៥ ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យធ្វើឡើងតាមបរិមាណវិស័យបែបពណ៌នា (Descriptive_statistic) ការបកស្រាយ និងវិភាគទិន្នន័យផ្អែកលើតួលេខតារាង ភាគរយ និងកម្រិតតម្លៃមធ្យមដោយប្រើកម្មវិធី SPSS ដើម្បីរកមធ្យមភាគ និងគម្លាតស្តង់ដា ក្នុងគោលបំណងឆ្លើយតបទៅនិងសំណួរទី១។ ចំពោះកម្មវិធី SPSS អ្នកសិក្សាបានបញ្ចូលចម្លើយនីមួយៗទៅក្នុងកម្មវីធីSPSS ដោយចម្លើយនីមួយៗអ្នកស្រាវជ្រាវធ្វើការបង់លេខកូដត្រឹមត្រូវស្របតាមកម្រិតនៃការវាស់វែងទៅតាមសូចនាករនីមួយៗ។

# ជំពូក ៤

# លទ្ធផល និងការពិភាក្សា

# ជំពូក ៤

# លទ្ធផល និងការពិភាក្សា

ជំពូកទី៤ នេះ អ្នកស្រាវជ្រាវនឹងធ្វើការបង្ហាញ បកស្រាយ និងពិភាក្សាលទ្ធផលនូវអ្វីដែលបានរកឃើញតាមរយៈការបំពេញកម្រងសំណួរលើក្រុមគោលដៅដែលពាក់ព័ន្ធ។ អ្នកស្រាវជ្រាវប្រើប្រាស់ទិន្នន័យបានមកពីការបំពេញកម្រងសំណួរតាមរយៈឯកសារជា (Hard Copy) ដើម្បីមានភាពងាយស្រួលក្នុងការចុះទៅប្រមូលជាក់ស្តែងដល់សាលាគោលដៅនីមួយៗ ដែលប្រមូលបានជាក់ស្តែងមានចំនួនសរុប ២២២ នាក់ នៅក្នុងរាជធានីភ្នំពេញ ដើម្បីស្វែងយល់ពីវឌ្ឍនភាព បញ្ហាប្រឈម និងការចូលរួមពីអ្នកពាក់ព័ន្ធក្នុងនោះមានដូចជា មាតាបិតាសិស្ស លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស តាមកម្រិតថ្នាក់នៅមធ្យមសិក្សាទុតិយភូមិ។ ការចូលរួមចំណែកជួយការអប់រំ ជួយសិស្ស ជាពិសេសគឺផ្តោតសំខាន់ទៅលើមាតាបិតាសិស្សតែម្តង ថាតើពួកគាត់បានយកចិត្តទុកដាក់ក្នុងការជួយកូនក្នុងការសិក្សាបានដល់កម្រិតណា។

ការវិភាគទិន្នន័យ នៃការសិក្សាស្រាវជ្រាវស្តីពីទស្សនៈរបស់មាតាបិតាសិស្ស លើតួនាទីរបស់ខ្លួនក្នុងការចូលរួមចំណែកក្នុងការអប់រំ និងការសិក្សារបស់កូនៗ គឺអ្នកស្រាវជ្រាវបានធ្វើការវិភាគទិន្នន័យបង្ហាញលទ្ធផលលើការវិភាគទិន្នន័យ និងពិភាក្សាតាមចំណុចសំខាន់ៗស្របតាមគោលបំណងនៃការស្រាវជ្រាវ ដោយបែងចែកជា ២ ផ្នែក។

ផ្នែកទី១៖ លទ្ធផលវិភាគលើកម្រិត ទស្សនៈរបស់មាតាបិតាសិស្ស លើតួនាទីរបស់ខ្លួន ក្នុងការចូលរួមចំណែកជួយការអបរំ និងការសិក្សារបស់កូនៗ ដោយផ្តោតសំខាន់លើ៤១សូចនាករ។

ផ្នែកទី២៖ លទ្ធផលវិភាគពីឧបសគ្គរាំងនៃការចូលរួម និងបញ្ហាប្រឈមនានាដោយផ្តោតសំខាន់លើ១៣ សូចនាករ។

## ៤.១ ព័ត៌មានមូលដ្ឋាននៃអ្នកចូលរួម

ក្នុងកិច្ចការស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានប្រមូលភាគសំណាកជាបីផ្នែកទៅលើអ្នកចូលរួម រួមមាន៖ មាតាបិតាសិស្សចំនួន៦២នាក់ ស្មើនឹង១០០% ក្នុងនោះស្រីចំនួន៣០នាក់ ស្មើនឹង ៤៨,៣៨%។

គ្រូបង្រៀនចំនួន៣៧នាក់ ស្មើនឹង១០០% ក្នុងនោះស្រីចំនួន១២នាក់ ស្មើនឹង៣២,៤៣%។ សិស្សមានចំនួន១២៣នាក់ស្មើនឹង១០០% ក្នុងនោះស្រីចំនួន៦២នាក់ ស្មើនឹង៥០,៤០%។

## ៤.២ លទ្ធផលការស្រាវជ្រាវ

### ៤.២.១ ទស្សនៈរបស់មាតាបិតាសិស្ស លើតួនាទីរបស់ខ្លួន ក្នុងការចូលរួម និង ការសិក្សារបស់កូន

ទស្សនៈរបស់មាតាបិតាសិស្ស លើតួនាទីរបស់ខ្លួន ក្នុងការចូលរួម និងការសិក្សារបស់កូន គឺពួកគាត់ជួយកូនក្នុងការសិក្សា និងជួយផ្នែកផ្សេងៗទៀតតាមលទ្ធភាពរបស់ពួកគាត់ ពិតជាមានសារៈសំខាន់យ៉ាងខ្លាំងចំពោះកូន។ ដំណើរការចូលរួមចំណែកនោះទៀតសោតមានលក្ខណៈខុសគ្នាពីម្នាក់ទៅម្នាក់ផ្អែកលើស្ថានភាពជាក់ស្តែងរបស់ក្រុមគ្រួសារ ដូចជា ចំណេះដឹង សេដ្ឋកិច្ច ពេលវេលា កត្តាទំនាក់ទំនងសាលា និងកត្តាផ្សេងៗទៀតជាច្រើន។ ខាងក្រោមនេះគឺជាលទ្ធផលដែលបានមកពីការវិភាគលើផ្នែកសំខាន់ៗដែលអ្នកសិក្សាស្រាវជ្រាវបង្ហាញក្នុងរូបភាព និងតារាងគិតជាភាគរយ និងមធ្យម ដោយយោងតាមតម្លៃមធ្យម(១.00-១.៨០)=មានន័យថាខ្សោយណាស់ (១.៨១-២.៦០)= មានន័យថាខ្សោយ (២.៦១-៣.៤០)=មានន័យថា មធ្យម (៣.៤១-៤.២០)=មានន័យថាល្អ (៤.២១-៥.00)=មានន័យថាល្អណាស់។

ការវិភាគទិន្នន័យ គឺប្រើប្រាស់តម្លៃមធ្យម និងគម្លាតស្តង់ដា។ លទ្ធផលផ្នែកទី១ ត្រូវបានបង្ហាញតាមតារាងដូចខាងក្រោម៖

លទ្ធផលនៃកម្រងសំណួរសម្រាប់មាតាបិតា

តារាងទី៤.១ ៖ តម្លៃមធ្យម គម្លាតស្តង់ដា កម្រិតចង្អុលបង្ហាញ ដំណើរការចូលរួមចំណែកអប់រំកូនរបស់មាតាបិតា តាមចំណុចនីមួយៗ (N=៦២)

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ខ្ញុំយល់ឃើញថា ការអប់រំមានសារៈសំខាន់ណាស់ចំពោះកូនៗ | ៤.៤៣ | ០.៥៦ | ល្អណាស់ |
| ២ | ខ្ញុំតែងតែបានពិភាក្សាជាមួយកូន អំពីការសិក្សារបស់ពួកគេ គឺពិតមានសារៈសំខាន់ណាស់សម្រាប់ខ្ញុំដែលជាឪពុកម្តាយ | ៤.១១ | ០.៧២ | ល្អ |
| ៣ | ខ្ញុំជឿជាក់ថាកូនៗ យល់ដឹងច្រើន អំពីសារៈសំខាន់នៃការសិក្សា | ៣.៩៨ | ០.៧៩ | ល្អ |
| ៤ | ខ្ញុំជំរុញកូនឲ្យទៅសាលារៀនបានទៀងទាត់ និងទាន់ពេលវេលា គឺពិតជាមានសារៈសំខាន់ណាស់ចំពោះការសិក្សារបស់ពួកគេ | ៤.២០ | ០.៧៤ | ល្អ |
| ៥ | ខ្ញុំតាមដានសកម្មភាពកូនៗ ដែលពួកគេចំណាយពេលនៅក្រៅសាលារៀនបានជាប្រចាំ | ៣.៥១ | ១.០៥ | ល្អ |
| ៦ | ខ្ញុំតែងតែសាកសួរកូនអំពីផលលំបាក ឬឧបសគ្គនៅពេលដែលកូនធ្វើដំណើរទៅសាលា និងពេលត្រឡប់មកផ្ទះវិញ | ៣.៥១ | ១.០៩ | ល្អ |
| ៧ | ខ្ញុំចំណាយពេលជូនកូនទៅសាលា និងទៅទទួលមកផ្ទះវិញជាប្រចាំ | ២.៨៨ | ១.២៤ | មធ្យម |
| ៨ | ខ្ញុំបានចូលរួមជួយកូន ចំពោះការសិក្សារបស់គេស្ទើរគ្រប់មុខវិជ្ជា | ៣.២៤ | ១.១១ | មធ្យម |
| ៩ | ខ្ញុំតែងតែលើកទឹកចិត្ត និងជួយជំរុញដល់កូនជានិច្ច គ្រប់កាលៈទេសៈនៅក្នុងការសិក្សារបស់គេ | ៤.០៤ | ០.៩៦ | ល្អ |
| | **សរុប** | **៣.៧៧** | **០.៥៥** | **ល្អ** |

តារាងខាងលើនេះ បានបង្ហាញពីដំណើរការ ចំពោះតួនាទីក្នុងការចូលរួមចំណែកអប់រំកូនរបស់មាតាបិតា សរុបគឺ ស្ថិតក្នុងកម្រិត(**ល្អ**) (**M = ៣.៧៧, S.D = ០.៥៥**)។

លទ្ធផលខាងលើបង្ហាញថា សូចនាករដែលមានលំដាប់មធ្យមភាគខ្ពស់ជាងគេ គឺចំណុចទី១ «ឪពុកម្តាយសិស្ស យល់ឃើញថា ការអប់រំមានសារៈសំខាន់ណាស់ ចំពោះកូនៗ» ស្ថិតក្នុងកម្រិត ល្អណាស់ (**M = ៤.៤៣ , S.D = ០.៥៦**)។ ចំពោះសូចនាករដែលមានលំដាប់មធ្យមភាគទាបជាងគេ គឺចំណុចទី៧ «ឪពុកម្តាយសិស្ស ចំណាយពេលជូនកូនទៅសាលា និងទៅទទួលមកផ្ទះវិញជាប្រចាំ» ស្ថិតក្នុងកម្រិតមធ្យម (**M = ២.៨៨ , S.D = ១.២៤**)។

ដំណើរការចំពោះតួនាទីក្នុងការចូលរួមចំណែកអប់រំកូនរបស់មាតាបិតា មានសូចនាករសរុបចំនួន ៩ ក្នុងនោះ ឪពុកម្តាយសិស្ស បានធ្វើការជ្រើសរើសយកចម្លើយ កម្រិតល្អណាស់មានចំនួន១ កម្រិតល្អមានចំនួន៦ និងកម្រិតមធ្យមចំនួន២។ តាមលទ្ធផលបានបង្ហាញថា ដំណើរការចំពោះតួនាទីក្នុងការចូលរួមចំណែកអប់រំកូនរបស់មាតាបិតា គឺមានភាពល្អប្រសើរ ដោយឪពុកម្តាយ បានយល់ដឹង និងចូលរួម បានច្រើន ក្នុងការអប់រំកូន។

**តារាងទី៤.២ ៖ តម្លៃមធ្យម គម្លាតស្តង់ដា កម្រិតចង្អុលបង្ហាញ ការរួមចំណែកពីមាតាបិតានៅសាលារៀន តាមចំណុចនីមួយៗ (N=៦២)**

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ខ្ញុំឧស្សាហ៍ទៅសាលារៀនដើម្បីជួប នាយក និងគ្រូ ព្រោះចង់ដឹងពីការសិក្សារបស់កូនខ្ញុំបានញឹកញាប់ណាស់ | ២.៩១ | ០.៩១ | មធ្យម |
| ២ | ខ្ញុំបានទទួលសៀវភៅតាមដានការសិក្សារបស់កូនពីសាលារៀនជារៀងរាល់ខែ គឺពិតមានសារៈសំខាន់ណាស់សម្រាប់ពួកខ្ញុំ | ៤.០០ | ០.៩៧ | ល្អ |
| ៣ | លោកគ្រូ អ្នកគ្រូ តែងតែទំនាក់ទំនងមកខ្ញុំជារៀងរាល់ខែ | ៣.០៣ | ១.១៤ | មធ្យម |

| | | | | |
|---|---|---|---|---|
| ៤ | នាយកសាលារៀនទាក់ទងជាមួយខ្ញុំ ដើម្បីផ្តល់ព័ត៌មានអំពីការរីកចម្រើន ឬភាពអវិជ្ជមាន ចំពោះការសិក្សារបស់កូនៗ | ៣.០៨ | ១.១៤ | មធ្យម |
| ៥ | ខ្ញុំគិតថា កម្មវិធីសិក្សារបស់សាលារៀន មានសារៈសំខាន់ណាស់ចំពោះកូនៗ | ៤.២៥ | ០.៦៧ | ល្អណាស់ |
| ៦ | វាជារឿងត្រឹមត្រូវណាស់សម្រាប់សាលារៀន ដែលបានដោះស្រាយរាល់បញ្ហាផ្សេងៗ ដែលទាក់ទងជាមួយនិងកូនខ្ញុំ | ៣.៨០ | ០.៩២ | ល្អ |
| ៧ | ខ្ញុំយល់ថាការដាក់ពិន្ទុក្នុងសៀវភៅតាមដានការសិក្សា មានលក្ខណៈយុត្តិធម៌ និងមានតម្លាភាព | ៣.៨៧ | ០.៨៩ | ល្អ |
| ៨ | ខ្ញុំគិតថាល្អ បើខ្ញុំទៅតាមដានកូនដល់សាលារៀន ដោយផ្ទាល់ជាប្រចាំនោះ | ៣.០១ | ១.១៨ | មធ្យម |
| ៩ | ខ្ញុំប្រើទូរស័ព្ទ ដើម្បីខលទាក់ទងទៅសាលា សួរនាំពីបញ្ហាកូន វាជាជំរើសដ៏ល្អបំផុត | ៣.៣០ | ១.០៩ | មធ្យម |
| ១០ | មុនពេលកូនទៅសាលារៀន ខ្ញុំបានជួយរំលឹកកូន ឲ្យមើលមេរៀន ឬអានសៀវភៅផងដែរ | ៣.៨២ | ១.០៣ | ល្អ |
| **សរុប** | | **៣.៥១** | **០.៦២** | **ល្អ** |

តារាងខាងលើនេះ បានបង្ហាញពីការរួមចំណែកពីមាតាបិតានៅសាលារៀន សរុបគឺ ស្ថិតក្នុងកម្រិត (ល្អ) (**M = ៣.៥១, S.D = ០.៦២**)។

លទ្ធផលខាងលើបង្ហាញថា សូចនាករដែលមានលំដាប់មធ្យមភាគខ្ពស់ជាងគេ គឺចំណុចទី៥ «ឪពុកម្តាយសិស្ស គិតថា កម្មវិធីសិក្សារបស់សាលារៀន មានសារៈសំខាន់ណាស់ចំពោះកូនៗ» ស្ថិតក្នុងកម្រិត ល្អណាស់ (**M = ៤.២៥ , S.D = ០.៦៧**)។ ចំពោះសូចនាករដែលមានលំដាប់មធ្យមភាគទាបជាងគេ គឺចំណុចទី១ «ឪពុកម្តាយសិស្ស ឧស្សាហ៍ទៅសាលារៀនដើម្បីជួប នាយក និងគ្រូ ព្រោះចង់ដឹងពីការសិក្សារបស់កូនខ្ញុំបានញឹកញាប់ណាស់» ស្ថិតក្នុងកម្រិត មធ្យម(**M = ២.៩១ , S.D = ០.៩១**)។

ការរួមចំណែកពីមាតាបិតានៅសាលារៀន គឺមានសូចនាករទាំងអស់ចំនួន១០ ដែលការជ្រើសរើសចម្លើយ របស់ឪពុកម្តាយសិស្សជាក់ស្តែង មានដូចជា៖ កម្រិតល្អណាស់មានចំនួន១ កម្រិតល្អមានចំនួន៤

និងកម្រិតមធ្យមមានចំនួន៥។ យោងតាមលទ្ធផលនេះបានបង្ហាញឲ្យយើងឃើញថា ការរួមចំណែកពីមាតាបិតានៅសាលារៀន គឺមានភាពល្អប្រសើរខ្លះ តែក៏នៅមានភាពមិនប្រាកដប្រជា ពីឪពុក ម្ដាយសិស្សផងដែរ។

**តារាងទី៤.៣៖ តម្លៃមធ្យម គម្លាតស្តង់ដា កម្រិតចង្អុលបង្ហាញ ឥទ្ធិពលនៃការចូលរួមរបស់មាតាបិតាលើសមិទ្ធផលការសិក្សា តាមចំណុចនីមួយៗ (N=៦២)**

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | កូនខ្ញុំប្រែប្រួលឥរិយាបថពីការមិនមើលសៀវភៅ ទៅជាការចូលចិត្តអានសៀវភៅបានជាប្រចាំ | ៣.៧៥ | ០.៨៩ | ល្អ |
| ២ | ខ្ញុំបានជួយជំរុញ និងត្រួតពិនិត្យកិច្ចការផ្ទះជាមួយកូនរបស់ខ្ញុំ បានញឹកញាប់ណាស់ | ៣.៥៤ | ១.០៩ | ល្អ |
| ៣ | កូនមានភាពក្លាហានក្នុងការសួរគ្រូ ឬឆ្លើយសំណួរ និងឡើងដោះស្រាយលំហាត់បានល្អ | ៣.៧៤ | ០.៩០ | ល្អ |
| ៤ | ខ្ញុំរំពឹងថា លទ្ធផលការសិក្សារបស់កូន លើមុខវិជ្ជានីមួយៗ បានពិន្ទុចាប់ពី៥០%ឡើង | ៣.៧៩ | ០.៨៨ | ល្អ |
| ៥ | កូនខ្ញុំអាចបែងចែកពេលវេលារៀនសូត្រនៅផ្ទះ និងសម្រាកដោយខ្លួនឯងបាន | ៣.៥៦ | ០.៨៩ | ល្អ |
| ៦ | ខ្ញុំបានដាស់តឿនកូន ឲ្យពិនិត្យ និងអនុវត្តលើកិច្ចការផ្ទះ ជាប្រចាំ | ៣.៩១ | ០.៨៣ | ល្អ |
| ៧ | ខ្ញុំដាស់តឿនឲ្យកូនខិតខំរៀន និងស្រាវជ្រាវលើមុខវិជ្ជាណាដែលរៀនខ្សោយជាងគេ | ៤.០៦ | ០.៦២ | ល្អ |

| | | | | |
|---|---|---|---|---|
| ៨ | ខ្ញុំបានផ្តល់សៀវភៅផ្សេងៗ ឬទស្សនាវដ្ដីនានា សម្រាប់ឲ្យកូនអាន ដើម្បីកាត់បន្ថយការលេងទូរស័ព្ទ | ៣.៤៥ | ១.០៨ | ល្អ |
| ៩ | ខ្ញុំគ្រប់គ្រងពេលវេលាក្នុងការមើលទូរទស្សន៍ និងការលេងហ្គេម ឬលេងស្មាតហ្វូនរបស់កូន បានទៀងទាត់ល្អណាស់ | ៣.៣៨ | ១.០៩ | មធ្យម |
| ១០ | ខ្ញុំតែងតែត្រួតពិនិត្យកិច្ចការពីសាលារបស់កូនបានញឹកញាប់ណាស់ | ៣.៤០ | ១.០១ | មធ្យម |
| ១១ | ខ្ញុំតាមដានលើការសិក្សារបស់កូន តាមរយៈសៀវភៅតាមដានការសិក្សាជារៀងរាល់ខែ | ៣.៩៣ | ០.៩០ | ល្អ |
| **សរុប** | | **៣.៦៨** | **០.៥៤** | **ល្អ** |

តារាងខាងលើនេះ បានបង្ហាញពីឥទ្ធិពលនៃការចូលរួមរបស់មាតាបិតាលើសមិទ្ធផលការសិក្សាសរុបគឺ ស្ថិតក្នុងកម្រិត(**ល្អ**) (**M = ៣.៦៨, S.D = ០.៥៤**)។

លទ្ធផលខាងលើបង្ហាញថា សូចនាករដែលមានលំដាប់មធ្យមភាគខ្ពស់ជាងគេ គឺចំណុចទី៧ «ឪពុកម្ដាយសិស្ស ដាស់តឿនឲ្យកូនខិតខំរៀន និងស្រាវជ្រាវលើមុខវិជ្ជាណាដែលរៀនខ្សោយជាងគេ» ស្ថិតក្នុងកម្រិត ល្អ (**M = ៤.០៦, S.D = ០.៦២**)។ ចំពោះសូចនាករដែលមានលំដាប់មធ្យមភាគទាបជាងគេ គឺចំណុចទី៩ «ឪពុកម្ដាយសិស្ស គ្រប់គ្រងពេលវេលាក្នុងការមើលទូរទស្សន៍ និងការលេងហ្គេម ឬលេងស្មាតហ្វូនរបស់កូន បានទៀងទាត់ល្អណាស់» ស្ថិតក្នុងកម្រិត មធ្យម (**M = ៣.៣៨, S.D = ១.០៩**)។

ឥទ្ធិពលនៃការចូលរួមរបស់មាតាបិតាលើសមិទ្ធផលការសិក្សា អ្នកស្រាវជ្រាវបានបែងចែកជា១១ សូចនាករ។ លទ្ធផលបានបង្ហាញថា កម្រិតល្អមានចំនួន៩ និង កម្រិតមធ្យមមានចំនួន២។ ក្រៅពីនេះ ឪពុកម្ដាយសិស្សមិនបានជ្រើសរើសនោះទេ។ បើផ្អែកលើលទ្ធផលខាងលើនេះ យើងឃើញថា ឥទ្ធិពលនៃការចូលរួម

របស់មាតាបិតាលើសមិទ្ធផលការសិក្សា អាចទទួលយកបានក្នុងកម្រិតខ្ពស់ ពីព្រោះឪពុកម្ដាយសិស្ស យល់ពីតម្លៃនៃការអប់រំ និងការសិក្សារបស់កូនគាត់បានច្បាស់លាស់។

**តារាងទី៤.៤៖ តម្លៃមធ្យម គម្លាតស្តង់ដា កម្រិតចង្អុលបង្ហាញ ការទំនាក់ទំនងរវាងមាតាបិតា ការចូលរួម និងការលើកទឹកចិត្តសិស្ស តាមចំណុចនីមួយៗ (N=៦២)**

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ខ្ញុំផ្ដល់ជំបូន្មានល្អៗ និងលើកទឹកចិត្តដល់កូនដើម្បីឲ្យកូនមានអាកប្បកិរិយាថ្លៃថ្នូរនិងមានការផ្លាស់ប្តូរទម្លាប់មិនល្អចេញ | ៤.២៧ | ០.៦៣ | ល្អណាស់ |
| ២ | ខ្ញុំលើកទឹកចិត្តកូន ឲ្យចេះធ្វើបុណ្យទាន ដើម្បីឲ្យគាត់ក្លាយជាពលរដ្ឋល្អ មានសីលធម៌ល្អ ក្នុងសង្គម | ៤.២៥ | ០.៧២ | ល្អណាស់ |
| ៣ | ខ្ញុំតែងតែអប់រំកូនឲ្យចេះ ស្រឡាញ់មិត្តភក្តិ ចេះជួយយកអាសារគ្នាទៅវិញទៅមក | ៤.៣៥ | ០.៤៨ | ល្អណាស់ |
| ៤ | ខ្ញុំអប់រំកូន ឲ្យចេះសាមគ្គីគ្នាជាមួយបងប្អូនស្រឡាញ់ឪពុកម្តាយ សាច់ញាតិជិតឆ្ងាយបានល្អ | ៤.៤៣ | ០.៥៣ | ល្អណាស់ |
| ៥ | ខ្ញុំ អប់រំកូន មិនត្រូវរើសអើងគ្នា ឲ្យចេះរស់នៅក្នុងសង្គមប្រកបដោយសុខដុមរមនា | ៤.២៧ | ០.៦៥ | ល្អណាស់ |
| ៦ | ខ្ញុំ អប់រំកូនឲ្យចេះចែករំលែក និងជួយទុក្ខធុរៈ ចំពោះមិត្តភក្តិ ក៏ដូចជាមនុស្សផងទាំងឡាយទាំងពួង | ៤.១៧ | ០.៦៦ | ល្អ |
| ៧ | ខ្ញុំអប់រំកូន ឲ្យមានគំនិតជឿនលឿន ដោយចេះវិវត្តន៍ខ្លួន បត់បែនទៅតាមបរិបទនៃសង្គមភាវូបនីយកម្ម | ៤.០៩ | ០.៨២ | ល្អ |

| | | | |
|---|---|---|---|
| សរុប | ៤.២៦ | ០.៤៨ | ល្អណាស់ |

តារាងខាងលើនេះ បានបង្ហាញពីការទំនាក់ទំនងរវាងមាតាបិតា ការចូលរួម និងការលើកទឹកចិត្តសិស្ស សរុបគឺ ស្ថិតក្នុងកម្រិត(**ល្អណាស់**) (**M = ៤.២៦, S.D = ០.៤៨**)។

លទ្ធផលខាងលើបង្ហាញថា សូចនាករដែលមានលំដាប់មធ្យមភាគខ្ពស់ជាងគេ គឺចំណុចទី៤ «ឪពុកម្តាយសិស្ស អប់រំកូន ឲ្យចេះសាមគ្គីគ្នាជាមួយបងប្អូន ស្រឡាញ់ឪពុកម្តាយ សាច់ញាតិជិតឆ្ងាយបានល្អ» ស្ថិតក្នុងកម្រិត ល្អណាស់(**M = ៤.៤៣, S.D = ០.៥៣**)។ ចំពោះសូចនាករដែលមានលំដាប់មធ្យមភាគទាបជាងគេ គឺចំណុចទី៧ «ឪពុកម្តាយសិស្ស អប់រំកូន ឲ្យមានគំនិតជឿនលឿន ដោយចេះវិវត្តន៍ខ្លួន បត់បែនទៅតាមបរិបទនៃសង្គមការូបនីយកម្ម» ស្ថិតក្នុងកម្រិត ល្អ (**M = ៤.០៩, S.D = ០.៨២**)។

ការទំនាក់ទំនងរវាងមាតាបិតា ការចូលរួម និងការលើកទឹកចិត្តសិស្ស បានបែងចែកជា៧សូចនាករ។ ឪពុកម្តាយសិស្សបានជ្រើសរើស នូវកម្រិតចម្លើយនីមួយៗដូចតទៅ៖ កម្រិតល្អណាស់មានចំនួន៥ និងកម្រិតល្អមានចំនួន២។ នេះបង្ហាញឲ្យឃើញថា ការទំនាក់ទំនងរវាងមាតាបិតា ការចូលរួម និងការលើកទឹកចិត្តសិស្ស ឪពុកម្តាយភាគច្រើនបានទំនាក់ទំនង ក៏ដូចជាការលើកទឹកចិត្តឲ្យកូនខិតខំរៀនសូត្រឲ្យបានពិន្ទុខ្ពស់ និងឡើងថ្នាក់ជាបន្តបន្ទាប់។

**តារាងទី៤.៥៖ តម្លៃមធ្យម គម្លាតស្តង់ដា កម្រិតចង្អុលបង្ហាញ ការចូលរួមចំណែកលើការអប់រំកូន និងការទទួលខុសត្រូវរបស់មាតាបិតា តាមចំណុចនីមួយៗ (N = ៦២)**

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ការទទួលខុសត្រូវរបស់ខ្ញុំជាឪពុកម្តាយ គឺចង់ឲ្យកូនរៀនបានចប់នៅកម្រិតវិទ្យាល័យ និងបន្តដល់មហាវិទ្យាល័យ | ៤.៣៥ | ០.៧៧ | ល្អណាស់ |
| ២ | ទោះបីជាសាលារៀនបានជួយ និងយកចិត្ត | ៤.២៩ | ០.៦៣ | ល្អណាស់ |

| | | | | |
|---|---|---|---|---|
| | ទុកដាក់ចំពោះកូនខ្ញុំយ៉ាងណាក៏ដោយ ក៏ខ្ញុំនៅតែបង្កើនការយកចិត្តទុកដាក់ដល់រូបគេជាដរាប | | | |
| ៣ | ទោះបីជាខ្ញុំមានការមមាញឹករវល់នឹងការងារយ៉ាងណា ក៏ខ្ញុំឆ្លៀតពេលតាមដាន និងពិនិត្យលើការសិក្សារបស់កូនដែរ | ៤.០៩ | ០.៨៤ | ល្អ |
| ៤ | ខ្ញុំប្រើមធ្យោបាយជាច្រើន ដើម្បីឲ្យកូនទទួលជោគជ័យក្នុងការសិក្សា ដូចជា ឲ្យកូនរៀនគួរនៅខាងក្រៅ ឬសាលាឯកជនដទៃទៀត | ៤.២៥ | ០.៧៨ | ល្អណាស់ |
| **សរុប** | | **៤.២៥** | **០.៥៩** | **ល្អ** |

តារាងខាងលើនេះ បានបង្ហាញពីការចូលរួមចំណែកលើការអប់រំកូន និងការទទួលខុសត្រូវរបស់មាតាបិតា សរុបគឺ ស្ថិតក្នុងកម្រិត(**ល្អណាស់**) (**M = ៤.២៥, S.D = ០.៥៩**)។

លទ្ធផលខាងលើបង្ហាញថា សូចនាករដែលមានលំដាប់មធ្យមភាគខ្ពស់ជាងគេ គឺចំណុចទី១ «ការទទួលខុសត្រូវរបស់ខ្ញុំជាឪពុកម្តាយ គឺចង់ឲ្យកូនរៀនបានចប់នៅកម្រិតវិទ្យាល័យ និងបន្តដល់មហាវិទ្យាល័យ» ស្ថិតក្នុងកម្រិត ល្អណាស់(**M = ៤.៣៥, S.D = ០.៧៧**)។ ចំពោះសូចនាករដែលមានលំដាប់មធ្យមភាគទាបជាងគេ គឺចំណុចទី៣ «ទោះបីជាឪពុកម្តាយសិស្ស មានការមមាញឹករវល់នឹងការងារយ៉ាងណា ក៏គាត់ឆ្លៀតពេលតាមដាន និងពិនិត្យលើការសិក្សារបស់កូនដែរ» ស្ថិតក្នុងកម្រិត ល្អ (**M = ៤.០៩, S.D = ០.៨៤**)។

ការចូលរួមចំណែកលើការអប់រំកូន និងការទទួលខុសត្រូវរបស់មាតាបិតា មានចំនួន៤សូចនាករ។ លទ្ធផលបានពីការស្រាវជ្រាវនោះគឺ កម្រិតល្អណាស់មានចំនួន៣ និងកម្រិតល្អមានចំនួន១។ លទ្ធផលនេះ អ្នកស្រាវជ្រាវយល់ឃើញថា ការចូលរួមចំណែកលើការអប់រំកូន និងការទទួលខុសត្រូវរបស់មាតាបិតាឪពុកម្តាយសិស្សភាគច្រើនគឺ យល់ដឹងពីតួនាទីរបស់ខ្លួន និងការទទួលខុសត្រូវ ចំពោះជោគវាសនាកូនរបស់ពួកគាត់បានល្អប្រសើរខ្លាំងណាស់។

**តារាងទី៤.៦៖ សរុបលទ្ធផលរួម ការចូលរួមឆ្លើយរបស់មាតាបិតា៖ (N=៦២)**

| ល.រ | សូចនាករតាមផ្នែកនីមួយៗ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|---|
| ១ | ២.១-២.៩ | ដំណើរការចំពោះតួនាទីក្នុងការចូលរួមចំណែកអប់រំកូនរបស់មាតាបិតា | ៣.៧៧ | ០.៥៥ | ល្អ |
| ២ | ២.១០-២.១៩ | ការរួមចំណែកពីមាតាបិតានៅសាលារៀន | ៣.៥១ | ០.៦២ | ល្អ |
| ៣ | ២.២០-២.៣០ | ឥទ្ធិពលនៃការចូលរួមរបស់មាតាបិតាលើសមិទ្ធផលការសិក្សា | ៣.៦៨ | ០.៥៤ | ល្អ |
| ៤ | ២.៣១-២.៣៧ | ការទំនាក់ទំនងរវាងមាតាបិតា ការចូលរួម និងការលើកទឹកចិត្តសិស្ស | ៤.២៦ | ០.៤៨ | ល្អ |
| ៥ | ២.៣៨-២.៤១ | ការចូលរួមចំណែកលើការអប់រំកូន និងការទទួលខុសត្រូវរបស់មាតាបិតា | ៤.២៥ | ០.៥៩ | ល្អណាស់ |
| **សរុប** | | | **៣.៨៩** | **០.៤៦** | **ល្អ** |

នៅក្នុងផ្នែកទី២ នៃកម្រងសំណួរសម្រាប់មាតាបិតា ដែលបាននិយាយពីទស្សនៈរបស់មាតាបិតាលើតួនាទី ក្នុងការចូលរួម និងការសិក្សារបស់កូន គឺពិតជាអាចទទួលយកជាការបាន ពីព្រោះយោងតាមលទ្ធផលសរុប ស្ថិតក្នុងកម្រិតល្អ (**M = ៣.៨៩, S.D = ០.៤៦**)។ បើតាមការពិនិត្យមើលគ្រប់ចំណាងជើងរងទាំង៥ចំណុច យើងទាញបានលទ្ធផលដូចតទៅ៖ លទ្ធផលខាងលើបង្ហាញថា សូចនាករដែលមានលំដាប់មធ្យមភាគខ្ពស់ជាងគេ គឺចំណុចទី៤ «ការទំនាក់ទំនងរវាងមាតាបិតា ការចូលរួម និងការលើកទឹកចិត្តសិស្ស» ស្ថិតក្នុងកម្រិត ល្អណាស់(**M = ៤.២៦, S.D = ០.៤៨**)។ ចំពោះសូចនាករដែលមានលំដាប់មធ្យមភាគទាបជាងគេ គឺចំណុចទី២ «ការរួមចំណែកពីមាតាបិតានៅសាលារៀន» ស្ថិតក្នុងកម្រិត ល្អ (**M = ៣.៥១, S.D = ០.៦២**)។

លទ្ធផលនៃកម្រងសំណួរសម្រាប់គ្រូ

តារាងទី៤.៧៖ តម្លៃមធ្យម គម្លាតស្តង់ដា កម្រិតចង្អុលបង្ហាញ ដំណើរការចូលរួមចំណែកអប់រំកូនរបស់មាតាបិតា តាមចំណុចនីមួយៗ (N=៣៧)

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ខ្ញុំយល់ឃើញថា ឪពុកម្តាយសិស្សបានចូលរួមជួយកូនច្រើន ក្នុងការសិក្សារបស់ពួកគេ | ៣.៥១ | ១.០៧ | ល្អ |
| ២ | ខ្ញុំតែងតែពិភាក្សាជាមួយឪពុកម្តាយសិស្ស អំពីការសិក្សារបស់កូន | ៣.២៩ | ០.៩៩ | មធ្យម |
| ៣ | ខ្ញុំជឿជាក់ថាឪពុកម្តាយ យល់ដឹងបានច្រើន អំពីសារៈសំខាន់នៃការសិក្សារបស់កូន | ៣.៩៧ | ០.៨៣ | ល្អ |
| ៤ | សិស្សចូលរៀនបានទៀងទាត់ និងទាន់ពេលវេលា គឺពិតជាមានការជំរុញពីឪពុកម្តាយជាប្រចាំ | ៣.៨៣ | ០.៩៨ | ល្អ |
| ៥ | ខ្ញុំតែងតែ ដាក់កិច្ចការឲ្យសិស្សយកទៅធ្វើនៅផ្ទះ និងបានផ្តាំផ្ញើឲ្យឪពុកម្តាយ ជួយកូនតាមភាពជាក់ស្តែងបានញឹកញាប់ណាស់ | ៣.៧២ | ០.៩៦ | ល្អ |
| ៦ | មានឪពុកម្តាយសិស្សមួយចំនួន តែងតែសួរខ្ញុំ អំពីផលលំបាក ឬឧបសគ្គ នៅពេលដែលកូនធ្វើដំណើរទៅសាលា និងពេលត្រឡប់មកផ្ទះវិញ | ៣.០៥ | ១.០២ | មធ្យម |
| ៧ | ឪពុកម្តាយសិស្ស ចំណាយពេលជូនកូនទៅសាលា និងចាំទៅទទួលមកផ្ទះវិញជាប្រចាំ | ២.៨៩ | ១.១៤ | មធ្យម |
| ៨ | ឪពុកម្តាយសិស្ស បានចូលរួមជួយកូន ចំពោះការសិក្សារបស់គេ លើគ្រប់មុខវិជ្ជា | ៣.០០ | ១.០៨ | មធ្យម |
| ៩ | ឪពុកម្តាយសិស្ស យល់ថា ការគ្រប់គ្រងពេលវេលាក្នុងការមើលទូរទស្សន៍ ការលេងហ្គេម ឬលេងស្មាតហ្វូនរបស់កូនពិតជាមានសារៈសំខាន់ណាស់ | ៣.៥៩ | ១.១៤ | ល្អ |
| **សរុប** | | **៣.៤៣** | **០.៦២** | **ល្អ** |

តារាងខាងលើនេះ បានបង្ហាញពីដំណើរការចំពោះតួនាទីក្នុងការចូលរួមចំណែកអប់រំកូនរបស់មាតាបិតា សរុបគឺ ស្ថិតក្នុងកម្រិត(**ល្អ**) (**M = ៣.៤៣, S.D = ០.៦២**)។

លទ្ធផលខាងលើបង្ហាញថា សូចនាករដែលមានលំដាប់មធ្យមភាគខ្ពស់ជាងគេ គឺចំណុចទី៣ «លោកគ្រូ អ្នកគ្រូ ជឿជាក់ថាឪពុកម្ដាយសិស្ស យល់ដឹងបានច្រើន អំពីសារៈសំខាន់នៃការសិក្សារបស់កូន» ស្ថិតក្នុងកម្រិត ល្អ(**M = ៣.៩៧ , S.D = ០.៨៣**)។ ចំពោះសូចនាករដែលមានលំដាប់មធ្យមភាគទាបជាងគេ គឺចំណុចទី៧ «ឪពុកម្ដាយសិស្ស ចំណាយពេលជូនកូនទៅសាលា និងចាំទៅទទួលមកផ្ទះវិញជាប្រចាំ» ស្ថិតក្នុងកម្រិតមធ្យម(**M = ២.៨៩ , S.D = ១.១៤**)។

ដំណើរការចំពោះតួនាទីក្នុងការចូលរួមចំណែកអប់រំកូនរបស់មាតាបិតា មានសរុបសូចនាករទាំងអស់ចំនួន៩ចំណុច ក្នុងនោះដែរតាមការឆ្លើយរបស់លោកគ្រូ អ្នកគ្រូ ទាំង៣៧នាក់ បានង្ហាញថា កម្រិតល្អមានចំនួន៥ និងកម្រិតមធ្យមចំនួន៤ ក្រៅពីនោះលោកគ្រូ អ្នកគ្រូ មិនបានជ្រើសរើសចម្លើយនោះទេ។ មានន័យថាដំណើរការចំពោះតួនាទីក្នុងការចូលរួមចំណែកអប់រំកូនរបស់មាតាបិតា ពិតជាមានការយកចិត្តដាក់ខ្ពស់ពីសំណាក់មាតាបិតាសិស្ស ក្នុងការបំពេញតួនាទីរបស់ខ្លួន នេះតាមការយល់ឃើញរបស់លោកគ្រូ អ្នកគ្រូទាំង៥សាលាគោលដៅពិតប្រាកដមែន។

**តារាងទី៤.៨៖ តម្លៃមធ្យម គម្លាតស្តង់ដា កម្រិតចង្អុលបង្ហាញ ការរួមចំណែកពីមាតាបិតានៅសាលារៀន តាមចំណុចនីមួយៗ (N=៣៧)**

| **ល.រ** | **បរិយាយ** | **មធ្យម** | **គម្លាតស្តង់ដា** | **កម្រិតចង្អុលបង្ហាញ** |
|---|---|---|---|---|
| ១ | ឪពុកម្តាយសិស្ស ឧស្សាហ៍ទៅសាលារៀនដើម្បីជួបនាយក និងគ្រូ ព្រោះគាត់ចង់ដឹងពីការសិក្សារបស់កូន | ៣.២១ | ១.០៨ | មធ្យម |
| ២ | ឪពុកម្តាយសិស្ស យល់ថាការទទួលសៀវភៅតាមដានការសិក្សារបស់កូនពីសាលារៀនជារៀងរាល់ខែមានសារៈសំខាន់ណាស់ | ៤.១៨ | ០.៨១ | ល្អ |
| ៣ | ឪពុកម្តាយសិស្សគិតថា កម្មវិធីសិក្សារបស់សាលារៀន | ៤.០២ | ០.៧៩ | ល្អ |

| | | | | |
|---|---|---|---|---|
| | មានសារៈសំខាន់ណាស់ចំពោះការសិក្សារបស់កូនៗ | | | |
| ៤ | ឪពុកម្តាយសិស្ស បានចូលរួមជាមួយគណៈគ្រប់គ្រងសាលា ចំពោះការដោះស្រាយរាល់បញ្ហាផ្សេងៗ ដែលទាក់ទងជាមួយនិងកូនគាត់បានទាន់ពេលវេលា | ៣.៨១ | ០.៨៧ | ល្អ |
| ៥ | ឪពុកម្តាយសិស្សយល់ថា ការដាក់ពិន្ទុក្នុងសៀវភៅតាមដានការសិក្សា មានលក្ខណៈយុត្តិធម៌និងមានតម្លាភាព | ៣.៧៥ | ០.៨៩ | ល្អណាស់ |
| **សរុប** | | **៣.៨០** | **០.៦១** | **ល្អ** |

តារាងខាងលើនេះ បានបង្ហាញពីការរួមចំណែកពីមាតាបិតានៅសាលារៀន សរុបគឺ ស្ថិតក្នុងកម្រិត **(ល្អ) (M = ៣.៨០, S.D = ០.៦១)**។

លទ្ធផលខាងលើបង្ហាញថា សូចនាករដែលមានលំដាប់មធ្យមភាគខ្ពស់ជាងគេ គឺចំណុចទី២ «ឪពុកម្តាយសិស្ស យល់ថាការទទួលសៀវភៅតាមដានការសិក្សារបស់កូនពីសាលារៀនជារៀងរាល់ខែមានសារៈសំខាន់ណាស់» ស្ថិតក្នុងកម្រិត ល្អ**(M = ៤.១៨ , S.D = ០.៨១)**។ ចំពោះសូចនាករដែលមានលំដាប់មធ្យមភាគទាបជាងគេ គឺចំណុចទី១ «ឪពុកម្តាយសិស្ស ឧស្សាហ៍ទៅសាលារៀនដើម្បីជួប នាយក និងគ្រូ ព្រោះគាត់ចង់ដឹងពីការសិក្សារបស់កូន» ស្ថិតក្នុងកម្រិត មធ្យម **(M = ៣.២១, S.D = ១.០៨)**។

ការរួមចំណែកពីមាតាបិតានៅសាលារៀន មានសូចនាករសរុបចំនួន៥ ក្នុងនោះ កម្រិតល្អណាស់មានចំនួន១ កម្រិតល្អមានចំនួន៣ និងកម្រិតមធ្យមមានចំនួន១ ក្រៅពីនោះលោកគ្រូ អ្នកគ្រូមិនបានជ្រើសរើស និងបំពេញចម្លើយនោះទេ។ លទ្ធផលបានបង្ហាញថា ការរួមចំណែកពីមាតាបិតានៅសាលារៀនឃើញថាអាចទទួលយកបានពីសំណាក់មាតាបិតា ដែលបានគិតគូរ និងយកចិត្តទុកដាក់ជាមួយសាលារៀនដើម្បីការសិក្សារបស់កូន ឲ្យទទួលបាននូវលទ្ធផលល្អប្រសើរ។ កម្រិតមធ្យម គឺឪពុកម្តាយសិស្សឧស្សាហ៍ទៅសាលារៀនដើម្បីជួប នាយក និងគ្រូ ព្រោះគាត់ចង់ដឹងពីការសិក្សារបស់កូន ក្នុងករណីនេះលោកគ្រូ អ្នកគ្រូយល់ឃើញថា មានឪពុកម្តាយសិស្សមួយចំនួនតិចតែប៉ុណ្ណោះដែលមិនសូវមានពេលវេលាដើម្បីទៅសាលា ដើម្បីជួប នាយក ឬគ្រូបង្រៀន។

តារាងទី៤.៩៖ តម្លៃមធ្យម គម្លាតស្តង់ដា កម្រិតចង្អុលបង្ហាញ  ឥទ្ធិពលនៃការចូលរួមរបស់មាតាបិតាលើសមិទ្ធផលការសិក្សា តាមចំណុចនីមួយៗ (N=៣៧)

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | បន្ទាប់ពីមានការចូលរួមរបស់ឪពុកម្តាយមក ធ្វើឲ្យកូនមានការប្រែប្រួលឥរិយាបថពីការមិនមើលសៀវភៅ ទៅជាការចូលចិត្តអានសៀវភៅបានជាប្រចាំ | ៣.៨១ | ១.០២ | ល្អ |
| ២ | ឪពុកម្តាយសិស្សជួយជំរុញ និងត្រួតពិនិត្យកិច្ចការផ្ទះជាមួយកូន បានញឹកញាប់ណាស់ | ៣.១៣ | ០.៩៧ | មធ្យម |
| ៣ | កូនសិស្សមានភាពក្លាហានក្នុងការសួរគ្រូ ឬឆ្លើយសំណួរ និងឡើងដោះស្រាយលំហាត់បានល្អ | ៣.៤៥ | ០.៩៦ | ល្អ |
| ៤ | ឪពុកម្តាយសិស្សរំពឹងថា លទ្ធផលការសិក្សារបស់កូន លើមុខវិជ្ជានីមួយៗ បានពិន្ទុចាប់ពី៥០%ឡើង | ៣.៥៩ | ០.៩២ | ល្អ |
| ៥ | ឪពុកម្តាយសិស្សយល់ឃើញថា កូនរបស់គាត់អាចបែងចែកពេលវេលារៀនសូត្រនៅផ្ទះ និងសម្រាកដោយខ្លួនឯងបាន | ៣.០៥ | ១.០៧ | មធ្យម |
| ៦ | ឪពុកម្តាយសិស្សបានប្រាប់ខ្ញុំឲ្យជួយដាក់កិច្ចការផ្ទះជាប្រចាំដើម្បីឲ្យកូនបានអនុវត្ត | ៣.៣២ | ១.០០ | មធ្យម |
| ៧ | ឪពុកម្តាយសិស្សបានជួយជំរុញឲ្យកូនខិតខំរៀន និងស្រាវជ្រាវលើមុខវិជ្ជាណាដែលរៀនខ្សោយជាងគេ | ៣.៣២ | ១.០២ | មធ្យម |
| ៨ | ឪពុកម្តាយសិស្ស បានផ្តល់សៀវភៅផ្សេងៗ ឬទស្សនាវដ្តីនានា សម្រាប់ឲ្យកូនអាន ដើម្បីកាត់បន្ថយការលេងទូរស័ព្ទ | ៣.១០ | ០.៩៦ | មធ្យម |
| ៩ | ឪពុកម្តាយសិស្ស យល់ថាការគ្រប់គ្រងពេលវេលាក្នុងការមើលទូរទស្សន៍ និងការលេងហ្គេមជាមួយស្មាតហ្វូនរបស់កូន គឺពិតជាល្អណាស់ | ៣.៦២ | ០.៨៩ | ល្អ |
| ១០ | ឪពុកម្តាយសិស្ស បានប្រាប់ខ្ញុំថា ពួកគាត់តែងតែត្រួតពិនិត្យកិច្ចការពីសាលារបស់កូនបានញឹកញាប់ណាស់ | ២.៨០ | ១.១២ | មធ្យម |
| ១១ | ឪពុកម្តាយសិស្សបានតាមដានលើការសិក្សារបស់កូន តាមរយៈសៀវភៅតាមដានការសិក្សាជារៀងរាល់ខែ | ៣.៦២ | ១.០៣ | ល្អ |
| | **សរុប** | **៣.៣៥** | **០.៦៦** | **មធ្យម** |

តារាងខាងលើនេះ បានបង្ហាញពីឥទ្ធិពលនៃការចូលរួមរបស់មាតាបិតាលើសមិទ្ធផលការសិក្សាសរុបគឺ ស្ថិតក្នុងកម្រិត(**មធ្យម**) (**M = ៣.៣៥, S.D = ០.៦៦**)។

លទ្ធផលខាងលើបង្ហាញថា សូចនាករដែលមានលំដាប់មធ្យមភាគខ្ពស់ជាងគេ គឺចំណុចទី១ «បន្ទាប់ពីមានការចូលរួមរបស់ឪពុកម្ដាយមក ធ្វើឲ្យកូនមានការប្រែប្រួលឥរិយាបថពីការមិនមើលសៀវភៅ ទៅជាការចូលចិត្តអានសៀវភៅបានជាប្រចាំ» ស្ថិតក្នុងកម្រិត ល្អ (**M = ៣.៨១, S.D = ០.៨៧**)។ ចំពោះសូចនាករដែលមានលំដាប់មធ្យមភាគទាបជាងគេ គឺចំណុចទី១០ «ឪពុកម្តាយសិស្ស បានប្រាប់ខ្ញុំថា ពួកគាត់តែងតែត្រួតពិនិត្យកិច្ចការពីសាលារបស់កូនបានញឹកញាប់ណាស់» ស្ថិតក្នុងកម្រិត មធ្យម (**M = ២.៨៩, S.D = ១.១២**)។

ឥទ្ធិពលនៃការចូលរួមរបស់មាតាបិតាលើសមិទ្ធផលការសិក្សា គឺមានចំនួន១១សូចនាករ លោកគ្រូ អ្នកគ្រូ ទាំង៥សាលាបានជ្រើសរើស និងបំពេញក្នុងកម្រិតចម្លើយនីមួយៗ បានជាលទ្ធផល ដូចតទៅ៖ កម្រិតល្អ មានចំនួន៥ និងកម្រិតមធ្យម មានចំនួន៦ ក្រៅពីនេះ ពួកគាត់មិនបានជ្រើសរើសទេ។ តាមទិន្នន័យនេះ អ្នកស្រាវជ្រាវយល់ឃើញថា ឥទ្ធិពលនៃការចូលរួមរបស់មាតាបិតាលើសមិទ្ធផលការសិក្សា ដូចជានៅមានការខ្វះចន្លោះនៅឡើយ ដោយការជ្រើសរើសភាគច្រើន ស្ថិតក្នុងកម្រិត មធ្យម។ មានន័យថាឥទ្ធិពលនៃការចូលរួមរបស់មាតាបិតា លើសម្មិផលការសិក្សា ហាក់មានភាពស្រពិចស្រពិល។

**តារាងទី៤.១០៖ តម្លៃមធ្យម គម្លាតស្តង់ដា កម្រិតចង្អុលបង្ហាញ ការទំនាក់ទំនងរវាងមាតាបិតា ការចូលរួម និងការលើកទឹកចិត្តសិស្ស តាមចំណុចនីមួយៗ (N = ៣៧)**

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ឪពុកម្តាយសិស្ស ផ្តល់ដំបូន្មានល្អៗ និងលើកទឹកចិត្តដល់កូនដើម្បីឲ្យកូនមានអាកប្បកិរិយាថ្លៃថ្នូរនិងមានការផ្លាស់ប្តូរទម្លាប់មិនល្អ | ៤.០៥ | ០.៧៧ | ល្អ |
| ២ | ឪពុកម្តាយសិស្ស លើកទឹកចិត្តកូន ឲ្យចេះធ្វើបុណ្យទានដើម្បីឲ្យគាត់ក្លាយជាពលរដ្ឋល្អ មានសីលធម៌ល្អ ក្នុង | ៣.៩១ | ០.៩៥ | ល្អ |

| | | | | |
|---|---|---|---|---|
| | សង្គម | | | |
| ៣ | ឪពុកម្តាយសិស្ស តែងតែអប់រំកូនឲ្យចេះ ស្រឡាញ់មិត្តភក្តិ ចេះជួយយកអាសារគ្នាទៅវិញទៅមក | ៤.០៨ | ០.៧៥ | ល្អ |
| ៤ | ឪពុកម្តាយសិស្ស អប់រំកូន ឲ្យចេះសាមគ្គីគ្នាជាមួយបងប្អូន ស្រឡាញ់ឪពុកម្តាយ សាច់ញាតិជិតឆ្ងាយបានល្អ | ៤.១០ | ០.៩០ | ល្អ |
| ៥ | ឪពុកម្តាយសិស្ស អប់រំកូន មិនត្រូវរើសអើងគ្នា ឲ្យចេះរស់នៅក្នុងសង្គមប្រកបដោយសុខដុមរមនា | ៣.៩៤ | ០.៨១ | ល្អ |
| ៦ | ឪពុកម្តាយសិស្ស អប់រំកូនឲ្យចេះចែករំលែក និងជួយទុក្ខធុរៈ ចំពោះមិត្តភក្តិ ក៏ដូចជាមនុស្សផងទាំងពួង | ៤.០២ | ០.៨៦ | ល្អ |
| ៧ | ឪពុកម្តាយសិស្ស អប់រំកូន ឲ្យមានគំនិតជឿនលឿន ដោយចេះវិវត្តន៍ខ្លួន បត់បែនទៅតាមបរិបទនៃសង្គមភាវូបនីយកម្ម | ៣.៧២ | ០.៩៦ | ល្អ |
| **សរុប** | | **៣.៩៨** | **០.៧០** | **ល្អ** |

តារាងខាងលើនេះ បានបង្ហាញពីការទំនាក់ទំនងរវាងមាតាបិតា ការចូលរួម និងការលើកទឹកចិត្តសិស្ស សរុបគឺ ស្ថិតក្នុងកម្រិត(**ល្អ**) (**M = ៣.៩៨, S.D = ០.៧០**)។

លទ្ធផលខាងលើបង្ហាញថា សូចនាករដែលមានលំដាប់មធ្យមភាគខ្ពស់ជាងគេ គឺចំណុចទី៤ «ឪពុកម្តាយសិស្ស អប់រំកូន ឲ្យចេះសាមគ្គីគ្នាជាមួយបងប្អូន ស្រឡាញ់ឪពុកម្តាយ សាច់ញាតិជិតឆ្ងាយបានល្អ» ស្ថិតក្នុងកម្រិត ល្អ (**M = ៤.១០, S.D = ០.៩០**) ចំពោះសូចនាករដែលមានលំដាប់មធ្យមភាគទាបជាងគេ គឺចំណុចទី៧ «ឪពុកម្តាយសិស្ស អប់រំកូន ឲ្យមានគំនិតជឿនលឿន ដោយចេះវិវត្តន៍ខ្លួន បត់បែនទៅតាមបរិបទនៃសង្គមភាវូបនីយកម្ម» ស្ថិតក្នុងកម្រិត ល្អ (**M = ៣.៧២, S.D = ០.៩៦**)។

ការទំនាក់ទំនងរវាងមាតាបិតា ការចូលរួម និងការលើកទឹកចិត្តសិស្ស ចែកចេញជា៧សូចនាករ។ ក្នុងនោះលោកគ្រូ អ្នកគ្រូបានជ្រើសរើសយកចម្លើយ កម្រិតល្អ ទាំង៧សូចនាករតែម្តង។ ដូចនេះ ការទំនាក់ទំនងរវាងមាតាបិតា ការចូលរួម និងការលើកទឹកចិត្តសិស្ស គឺមានភាពល្អប្រសើរ។

**តារាងទី៤.១១៖ តម្លៃមធ្យម គម្លាតស្តង់ដា កម្រិតចង្អុលបង្ហាញ ការចូលរួមចំណែកលើការអប់រំកូន និងការទទួលខុសត្រូវរបស់មាតាបិតា តាមចំណុចនីមួយៗ (N=៣៧)**

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ការទទួលខុសត្រូវរបស់ ឪពុកម្តាយសិស្ស គឺចង់ឲ្យកូនរៀនបានចប់នៅកម្រិតវិទ្យាល័យ និងបន្តដល់មហាវិទ្យាល័យ | ៤.២១ | ០.៧១ | ល្អណាស់ |
| ២ | ឪពុកម្តាយសិស្ស មានបំណងជួបនាយក ឬគ្រូ ជារៀងរាល់ខែ ដើម្បីចង់ដឹងពីការសិក្សារបស់កូន | ៣.១៨ | ០.៩៣ | មធ្យម |
| ៣ | មុនឲ្យកូនទៅសាលា ឪពុកម្តាយសិស្ស បានជួយរំលឹកកូន ដើម្បីបានមើលមេរៀន ឬអានសៀវភៅផ្សេងៗផងដែរ | ៣.២១ | ១.១០ | មធ្យម |
| ៤ | ឪពុកម្តាយសិស្ស ប្រើមធ្យោបាយជាច្រើន ដើម្បីឲ្យកូនទទួលបានជោគជ័យក្នុងការសិក្សា ដូចជា ឲ្យកូនរៀនគួរនៅខាងក្រៅ ឬសាលាឯកជនដទៃទៀត | ៣.៧២ | ១.០៤ | ល្អ |
| **សរុប** | | **៣.៥៨** | **០.៧៦** | **ល្អ** |

តារាងខាងលើនេះ បានបង្ហាញពីការចូលរួមចំណែកលើការអប់រំកូន និងការទទួលខុសត្រូវរបស់មាតាបិតា សរុបគឺ ស្ថិតក្នុងកម្រិត(**ល្អ**) (**M = ៣.៥៨, S.D = ០.៧៦**)។

លទ្ធផលខាងលើបង្ហាញថា សូចនាករដែលមានលំដាប់មធ្យមភាគខ្ពស់ជាងគេ គឺចំណុចទី១ «ការទទួលខុសត្រូវរបស់ ឪពុកម្តាយសិស្ស គឺចង់ឲ្យកូនរៀនបានចប់នៅកម្រិតវិទ្យាល័យ និងបន្តដល់មហាវិទ្យាល័យ» ស្ថិតក្នុងកម្រិត ល្អណាស់ (**M = ៤.២១, S.D = ០.៧១**)។ ចំពោះសូចនាករដែលមានលំដាប់មធ្យមភាគទាបជាងគេ គឺចំណុចទី២ «ឪពុកម្តាយសិស្ស មានបំណងជួបនាយក ឬគ្រូ ជារៀងរាល់ខែ ដើម្បីចង់ដឹងពីការសិក្សារបស់កូន» ស្ថិតក្នុងកម្រិត មធ្យម (**M = ៣.១៨, S.D = ០.៩៣**)។

ការចូលរួមចំណែកលើការអប់រំកូន និងការទទួលខុសត្រូវរបស់មាតាបិតា បានបែងចែកត្រឹមតែ៤សូចនាករតែប៉ុណ្ណោះ ក្នុងនោះមានកម្រិតយល់ស្របទាំងស្រុងចំនួន១ កម្រិតល្អ មានចំនួន១ និងកម្រិតមធ្យម ចំនួន២។ ផ្អែកតាមលទ្ធផលនៃការស្រាវជ្រាវ ការចូលរួមចំណែកលើការអប់រំកូន និងការទទួលខុសត្រូវរបស់មាតាបិតា គឺនៅមិនទាន់បានល្អ១០០% នោះឡើយ។

**តារាងទី៤.១២៖ សរុបលទ្ធផលរួម ការចូលរួមឆ្លើយរបស់លោកគ្រូ អ្នកគ្រូ៖ (N= ៣៧)**

| ល.រ | សូចនាករតាមផ្នែកនីមួយៗ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|---|
| ១ | ២.១-២.៩ | ដំណើរការចូលរួមចំណែកអប់រំកូនរបស់មាតាបិតា | ៣.៤៣ | ០.៦២ | ល្អ |
| ២ | ២.១០-២.១៤ | ការរួមចំណែកពីមាតាបិតានៅសាលារៀន | ៣.៨០ | ០.៦១ | ល្អ |
| ៣ | ២.១៥-២.២៥ | ឥទ្ធិពលនៃការចូលរួមរបស់មាតាបិតាលើសមិទ្ធផលការសិក្សា | ៣.៣៥ | ០.៦៦ | មធ្យម |
| ៤ | ២.២៦-២.៣២ | ការទំនាក់ទំនងរវាងមាតាបិតា ការចូលរួម និងការលើកទឹកចិត្តសិស្ស | ៣.៩៨ | ០.៧០ | ល្អ |
| ៥ | ២.៣៣-២.៣៦ | ការចូលរួមចំណែកលើការអប់រំកូន និងការទទួលខុសត្រូវរបស់មាតាបិតា | ៣.៥៨ | ០.៧៦ | ល្អ |
| **សរុប** | | | **៣.៦៣** | **០.៥២** | **ល្អ** |

នៅក្នុងផ្នែកទី២ នៃកម្រងសំណួរសម្រាប់លោកគ្រូ អ្នកគ្រូ ដែលនិយាយពីទស្សនៈរបស់មាតាបិតាលើតួនាទី ក្នុងការចូលរួម និងការសិក្សារបស់កូន គឺពិតជាអាចទទួលយកជាការបាន ពីព្រោះយោងតាមលទ្ធផលសរុប ស្ថិតក្នុងកម្រិតល្អ (**M = ៣.៦៣, S.D = ០.៥២**)។ បើតាមការពិនិត្យមើលគ្រប់ចំណងជើងរងទាំង៥ចំណុច យើងទាញបានលទ្ធផលដូចតទៅ៖ លទ្ធផលខាងលើបង្ហាញថា សូចនាករដែលមានលំដាប់មធ្យមភាគខ្ពស់ជាងគេ គឺចំណុចទី៤ «ការទំនាក់ទំនងរវាងមាតាបិតា ការចូលរួម និងការលើកទឹកចិត្តសិស្ស» ស្ថិតក្នុងកម្រិត ល្អ (**M = ៣.៩៨, S.D = ០.៧០**)។ ចំពោះសូចនាករដែលមានលំដាប់មធ្យមភាគទាបជាងគេ គឺចំណុចទី៣ «ឥទ្ធិពលនៃការចូលរួមរបស់មាតាបិតាលើសមិទ្ធផលការសិក្សា» ស្ថិតក្នុងកម្រិត ល្អ (**M = ៣.៣៥, S.D = ០.៦៦**)។

លទ្ធផលនៃកម្រងសំណួរសម្រាប់សិស្ស

តារាងទី៤.១៣៖ តម្លៃមធ្យម គម្លាតស្តង់ដា កម្រិតចង្អុលបង្ហាញ ដំណើរការចូលរួមចំណែកអប់រំកូនរបស់មាតាបិតា តាមចំណុចនីមួយៗ (N=១២៣)

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ខ្ញុំយល់ឃើញថា ការអប់រំមានសារៈសំខាន់ណាស់ ចំពោះខ្លួនខ្ញុំ និងឪពុកម្តាយ | ៤.២៦ | ០.៧២ | ល្អណាស់ |
| ២ | ខ្ញុំយល់ថា ការពិភាក្សាជាមួយឪពុកម្តាយ អំពីការសិក្សារបស់ខ្ញុំ ពិតជាមានសារៈសំខាន់ណាស់ | ៤.០៩ | ០.៨៩ | ល្អ |
| ៣ | ឪពុកម្តាយខ្ញុំ យល់ដឹងច្រើន អំពីសារៈសំខាន់នៃការសិក្សារបស់កូន | ៣.៨៤ | ១.០៣ | ល្អ |
| ៤ | ការចូលរៀនបានទៀងទាត់ និងទាន់ពេលវេលា សម្រាប់រូបខ្ញុំ ពិតជាមានការជំរុញពីឪពុកម្តាយជាប្រចាំ | ៣.៥៧ | ១.១៣ | ល្អ |
| ៥ | ពេលដែលខ្ញុំនៅក្រៅផ្ទះ ឪពុកម្តាយគាត់តែងតែ តាមដានសកម្មភាពរបស់ខ្ញុំ ជាប្រចាំ | ៣.២៦ | ១.១៣ | មធ្យម |
| ៦ | ឪពុកម្តាយខ្ញុំតែងតែសាកសួរខ្ញុំ អំពីផលលំបាក ឬឧបសគ្គនៅពេលដែលធ្វើដំណើរទៅសាលា និងពេលត្រឡប់មកផ្ទះវិញ | ៣.៤១ | ១.១៣ | ល្អ |
| ៧ | ឪពុកម្តាយខ្ញុំចំណាយពេលជូនកូនទៅសាលា និងទៅទទួលមកផ្ទះវិញជាប្រចាំ | ២.៣០ | ១.២០ | ខ្សោយ |
| ៨ | ឪពុកម្តាយខ្ញុំឧស្សាហ៍ទៅសាលារៀន ឬទាក់ទងតាម | ២.៦១ | ១.១៨ | មធ្យម |

| | | | | |
|---|---|---|---|---|
| | ទូរស័ព្ទដើម្បីជួប នាយក និងគ្រូ ព្រោះគាត់ចង់ដឹងពីការសិក្សារបស់ខ្ញុំ | | | |
| ៩ | ឪពុកម្តាយខ្ញុំយល់ថាការទទួលសៀវភៅតាមដានការសិក្សារបស់កូនពីសាលារៀនជារៀងរាល់ខែមានសារៈសំខាន់ណាស់ | ៤.០៥ | ១.០៣ | ល្អ |
| ១០ | លោកគ្រូ អ្នកគ្រូ របស់ខ្ញុំតែងតែទំនាក់ទំនងមកឪពុកម្តាយជារៀងរាល់ខែ | ២.៥៤ | ១.១៧ | ខ្សោយ |
| ១១ | លោកនាយកសាលា ឧស្សាហ៍ទាក់ទងជាមួយឪពុកម្តាយខ្ញុំ ដើម្បីផ្តល់ព័ត៌មានអំពីការរីកចម្រើន ឬភាពអវិជ្ជមានចំពោះការសិក្សារបស់កូន | ២.៧០ | ១.១៦ | មធ្យម |
| ១២ | ឪពុកម្តាយខ្ញុំយល់ថាការដាក់ពិន្ទុក្នុងសៀវភៅតាមដានការសិក្សា មានលក្ខណៈយុត្តិធម៌និងមានតម្លាភាព | ៣.៣៩ | ១.២១ | មធ្យម |
| ១៣ | មុនឲ្យកូនទៅសាលា ឪពុកម្តាយខ្ញុំបានជួយរំលឹកខ្ញុំដើម្បីបានមើលមេរៀន ឬអានសៀវភៅផ្សេងៗផងដែរ | ៣.៤៣ | ១.១៦ | ល្អ |
| | **សរុប** | **៣.៣៤** | **០.៥៥** | **មធ្យម** |

តារាងខាងលើនេះ បានបង្ហាញពីដំណើរការចំពោះតួនាទីក្នុងការចូលរួមចំណែកអប់រំកូនរបស់មាតាបិតា សរុបគឺ ស្ថិតក្នុងកម្រិត(**មធ្យម**) (**M = ៣.៣៤, S.D = ០.៥៥**)។ លទ្ធផលខាងលើបង្ហាញថា សូចនាករដែលមានលំដាប់មធ្យមភាគខ្ពស់ជាងគេ គឺចំណុចទី១ «សិស្ស យល់ឃើញថា ការអប់រំមានសារៈសំខាន់ណាស់ ចំពោះខ្លួនខ្ញុំ និងឪពុកម្តាយ» ស្ថិតក្នុងកម្រិត ល្អណាស់ (**M = ៤.២៦ , S.D = ០.៧២**)។ ចំពោះសូចនាករដែលមានលំដាប់មធ្យមភាគទាបជាងគេ គឺចំណុចទី៧ «ឪពុកម្តាយសិស្ស

ចំណាយពេលជូនកូនទៅសាលា និងទៅទទួលមកផ្ទះវិញជាប្រចាំ» ស្ថិតក្នុងកម្រិតខ្សោយ (**M=២.៣០, S.D =១,២០**)។

ដំណើរការចូលរួមចំណែកអប់រំកូនរបស់មាតាបិតា នៅក្នុងចំណុចនេះអ្នកស្រាវជ្រាវបានបែងចែកជា១៣សូចនាករ។ សិស្សានុសិស្សទាំង៥សាលាគោលដៅបានឆ្លើយ និងបានបំពេញគ្រប់ចំណុចទាំងអស់ដែលទទួលបានលទ្ធផលដូចតទៅ៖ កម្រិតល្អណាស់ មានចំនួន១ កម្រិតល្អ មានចំនួន៦ កម្រិតមធ្យម ចំនួន៤ និងកម្រិតខ្សោយ មានចំនួន២។ យើងបានជាលទ្ធផល ដែលអាចយកជាការបានគឺ ដំណើរការចំពោះតួនាទីក្នុងការចូលរួមចំណែកអប់រំកូនរបស់មាតាបិតា ដែលសិស្សយល់ឃើញ គឺពិតជាពួកគាត់ចង់ឲ្យឪពុកម្ដាយរបស់ពួកគេផ្ទាល់ យល់ដឹងបន្ថែម ចំពោះការសិក្សា ក៏ដូចជាការអប់រំ។

**តារាងទី៤.១៤៖ តម្លៃមធ្យម គម្លាតស្តង់ដា កម្រិតចង្អុលបង្ហាញ ការរួមចំណែកពីមាតាបិតានៅសាលារៀន តាមចំណុចនីមួយៗ (N=១២៣)**

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ឪពុកម្តាយខ្ញុំគិតថាការធ្វើកិច្ចការផ្ទះមានសារៈសំខាន់ណាស់ សម្រាប់កូន | ៣.៩៣ | ០.៨៩ | ល្អ |
| ២ | ឪពុកម្តាយខ្ញុំបានជួយ និងត្រួតពិនិត្យកិច្ចការផ្ទះជាមួយកូនបានញឹកញាប់ណាស់ | ២.៨៤ | ១.១៩ | មធ្យម |
| ៣ | ឪពុកម្តាយខ្ញុំដឹងថាមុខវិជ្ជាមួយចំនួនដែលកូនកំពុងរៀនរាល់ថ្ងៃ គាត់មិនអាចជួយគាត់បានទេ | ៣.៣៣ | ១.២៥ | មធ្យម |
| ៤ | ការជួយពីឪពុកម្តាយ គាត់រំពឹងថា លទ្ធផលការសិក្សារបស់កូន លើមុខវិជ្ជានីមួយៗ បានពិន្ទុលើសពី៥០% | ៣.២៤ | ១.១២ | មធ្យម |

| | | | | |
|---|---|---|---|---|
| ៥ | ឪពុកម្ដាយខ្ញុំ បានជួយពន្យល់មេរៀន ឬជួយកិច្ចការផ្ទះ ដល់រូបខ្ញុំ លើមុខវិជ្ជាណាដែលខ្ញុំចេះធ្វើ ឬមិនចេះអាន | ២.៧០ | ១.១៦ | មធ្យម |
| ៦ | ឪពុកម្ដាយខ្ញុំ បានដាស់តឿន ឲ្យកូនពិនិត្យ មើលសម្ភារសិក្សាឲ្យបានគ្រប់គ្រាន់មុននិងទៅសាលារៀន ជាប្រចាំ | ៣.៦៩ | ១.១៣ | ល្អ |
| ៧ | ឪពុកម្ដាយខ្ញុំ បានចូលរួមជួយកូន ចំពោះការសិក្សាស្មើរគ្រប់មុខវិជ្ជា | ២.៩១ | ១.២១ | មធ្យម |
| ៨ | ឪពុកម្ដាយខ្ញុំដាស់តឿនឲ្យកូនខិតខំរៀន និងស្រាវជ្រាវលើមុខវិជ្ជាណាដែលរៀនខ្សោយជាងគេ | ៤.៣០ | ០.៨៦ | ល្អ |
| ៩ | ឪពុកម្ដាយខ្ញុំបានផ្ដល់សៀវភៅផ្សេងៗ ឬទស្សនាវដ្ដីនានា សម្រាប់ឲ្យកូនអាន | ៣.០៤ | ១.២១ | មធ្យម |
| ១០ | ខ្ញុំតែងតែ យកកិច្ចការពីសាលា ដើម្បីឲ្យឪពុកម្ដាយត្រួតពិនិត្យ បានញឹកញាប់ណាស់ | ២.៧៣ | ១.១៩ | មធ្យម |
| | **សរុប** | **៣.២៧** | **០.៥៦** | **មធ្យម** |

តារាងខាងលើនេះ បានបង្ហាញពីការរួមចំណែកពីមាតាបិតានៅសាលារៀន សរុបគឺ ស្ថិតក្នុងកម្រិត **(មធ្យម) (M = ៣.២៧, S.D = ០.៥៦)**។

លទ្ធផលខាងលើបង្ហាញថា សូចនាករដែលមានលំដាប់មធ្យមភាគខ្ពស់ជាងគេ គឺចំណុចទី៨ «ឪពុកម្ដាយសិស្ស ដាស់តឿនឲ្យកូនខិតខំរៀន និងស្រាវជ្រាវលើមុខវិជ្ជាណាដែលរៀនខ្សោយជាងគេ» ស្ថិតក្នុងកម្រិត ល្អ **(M = ៤.៣០ , S.D = ០.៨៦)**។ ចំពោះសូចនាករដែលមានលំដាប់មធ្យមភាគទាប

ជាងគេ គឺចំណុចទី៥ «ឪពុកម្ដាយសិស្ស បានជួយពន្យល់មេរៀន ឬជួយកិច្ចការផ្ទះ ដល់រូបខ្ញុំ លើមុខវិជ្ជាណាដែលខ្ញុំចេះធ្វើ ឬមិនចេះអាន» ស្ថិតក្នុងកម្រិត មធ្យម (**M = ២.៧០, S.D = ១.១៦**)។

ការរួមចំណែកពីមាតាបិតានៅសាលារៀន អ្នកស្រាវជ្រាវបានកំណត់ជា១០សូចនាករ។ បន្ទាប់ពីសិស្សបានឆ្លើយចប់សព្វគ្រប់ហើយ យើងឃើញលទ្ធផលដូចតទៅនេះ៖ កម្រិតល្អ មានចំនួន៣ និងកម្រិតមធ្យម មានចំនួន៧ ក្រៅពីនេះពុំមានការឆ្លើយរបស់សិស្សនោះទេ។ ទិន្នន័យនេះបានបង្ហាញថា ការរួមចំណែកពីមាតាបិតានៅសាលារៀន នៅមានកម្រិតទាបនៅឡើយ ដោយសិស្សខ្លួនឯងផ្ទាល់ មិនសូវបានឃើញឪពុកម្ដាយរបស់ខ្លួន មកសាលារៀននោះទេ។ ដូចនេះ ទាំងសាលារៀន មាននាយក គ្រូបង្រៀន និងសិស្សផ្ទាល់ ត្រូវមានការទំនាក់ទំនង ជាមួយនិងឪពុកម្ដាយសិស្សឲ្យបានញឹកញាប់ ឬជាប្រចាំ ទើបជាការប្រសើរ។

**តារាងទី៤.១៥៖ តម្លៃមធ្យម គម្លាតស្តង់ដា កម្រិតចង្អុលបង្ហាញ ឥទ្ធិពលនៃការចូលរួមរបស់មាតាបិតាលើសមិទ្ធផលការសិក្សា តាមចំណុចនីមួយៗ (N = ១២៣)**

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ខ្ញុំប្រែប្រួលឥរិយាបថ ពីការមិនមើលសៀវភៅ ទៅជាការចូលចិត្តអានសៀវភៅបានជាប្រចាំ | ៣.៦០ | ១.០៧ | ល្អ |
| ២ | ឪពុកម្តាយខ្ញុំបានជួយជំរុញ និងត្រួតពិនិត្យកិច្ចការផ្ទះជាមួយខ្ញុំ បានញឹកញាប់ណាស់ | ២.៧៥ | ១.១២ | មធ្យម |
| ៣ | ខ្ញុំមានភាពក្លាហានក្នុងការសួរគ្រូ ឬឆ្លើយសំណួរ និងឡើងដោះស្រាយលំហាត់បានល្អ | ៣.៥៥ | ១.០៩ | ល្អ |
| ៤ | ឪពុកម្តាយខ្ញុំរំពឹងថា លទ្ធផលការសិក្សារបស់កូន លើមុខវិជ្ជានីមួយៗ បានពិន្ទុចាប់ពី៥០%ឡើង | ៣.៣៨ | ១.០៩ | មធ្យម |

| | | | | |
|---|---|---|---|---|
| ៥ | ខ្ញុំអាចបែងចែកពេលវេលារៀនសូត្រនៅផ្ទះ និងពេលវេលាដែលត្រូវសម្រាកដោយខ្លួនឯងបាន | ៣.៦៩ | ១.០៧ | ល្អ |
| ៦ | ឪពុកម្ដាយខ្ញុំបានដាស់តឿនខ្ញុំ ឲ្យពិនិត្យ និងអនុវត្តលើកិច្ចការផ្ទះ ជាប្រចាំ | ៣.៦០ | ១.០៥ | ល្អ |
| ៧ | ឪពុកម្ដាយខ្ញុំដាស់តឿនឲ្យកូនខិតខំរៀន និងស្រាវជ្រាវលើមុខវិជ្ជាណាដែលរៀនខ្សោយជាងគេ | ៤.១១ | ០.៨១ | ល្អ |
| ៨ | ឪពុកម្ដាយខ្ញុំបានផ្ដល់សៀវភៅផ្សេងៗ ឬទស្សនាវដ្ដីនានា សម្រាប់ឲ្យកូនអាន ដើម្បីកាត់បន្ថយការលេងទូរស័ព្ទ | ៣.៣៧ | ១.០៩ | មធ្យម |
| ៩ | ឪពុកម្ដាយខ្ញុំគ្រប់គ្រងពេលវេលាក្នុងការមើលទូរទស្សន៍ និងការលេងហ្គេម ឬលេងស្មាតហ្វូនរបស់កូន បានទៀងទាត់ល្អណាស់ | ៣.០១ | ១.១៥ | មធ្យម |
| ១០ | ឪពុកម្ដាយខ្ញុំតែងតែត្រួតពិនិត្យកិច្ចការពីសាលារបស់កូនបានញឹកញាប់ណាស់ | ២.៨៤ | ១.១៩ | មធ្យម |
| **សរុប** | | **៣.៣៩** | **០.៦៦** | **មធ្យម** |

តារាងខាងលើនេះ បានបង្ហាញពីឥទ្ធិពលនៃការចូលរួមរបស់មាតាបិតាលើសមិទ្ធផលការសិក្សាសរុបគឺ ស្ថិតក្នុងកម្រិត(**មធ្យម**) (**M = ៣.៣៩, S.D = ០.៦៦**)។ លទ្ធផលខាងលើបង្ហាញថា សូចនាករដែលមានលំដាប់មធ្យមភាគខ្ពស់ជាងគេ គឺចំណុចទី៧ «ឪពុកម្ដាយសិស្ស ដាស់តឿនឲ្យកូនខិតខំរៀន និងស្រាវជ្រាវលើមុខវិជ្ជាណាដែលរៀនខ្សោយជាងគេ» ស្ថិតក្នុងកម្រិត ល្អ (**M = ៤.១១, S.D = ០.៨១**) ចំពោះសូចនាករដែលមានលំដាប់មធ្យមភាគទាបជាងគេ គឺចំណុចទី២ «ឪពុកម្ដាយសិស្ស បានជួយជំរុញ

និងត្រួតពិនិត្យកិច្ចការផ្ទះជាមួយខ្ញុំ បានញឹកញាប់ណាស់» ស្ថិតក្នុងកម្រិត មធ្យម (**M = ២.៧៥, S.D = ១.១២**)។

ឥទ្ធិពលនៃការចូលរួមរបស់មាតាបិតាលើសមិទ្ធផលការសិក្សា នៅក្នុងផ្នែកនេះ អ្នកស្រាវជ្រាវក៏បានបែងចែកជា១០ សូចនាករផងដែរ។ លទ្ធផលរួមមាន៖ កម្រិតល្អ មានចំនួន៥ និងកម្រិតមធ្យម មានចំនួន៥ ក្រៅពីនេះមិនមានចម្លើយ។ ដូចនេះ ឥទ្ធិពលនៃការចូលរួមរបស់មាតាបិតាលើសមិទ្ធផលការសិក្សា មានភាពប្រទាញប្រទង់គ្នា ដោយសិស្សយល់ឃើញជាក់ស្តែងទៅតាមស្ថានភាព និងផ្នត់គំនិតរបស់ឪពុកម្តាយគេ។ សិស្សដែលឆ្លើយថា ពុំមានយោបល់ ដោយពួកគាត់មិនសូវឃើញមានឪពុកម្តាយរបស់គេជួយអ្វីបានសោះសម្រាប់ការសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិ។

**តារាងទី៤.១៦ ៖ តម្លៃមធ្យម គម្លាតស្តង់ដា កម្រិតចង្អុលបង្ហាញ ការទំនាក់ទំនងរវាងមាតាបិតា ការចូលរួម និងការលើកទឹកចិត្តសិស្ស តាមចំណុចនីមួយៗ (N=១២៣)**

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ឪពុកម្តាយ មានតួនាទី និងមានការទទួលខុសត្រូវចំពោះកូនដែលកំពុងសិក្សា | ៤.០៨ | ០.៨៥ | ល្អ |
| ២ | ទោះបីជាឪពុកម្តាយខ្ញុំមានការមមាញឹករវល់នឹងការងារយ៉ាងណា ក៏គាត់ឆ្លៀតពេលតាមដាន និងពិនិត្យលើការសិក្សារបស់កូនដែរ | ៣.៧០ | ១.១២ | ល្អ |
| ៣ | ឪពុកម្តាយខ្ញុំប្រើមធ្យោបាយជាច្រើន ដើម្បីឲ្យកូនទទួលជោគជ័យក្នុងការសិក្សា ដូចជា ឲ្យកូនរៀនគួរនៅខាងក្រៅឬសាលាឯកជនដទៃទៀត | ៤.០៤ | ០.៩១ | ល្អ |
| ៤ | ឪពុកម្តាយជួយកូន ឲ្យទទួលបានជោគជ័យក្នុងការសិក្សា | ៤.១៣ | ០.៨៧ | |

| | | | | |
|---|---|---|---|---|
| | នៅមធ្យមសិក្សាទុតិយភូមិ និងបន្តការសិក្សានៅមហាវិទ្យាល័យ | | | ល្អ |
| ៥ | ឪពុកម្ដាយខ្ញុំ គ្រប់គ្រងពេលវេលាក្នុងការមើលទូរទស្សន៍ និងការលេងហ្គេម ឬលេងស្មាតហ្វូនរបស់កូន បានទៀងទាត់ល្អណាស់ | ៣.០៧ | ១.២៤ | មធ្យម |
| **សរុប** | | **៣.៨០** | **០.៦៦** | **ល្អ** |

តារាងខាងលើនេះ បានបង្ហាញពីការទំនាក់ទំនងរវាងមាតាបិតា ការចូលរួម និងការលើកទឹកចិត្តសិស្ស សរុបគឺ ស្ថិតក្នុងកម្រិត(**ល្អ**) (**M = ៣.៨០, S.D = ០.៦៦**)។

លទ្ធផលខាងលើបង្ហាញថា សូចនាករដែលមានលំដាប់មធ្យមភាគខ្ពស់ជាងគេ គឺចំណុចទី៤ «ឪពុកម្ដាយជួយកូន ឲ្យទទួលបានជោគជ័យក្នុងការសិក្សានៅមធ្យមសិក្សាទុតិយភូមិ និងបន្តការសិក្សានៅមហាវិទ្យាល័យ» ស្ថិតក្នុងកម្រិត ល្អ (**M = ៤.១៣, S.D = ០.៨៧**)។ ចំពោះសូចនាករដែលមានលំដាប់មធ្យមភាគទាបជាងគេ គឺចំណុចទី៥ «ឪពុកម្ដាយសិស្ស គ្រប់គ្រងពេលវេលាក្នុងការមើលទូរទស្សន៍ និងការលេងហ្គេម ឬលេងស្មាតហ្វូនរបស់កូន បានទៀងទាត់ល្អណាស់» ស្ថិតក្នុងកម្រិត មធ្យម (**M = ៣.០៧, S.D = ១.២៤**)។

ការទំនាក់ទំនងរវាងមាតាបិតា ការចូលរួម និងការលើកទឹកចិត្តសិស្ស នៅក្នុងចំណុចនេះ គឺមានចំនួន៥ សូចនាករ។ លទ្ធផលស្រាវជ្រាវគឺ កម្រិតល្អ មានចំនួន៤ និងកម្រិតមធ្យម មានចំនួន១។ ផ្អែកតាមលទ្ធផលនេះបានបង្ហាញថា ការទំនាក់ទំនងរវាងមាតាបិតា ការចូលរួម និងការលើកទឹកចិត្តសិស្ស គឺបានយកចិត្តដាក់ខ្ពស់ពីសំណាក់ឪពុកម្ដាយសិស្ស ផ្សារភ្ជាប់ជាមួយ ការចូលរួម ការលើកទឹកចិត្តឲ្យកូនខិតខំរៀនសូត្រ បានពេញលេញ ដែលអាចទទួលយកបានគ្រប់ភាគីចូលរួម។

**តារាងទី៤.១៧៖ សរុបលទ្ធផលរួម ការចូលរួមឆ្លើយរបស់សិស្ស៖**

| ល.រ | សូចនាករតាមផ្នែកនីមួយៗ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|---|
| ១ | ២.១-២.១៣ | ដំណើរការចំពោះតួនាទីក្នុងការចូលរួមចំណែកអប់រំកូនរបស់មាតាបិតា | ៣.៣៤ | ០.៥៥ | មធ្យម |
| ២ | ២.១៤-២.២៣ | ការរួមចំណែកពីមាតាបិតានៅសាលារៀន | ៣.២៧ | ០.៥៦ | មធ្យម |
| ៣ | ២.២៤-២.៣៣ | ឥទ្ធិពលនៃការចូលរួមរបស់មាតាបិតាលើសមិទ្ធផលការសិក្សា | ៣.៣៩ | ០.៦៦ | មធ្យម |
| ៤ | ២.៣៤-២.៣៨ | ការទំនាក់ទំនងរវាងមាតាបិតា ការចូលរួម និងការលើកទឹកចិត្តសិស្ស | ៣.៨០ | ០.៦៦ | ល្អ |
| **សរុប** | | | **៣.៤៥** | **០.៥២** | **ល្អ** |

នៅក្នុងផ្នែកទី២ នៃកម្រងសំណួរសម្រាប់សិស្សានុសិស្ស ដែលនិយាយពីទស្សនៈរបស់មាតាបិតាលើតួនាទី ក្នុងការចូលរួម និងការសិក្សារបស់កូន គឺពិតជាអាចទទួលយកជាការបាន ពីព្រោះយោងតាមលទ្ធផលសរុប ស្ថិតក្នុងកម្រិតល្អ (**M = ៣.៤៥, S.D = ០.៥២**)។ បើតាមការពិនិត្យមើលគ្រប់ចំណងជើងរងទាំង៤ចំណុច យើងទាញបានលទ្ធផលដូចតទៅ៖ លទ្ធផលខាងលើបង្ហាញថា សូចនាករដែលមានលំដាប់មធ្យមភាគខ្ពស់ជាងគេ គឺចំណុចទី៤ «ការទំនាក់ទំនងរវាងមាតាបិតា ការចូលរួម និងការលើក

ទឹកចិត្តសិស្ស» ស្ថិតក្នុងកម្រិត ល្អ (**M = ៣.៨០, S.D = ០.៦៦**)។ ចំពោះសូចនាករដែលមានលំដាប់មធ្យមភាគទាបជាងគេ គឺចំណុចទី២ «ការរួមចំណែកពីមាតាបិតានៅសាលារៀន» ស្ថិតក្នុងកម្រិត មធ្យម (**M = ៣.២៧, S.D = ០.៥៦**)។

## តារាងទី៤.១៨៖ លទ្ធផលរួម ការចូលរួមឆ្លើយរបស់ មាតាបិតា គ្រូបង្រៀន និងសិស្ស

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| **មាតាបិតា (M = ៣.៨៩, S.D = ០.៤៦)** | | | | |
| ១ | ដំណើរការចំពោះតួនាទីក្នុងការចូលរួមចំណែកអប់រំកូនរបស់មាតាបិតា | ៣.៧៧ | ០.៥៥ | ល្អ |
| ២ | ការរួមចំណែកពីមាតាបិតានៅសាលារៀន | ៣.៥១ | ០.៦២ | ល្អ |
| ៣ | ឥទ្ធិពលនៃការចូលរួមរបស់មាតាបិតាលើសមិទ្ធផលការសិក្សា | ៣.៦៨ | ០.៥៤ | ល្អ |
| ៤ | ការទំនាក់ទំនងរវាងមាតាបិតា ការចូលរួម និងការលើកទឹកចិត្តសិស្ស | ៤.២៦ | ០.៤៨ | ល្អណាស់ |
| ៥ | ការចូលរួមចំណែកលើការអប់រំកូន និងការទទួលខុសត្រូវរបស់មាតាបិតា | ៤.២៥ | ០.៥៩ | ល្អណាស់ |
| **គ្រូបង្រៀន (M = ៣.៦៣, S.D = ០.៥២)** | | | | |
| ១ | ដំណើរការចំពោះតួនាទីក្នុងការចូលរួមចំណែកអប់រំកូនរបស់មាតាបិតា | ៣.៤៣ | ០.៦២ | ល្អ |
| ២ | ការរួមចំណែកពីមាតាបិតានៅសាលារៀន | ៣.៨០ | ០.៦១ | ល្អ |
| ៣ | ឥទ្ធិពលនៃការចូលរួមរបស់មាតាបិតាលើសមិទ្ធផលការសិក្សា | ៣.៣៥ | ០.៦៦ | មធ្យម |
| ៤ | ការទំនាក់ទំនងរវាងមាតាបិតា ការចូលរួម និងការលើកទឹកចិត្តសិស្ស | ៣.៩៨ | ០.៧០ | ល្អ |
| ៥ | ការចូលរួមចំណែកលើការអប់រំកូន និងការទទួលខុស | ៣.៥៨ | ០.៧៦ | ល្អ |

| | | | | |
|---|---|---|---|---|
| | ត្រូវរបស់មាតាបិតា | | | |
| **សិស្ស (M= ៣.៤៥, S.D = ០.៥២)** | | | | |
| ១ | ដំណើរការចំពោះតួនាទីក្នុងការចូលរួមចំណែកអប់រំកូនរបស់មាតាបិតា | ៣.៣៤ | ០.៥៥ | មធ្យម |
| ២ | ការរួមចំណែកពីមាតាបិតានៅសាលារៀន | ៣.២៧ | ០.៥៦ | មធ្យម |
| ៣ | ឥទ្ធិពលនៃការចូលរួមរបស់មាតាបិតាលើសមិទ្ធផលការសិក្សា | ៣.៣៩ | ០.៦៦ | មធ្យម |
| ៤ | ការទំនាក់ទំនងរវាងមាតាបិតា ការចូលរួម និងការលើកទឹកចិត្តសិស្ស | ៣.៨០ | ០.៦៦ | ល្អ |
| **សរុបរួម** | | **៣.៦៦** | **០.៥០** | **ល្អ** |

យោងតាមលទ្ធផលនៃការសរុបរួម របស់ មាតាបិតា គ្រូបង្រៀន និងសិស្ស រួចមកយើងឃើញថា លទ្ធផលទាំងបីផ្នែកគឺអាចវាយតម្លៃបានថា ទស្សនៈរបស់មាតាបិតាសិស្ស ចំពោះតួនាទីរបស់ខ្លួន ក្នុងការចូលរួមចំណែកជួយការអប់រំ និងការសិក្សារបស់កូនៗ នៅមធ្យមសិក្សាទុតិយភូមិ គឺពិតជាអាចទទួលយកបានហើយ ពីព្រោះលទ្ធផលសរុបរួមគឺស្ថិតក្នុងកម្រិតល្អ (**M = ៣.៦៦, S.D = ០.៥០**)។ មាតាបិតា ស្ថិតក្នុងចំណាត់ថ្នាក់ទី១ ក្នុងចំណោមផ្នែកទាំងបី(មាតាបិតា គ្រូបង្រៀន និងសិស្ស) គឺ (**M = ៣.៨៩, S.D = ០.៤៦**) ដែលស្ថិតក្នុងកម្រិតមធ្យម រីឯសិស្សវិញបានទទួលចំណាត់ថ្នាក់ទាបជាងគេគឺ (**M= ៣.៤៥, S.D = ០.៥២**) ដែលស្ថិតក្នុងកម្រិតល្អ ដូចគ្នា។

## ៤.២.២ បញ្ហាប្រឈមក្នុងការចូលរួមរបស់មាតាបិតា

តារាងទី៤.១៩៖ សម្រាប់មាតាបិតា

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ខ្ញុំគ្មានពេលវេលាច្រើននៅផ្ទះ ដោយជាប់រវល់ធ្វើការងារ ឬរកស៊ី | ៣.៣៧ | ១.០១ | មធ្យម |
| ២ | ខ្ញុំមានកូនច្រើនដែលរៀនកម្រិតថ្នាក់ផ្សេងៗគ្នា ដូចនេះមិនបានជួយពួកគេក្នុងការអានសៀវភៅ ឬធ្វើលំហាត់ពីសាលាទេ | ២.៧៤ | ១.១៥ | មធ្យម |
| ៣ | ខ្ញុំមានកូនតូចច្រើនត្រូវមើលថែទាំនៅផ្ទះ | ២.៣២ | ១.១៤ | មធ្យម |
| ៤ | ខ្ញុំមិនមានចំណេះដឹងគ្រប់គ្រាន់ក្នុងការជួយកូននៅ មធ្យមសិក្សាទុតិយភូមិ | ២.៦៩ | ១.២៤ | មធ្យម |
| ៥ | ខ្ញុំមិនមានពេលវេលាគ្រប់គ្រាន់ទៅតាមដាន មើលកូន នៅសាលារៀនបានទៀងទាត់ជាប្រចាំនោះទេ | ២.៧៥ | ១.៣១ | មធ្យម |
| ៦ | ខ្ញុំមិនដែលបានដឹងពីតម្រូវការចាំបាច់របស់សាលារៀនឡើយ | ២.៤៨ | ១.២១ | មធ្យម |
| ៧ | ខ្ញុំឧស្សាហ៍ទទួលការកោះអញ្ជើញចូលរួមប្រជុំនៅសាលា ពីបញ្ហាកូន | ២.២៤ | ១.៣១ | ខ្សោយ |
| ៨ | ខ្ញុំបារម្ភហួងហែងខ្លាំងពេក | ២.០៣ | ០.៩៩ | ខ្សោយ |
| ៩ | ខ្ញុំចូលចិត្តប្រៀបធៀប ជាមួយកូនអ្នកដទៃ | ១.៩៨ | ១.១៨ | ខ្សោយ |
| ១០ | ខ្ញុំស្រែកគំហកនិងប្រើអំពើហិង្សាដាក់កូន | ១.៧០ | ១.០៧ | ខ្សោយ |

| | | | | |
|---|---|---|---|---|
| ១១ | ខ្ញុំមិនធ្វើជាគំរូល្អ ដល់កូនបានម្តងណាឡើយ | ១.៧២ | ១.០៥ | ខ្សោយ |
| ១២ | ខ្ញុំមិនចំណាយពេលវេលាជាមួយកូនសោះ | ១.៧២ | ១.០១ | ខ្សោយ |
| ១៣ | ខ្ញុំតែងតែបិទសិទ្ធិសេរីភាពរបស់កូន | ១.៧៥ | ១.០៥ | ខ្សោយ |
| **សរុប** | | **២.២៧** | **០.៧៤** | **ខ្សោយ** |

នៅក្នុងផ្នែកទី៣ នៃកម្រងសំណួរសម្រាប់មាតាបិតា ដែលនិយាយពីឧបសគ្គរាំងនៃការចូលរួម និងបញ្ហាប្រឈមនានា គឺនៅមិនទាន់បានល្អប្រសើរនៅឡើយ យោងតាមលទ្ធផលសរុប ស្ថិតក្នុងកម្រិតខ្សោយ (**M = ២.២៧, S.D = ០.៧៤**)។ សូចនាករដែលមានលំដាប់មធ្យមភាគខ្ពស់ជាងគេ គឺចំណុចទី៥ «មាតាបិតា មិនមានពេលវេលាគ្រប់គ្រាន់ទៅតាមដាន មើលកូន នៅសាលារៀនបានទៀងទាត់ជាប្រចាំនោះទេ» ស្ថិតក្នុងកម្រិត មធ្យម (**M = ២.៧៥, S.D = ១,៣១**)។ ចំពោះសូចនាករដែលមានលំដាប់មធ្យមភាគទាបជាងគេ គឺចំណុចទី១២ «មាតាបិតា មិនចំណាយពេលវេលាជាមួយកូនសោះ» ស្ថិតក្នុងកម្រិត មធ្យម (**M = ១.៧២, S.D = ១,០១**)។

**តារាងទី៤.២០៖ សម្រាប់គ្រូ**

| ល.រ | **បរិយាយ** | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ឪពុកម្តាយសិស្សគ្មានពេលវេលាច្រើននៅផ្ទះ ដោយជាប់រវល់ធ្វើការងារ ឬរកស៊ី | ៣.៩១ | ០.៩២ | ល្អ |
| ២ | ឪពុកម្តាយសិស្ស មួយចំនួយមានកូនច្រើនដែលរៀនកម្រិតថ្នាក់ផ្សេងៗគ្នា ដូចនេះមិនបានជួយកូនក្នុងការអានសៀវភៅ ឬធ្វើលំហាត់ពីសាលាទេ | ៣.៦៧ | ០.៩៤ | ល្អ |
| ៣ | ឪពុកម្តាយសិស្សខ្លះមានកូនតូចច្រើនត្រូវមើលថែទាំ | ៣.៤៨ | ០.៨៦ | ល្អ |

| | | | | |
|---|---|---|---|---|
| | នៅផ្ទះ | | | |
| ៤ | ឪពុកម្តាយសិស្ស មួយចំនួនមិនមានចំណេះដឹងគ្រប់គ្រាន់ក្នុងការជួយកូននៅមធ្យមសិក្សាទុតិយភូមិ | ៣.៧០ | ០.៩០ | ល្អ |
| ៥ | ឪពុកម្តាយសិស្សភាគច្រើនមិនមានពេលវេលាគ្រប់គ្រាន់ទៅតាមដាន មើលកូន នៅសាលារៀនបានទៀងទាត់ជាប្រចាំនោះទេ | ៣.៥៦ | ១.១៩ | ល្អ |
| ៦ | ឪពុកម្តាយសិស្សខ្លះ មិនដែលបានដឹងពីតម្រូវការចាំបាច់របស់សាលារៀនឡើយ | ៣.៦៧ | ០.៩៤ | ល្អ |
| ៧ | ឪពុកម្តាយសិស្សមួយចំនួនតូចឧស្សាហ៍ទទួលការកោះអញ្ជើញចូលរួមប្រជុំនៅសាលា ពីបញ្ហាកូនរបស់គាត់ | ៣.២៧ | ១.១៧ | មធ្យម |
| ៨ | ឪពុកម្តាយសិស្សខ្លះបារម្ភហួងហែងកូនខ្លាំងពេក | ៣.២៩ | ០.៩៩ | មធ្យម |
| ៩ | ឪពុកម្តាយសិស្សមួយចំនួនចូលចិត្តប្រៀបធៀប ជាមួយកូនអ្នកដទៃ | ៣.១៦ | ០.៩៥ | មធ្យម |
| ១០ | ឪពុកម្តាយសិស្សខ្លះស្រែកគំហកនិងប្រើអំពើហិង្សាដាក់កូន | ២.៨៩ | ១.០២ | មធ្យម |
| ១១ | ឪពុកម្តាយសិស្ស ភាគច្រើនមិនធ្វើជាគំរូល្អ ដល់កូនបានម្តងណាឡើយ | ២.៤៨ | ១.០៤ | មធ្យម |
| ១២ | ឪពុកម្តាយសិស្សខ្លះមិនបានចំណាយពេលវេលាជាមួយកូនសោះ | ២.៦៧ | ១.០៨ | មធ្យម |
| ១៣ | ឪពុកម្តាយសិស្សមួយចំនួនតែងតែបិទសិទ្ធិសេរីភាពរបស់កូន | ២.៥៩ | ១.០៦ | មធ្យម |
| **សរុប** | | **៣.២៦** | **០.៦៨** | **មធ្យម** |

នៅក្នុងផ្នែកទី៣ នៃកម្រងសំណួរសម្រាប់គ្រូបង្រៀន ដែលនិយាយពីឧបសគ្គរាំងនៃការចូលរួម និងបញ្ហាប្រឈមនានា គឺនៅមិនទាន់បានល្អប្រសើរនៅឡើយ យោងតាមលទ្ធផលសរុប ស្ថិតក្នុងកម្រិតមធ្យម (**M = ៣.២៦, S.D = ០.៦៨**)។ សូចនាករដែលមានលំដាប់មធ្យមភាគខ្ពស់ជាងគេ គឺចំណុចទី ១ «ឪពុកម្ដាយសិស្សគ្មានពេលវេលាច្រើននៅផ្ទះ ដោយជាប់រវល់ធ្វើការងារ ឬរកស៊ី» ស្ថិតក្នុងកម្រិត ល្អ (**M = ៣.៩១, S.D = ០.៩២**)។ ចំពោះសូចនាករដែលមានលំដាប់មធ្យមភាគទាបជាងគេ គឺចំណុចទី ១១ «ឪពុកម្ដាយសិស្ស ភាគច្រើនមិនធ្វើជាគំរូល្អ ដល់កូនបានម្ដងណាឡើយ» ស្ថិតក្នុងកម្រិត មធ្យម (**M = ២.៤៨, S.D = ១.០៤**)។

**តារាងទី៤.២១៖ សម្រាប់សិស្ស**

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ឪពុកម្ដាយខ្ញុំ គ្មានពេលវេលាច្រើននៅផ្ទះ ដោយជាប់រវល់ធ្វើការងារ ឬរកស៊ី | ៣.២០ | ១.២៨ | មធ្យម |
| ២ | ឪពុកម្ដាយខ្ញុំ មានកូនច្រើនដែលរៀនកម្រិតថ្នាក់ផ្សេងៗគ្នា ដូចនេះមិនបានជួយខ្ញុំក្នុងការអានសៀវភៅ ឬធ្វើលំហាត់ពីសាលាទេ | ២.៥៧ | ១.១៩ | ខ្សោយ |
| ៣ | ឪពុកម្ដាយខ្ញុំ មានកូនតូចៗច្រើនត្រូវមើលថែទាំនៅផ្ទះ | ២.០៦ | ១.២៩ | ខ្សោយ |
| ៤ | ឪពុកម្ដាយខ្ញុំ មិនមានចំណេះដឹងគ្រប់គ្រាន់ក្នុងការជួយកូននៅ មធ្យមសិក្សាទុតិយភូមិបានទេ | ២.៥៨ | ១.២៤ | ខ្សោយ |
| ៥ | ឪពុកម្ដាយខ្ញុំ បានទៅមើលកូន នៅសាលារៀនម្ដងម្កាល | ២.៤៤ | ១.៣១ | ខ្សោយ |
| ៦ | ឪពុកម្ដាយខ្ញុំមិនបានដឹងពីតម្រូវការចាំបាច់របស់សាលារៀនឡើយ | ២.៤៦ | ១.២៦ | ខ្សោយ |
| ៧ | ឪពុកម្ដាយខ្ញុំឧស្សាហ៍ទទួលការកោះអញ្ជើញចូលរួមប្រជុំនៅសាលា ពីបញ្ហាកូន | ១.៩៦ | ១.២៤ | ខ្សោយ |
| ៨ | ឪពុកម្ដាយខ្ញុំ បារម្ភហួងហែងខ្លាំងពេក | ២.១៥ | ១.១៨ | ខ្សោយ |

| | | | | |
|---|---|---|---|---|
| ៩ | ឪពុកម្តាយខ្ញុំ ចូលចិត្តប្រៀបធៀប ជាមួយកូនអ្នកដទៃ | ២.៣៤ | ១.៤១ | ខ្សោយ |
| ១០ | ឪពុកម្តាយខ្ញុំ ស្រែកគំហកនិងប្រើអំពើហិង្សាដាក់កូន | ១.៤៧ | ០.៩០ | ខ្សោយ |
| ១១ | ឪពុកម្តាយខ្ញុំ មិនធ្វើជាគំរូល្អ ដល់កូនបានម្តងណាឡើយ | ១.៤៣ | ០.៨៩ | ខ្សោយ |
| ១២ | ឪពុកម្តាយខ្ញុំ មិនចំណាយពេលវេលាជាមួយកូនសោះ | ១.៥២ | ០.៨៣ | ខ្សោយ |
| ១៣ | ឪពុកម្តាយខ្ញុំ តែងតែបិទសិទ្ធិសេរីភាពរបស់កូន | ១.៦០ | ០.៩៧ | ខ្សោយ |
| **សរុប** | | **២.១៤** | **០.៦១** | **ខ្សោយ** |

នៅក្នុងផ្នែកទី៣ នៃកម្រងសំណួរសម្រាប់សិស្ស ដែលនិយាយពីឧបសគ្គរាំងនៃការចូលរួម និងបញ្ហាប្រឈមនានា គឺនៅមិនទាន់បានល្អប្រសើរនៅឡើយ យោងតាមលទ្ធផលសរុប ស្ថិតក្នុងកម្រិតខ្សោយ (**M = ២.១៤, S.D = ០.៦១**)។ សូចនាករដែលមានលំដាប់មធ្យមភាគខ្ពស់ជាងគេ គឺចំណុចទី១ «ឪពុកម្តាយសិស្សគ្មានពេលវេលាច្រើននៅផ្ទះ ដោយជាប់រវល់ធ្វើការងារ ឬរកស៊ី» ស្ថិតក្នុងកម្រិតមធ្យម(**M = ៣.២០, S.D = ១.២៨**)។ ចំពោះសូចនាករដែលមានលំដាប់មធ្យមភាគទាបជាងគេ គឺចំណុចទី៧ «ឪពុកម្តាយខ្ញុំឧស្សាហ៍ទទួលការកោះអញ្ជើញចូលរួមប្រជុំនៅសាលា ពីបញ្ហាកូន» ស្ថិតក្នុងកម្រិត ខ្សោយ(**M = ១.៩៦, S.D = ១.២៤**)។

តារាងទី៤.២២៖ លទ្ធផលសរុបរួម សម្រាប់មាតាបិតា គ្រូបង្រៀន និងសិស្ស

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | មាតាបិតា | ២.២៧ | ០.៧៤ | ខ្សោយ |
| ២ | គ្រូបង្រៀន | ៣.២៦ | ០.៦៨ | មធ្យម |
| ៣ | សិស្ស | ២.១៤ | ០.៦១ | ខ្សោយ |
| | **សរុបរួម** | **២.៥៦** | **០.៦៨** | **ខ្សោយ** |

ផ្អែកតាមលទ្ធផលខាងលើបានបង្ហាញថា មាតាបិតា គ្រូបង្រៀន និងសិស្ស បានចូលរួមឆ្លើយជារួមចំពោះឧបសគ្គដែលតែងតែរាំងរបស់មាតាបិតា ក្នុងការចូលរួមចំណែកក្នុងការអប់រំ និងការសិក្សារបស់កូនៗនៅកម្រិតមធ្យមសិក្សាទុតិយភូមិ (**M = ២.៥៦, S.D = ០.៦៨**) ស្ថិតក្នុងកម្រិត ខ្សោយ។ ចំណែកឯ មាតាបិតា និងសិស្ស ហាក់ដូចគ្នាទាំងស្រុង ដែលស្ថិតក្នុងកម្រិតខ្សោយ ដូចគ្នា។

**( M = ២.២៧, S.D = ០.៧៤ ), ( M = ២.១៤, S.D = ០.៦១ ) ។**

## ៤.៣ ការពិភាក្សា

### ៤.៣.១ ការពិភាក្សានៅលើលទ្ធផលស្រាវជ្រាវ ផ្នែកទី១

យោងតាមលទ្ធផលនៃការសេរុបរួម របស់ មាតាបិតា គ្រូបង្រៀន និងសិស្ស រួចមកយើងឃើញថា លទ្ធផលទាំងបីផ្នែកគឺអាចវាយតម្លៃបានថា ទស្សនៈរបស់មាតាបិតាសិស្ស ចំពោះតួនាទីរបស់ខ្លួន ក្នុងការចូលរួមចំណែកជួយការអប់រំ និងការសិក្សារបស់កូនៗ នៅមធ្យមសិក្សាទុតិយភូមិ គឺពិតជាអាចទទួលយកបានហើយ។ ជាក់ស្តែង មាតាបិតាសិស្ស ប្រកាន់ខ្ជាប់នូវតួនាទីរបស់ខ្លួនដែលជាអ្នក មើលថែ ឃុំគ្រងកូនបានគ្រប់ពេលនោះ ការសិក្សារបស់ពួកគេពិតជាទទួលជោគជ័យ ជាក់ជាមិនខាន។ ម្យ៉ាងវិញទៀត គ្រូបង្រៀនខិតខំពង្រឹងសមត្ថភាពបង្រៀន ស្រាវជ្រាវ ចងក្រង ផ្តល់គន្លឹះបច្ចេកទេសល្អៗ ថ្មីៗ ដល់សិស្សឲ្យអស់ពីសមត្ថភាពទៀតនោះ គឺពិតជាទទួលបានលទ្ធផលខ្ពស់យ៉ាងពិតប្រាកដ។ លើសពីនេះទៀត សិស្សខ្លួនឯងដែលជាទំពាំងស្នងឫស្សីរបស់សង្គម របស់គ្រួសារ ត្រូវតែចូលរួម និងខិតខំរៀនសូត្រតាមលទ្ធភាពដែលខ្លួនមាន។ ត្រូវគិតគូរពីជោគវាសនារបស់ខ្លួនឯង សម្រាប់កិត្តិយស ឪពុកម្តាយ គ្រូបង្រៀន ដែលបានចំណាយពេលវេលា ទ្រព្យសម្បត្តិ ចំណេះដឹង សព្វបែបយ៉ាងទៅឲ្យខ្លួន។ ត្រូវអភិវឌ្ឍខ្លួនឲ្យដើរទាន់សម័យឌីជីថលនៅសតវត្សទី២១យើងនេះ។

### ៤.៣.២ ការពិភាក្សានៅលើលទ្ធផលស្រាវជ្រាវ ផ្នែកទី២

តាមរយៈលទ្ធផលដែលបានបង្ហាញនៅក្នុងផ្នែកទី៣ នៃកម្រងសំណួរទាំងបីផ្នែក (មាតាបិតា គ្រូបង្រៀន និងសិស្ស) យើងអាចយល់បានថា ឧបសគ្គរាំងនៃការចូលរួម និងបញ្ហាប្រឈមនានា គឺពិតជាមានការលំបាកច្រើន ក្នុងការអនុវត្ត ទាំងមាតាបិតា គ្រូបង្រៀន និងសិស្ស ផងដែរ។ តែទោះបីជាមានឧបសគ្គរាំងយ៉ាងណាក្តី ក៏មិនអាចបញ្ឈប់ការចូលរួមចំណែក ក្នុងការអប់រំ និងជួយកូនៗនៅមធ្យមសិក្សាទុតិយភូមិពី ឪពុកម្តាយសិស្សបានដែរ។ ពួកគាត់នៅតែបន្តជួយ និងលះបង់ពេលវេលាការងារ មកជួយមើលផ្នែកអប់រំដែលកូនគាត់កំពុងតែសិក្សានៅតាមវិទ្យាល័យនីមួយៗ។ ព្រោះថា អនាគត និងជោគវាសនារបស់កូនគាត់ គឺស្ថិតនៅលើការទទួលបានការអប់រំ និងងាយស្រួលរកការងារធ្វើដើម្បីជួយពួកគាត់វិញនៅថ្ងៃអនាគតផងដែរ។ ទាំងនេះវាជារឿងមួយសំខាន់ណាស់ដែលមាតាបិតាគ្រប់រូប ត្រូវតែយកចិត្តទុកដាក់និង គិតគូរដល់កូនៗរបស់ខ្លួនជាចាំបាច់។

# ជំពូក ៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

# ជំពូក ៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១ សង្ខេបលទ្ធផល

លទ្ធផលរួម ចំពោះការចូលរួមឆ្លើយរបស់ មាតាបិតា គ្រូបង្រៀន និងសិស្ស សម្រាប់ផ្នែកទី ១៖ មាតាបិតា ស្ថិតក្នុងកម្រិត ល្អ(M =៣.៨៩, S.D=0.៤៦) គ្រូបង្រៀន ស្ថិតក្នុងកម្រិត ល្អ (M =៣.៦៣, S.D =0.៥២) សិស្ស ស្ថិតក្នុងកម្រិត ល្អ(M=៣.៤៥, S.D =0.៥២)។ សរុបរួម ស្ថិតក្នុងកម្រិត ល្អ (M = ៣.៦៦, S.D =0.៥0)។

យោងតាមលទ្ធផលនៃការសរុបរួម របស់ មាតាបិតា គ្រូបង្រៀន និងសិស្ស រួចមកយើង ឃើញថា លទ្ធផលទាំងបីផ្នែកគឺអាចវាយតម្លៃបានថា ទស្សនៈរបស់មាតាបិតាសិស្ស ចំពោះតួនាទី របស់ខ្លួន ក្នុងការចូលរួមចំណែកជួយការអប់រំ និងការសិក្សារបស់កូនៗ នៅមធ្យមសិក្សាទុតិយភូមិ គឺពិតជាអាចទទួលយកបានហើយ ពីព្រោះលទ្ធផលសរុបរួមគឺស្ថិតក្នុងកម្រិតល្អ (M =៣.៦៦, S.D = 0.៥0)។ មាតាបិតា ស្ថិតក្នុងចំណាត់ថ្នាក់ទី១ ក្នុងចំណោមផ្នែកទាំងបី(មាតាបិតា គ្រូបង្រៀន និង សិស្ស) គឺ (M =៣.៨៩, S.D =0.៤៦) ដែលស្ថិតក្នុងកម្រិតមធ្យម រីឯសិស្សវិញបានទទួលចំណាត់ ថ្នាក់ទាបជាងគេគឺ (M=៣.៤៥, S.D =0.៥២) ដែលស្ថិតក្នុងកម្រិតល្អ ដូចគ្នា។

លទ្ធផលរួម ការចូលរួមឆ្លើយរបស់ មាតាបិតា គ្រូបង្រៀន និងសិស្ស សម្រាប់ផ្នែកទី២៖ មាតាបិតា ស្ថិតក្នុងកម្រិតខ្សោយ (M=២.២៧ S.D=0.៧៤) គ្រូបង្រៀន ស្ថិតក្នុងកម្រិតមធ្យម (M= ៣.២៦, S.D = 0.៦៨) សិស្ស ស្ថិតក្នុងកម្រិតខ្សោយ (M= ២.១៤, S.D = 0.៦១)។ សរុបរួម ស្ថិតក្នុង កម្រិតខ្សោយ (M= ២.៥៦, S.D = 0.៦៨)។

ផ្អែកតាមលទ្ធផលខាងលើបានបង្ហាញថា មាតាបិតា គ្រូបង្រៀន និងសិស្ស បានចូលរួមឆ្លើយជារួម ចំពោះឧបសគ្គដែលតែងតែរារាំងរបស់មាតាបិតា ក្នុងការចូលរួមចំណែកក្នុងការអប់រំ និងការសិក្សារបស់កូនៗនៅ កម្រិតមធ្យមសិក្សាទុតិយភូមិ **(M = ២.៥៦, S.D = 0.៦៨)** ស្ថិតក្នុងកម្រិត ខ្សោយ។ ចំណែកឯ មាតាបិតា និង សិស្ស ហាក់ដូចគ្នាទាំងស្រុង ដែលស្ថិតក្នុងកម្រិតខ្សោយ ដូចគ្នា **(M = ២.២៧, S.D = 0.៧៤), (M = ២.១៤, S.D = 0.៦១)**។

## ៥.២ ការពិភាក្សា

ទស្សនៈរបស់មាតាបិតាសិស្ស ចំពោះតួនាទីរបស់ខ្លួន ក្នុងការចូលរួមចំណែកជួយការអប់រំ និងការសិក្សារបស់កូនៗ មានភាពចាំបាច់ខ្លាំងណាស់ ព្រោះវាជាតួនាទីនិងកាតព្វកិច្ចរបស់ឪពុកម្តាយដើម្បីលើកកម្ពស់ការសិក្សារបស់កូនឱ្យទទួលបានជោគជ័យ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ការចូលរួមចំណែកជួយការអប់រំ និងការសិក្សារបស់កូននៅកម្រិតមធ្យមសិក្សាទុតិយភូមិ នៅរាជធានីភ្នំពេញ ស្ថិតក្នុងកម្រិតមួយដែលមិនទាន់ឆ្លើយតបទៅនឹងអ្វីដែល សាលារៀន ក៏ដូចជាក្រសួងអប់រំ យុវជន និងកីឡា ចង់បាននៅឡើយ។ ផ្អែកទៅលើលទ្ធផលនៃការស្រាវជ្រាវនេះបង្ហាញឱ្យយើងឃើញថា នៅក្នុងដំណើរការនៃការប្រព្រឹត្តទៅនៃការចូលរួមចំណែករបស់ឪពុកម្តាយចំពោះតួនាទីរបស់ខ្លួនពាក់ព័ន្ធនិងការអប់រំកូនមិនទាន់បានគ្រប់ជ្រុងជ្រោយ១០០%នៅឡើយទេ ព្រោះមានតែឪពុកម្តាយមួយចំនួន ដែលបានចូលរួមចំណែកជួយកូនក្នុងការធ្វើកិច្ចការផ្ទះ ជួយបង្ហាត់បង្រៀន ពន្យល់ ណែនាំ ដាស់តឿន និងពិនិត្យតាមដានការសិក្សាកូនជាប្រចាំ។ ដោយយោងទៅលើលទ្ធផលនៃការស្រាវជ្រាវខាងលើ គឺមានតែឪពុកម្តាយមួយចំនួនតូចប៉ុណ្ណោះដែលអាចជួយកូនបាន នៅក្នុងកម្រិតមធ្យមសិក្សាទុតិយភូមិ។ រីឯការទំនាក់ទំនងរវាងឪពុកម្តាយនិងសាលារៀន នៅមានកម្រិតនៅឡើយ។ ក្នុងករណីនេះឪពុកម្តាយសិស្សមិនសូវមានពេលទំនេរ ឬមួយបានឆ្លៀតពេលទៅសាលារៀនដើម្បីធ្វើការទំនាក់ទំនងដោយផ្ទាល់ជាមួយនិងគណៈនាយក គ្រូប្រចាំថ្នាក់ ឬគ្រូបង្រៀនតាមមុខវិជ្ជា នោះឡើយ។ ចំណុចអវិជ្ជមានខ្លះក៏បណ្តាលមកពីសាលារៀនផងដែរ មិនបានបង្កបរិយាកាសការជួបជុំ រវាងសាលារៀន មាតាបិតាសិស្ស និងភាគីពាក់ព័ន្ធផ្សេងទៀត។ សាលារៀនក៏មិនសូវបានអញ្ជើញឪពុកម្តាយឲ្យចូលរួមក្នុងសកម្មភាពផ្សេងៗរបស់សាលាផងដែរ។ សាលារៀនហាក់មើលរំលងចំពោះតួនាទីរបស់មាតាបិតា ដែលជាកម្លាំងចលករមួយដ៏សំខាន់ក្នុងការរុញច្រាន និងលើកទឹកចិត្តដល់កូនគ្រប់រូបឲ្យសម្រេចជោគជ័យក្នុងការសិក្សា។ ការសិក្សានេះបានរកឃើញផងដែរ នូវបញ្ហាប្រឈម និងឧបសគ្គមួយចំនួន ដែលជះឥទ្ធិពលដល់ការចូលរួមចំណែករបស់ឪពុកម្តាយចំពោះការអប់រំកូន រួមមានដូចជា៖ ឪពុកម្តាយកង្វះចំណេះដឹងក្នុងកម្រិតមធ្យមសិក្សាទុតិយភូមិ កត្តាកង្វះពេលវេលា បញ្ហាជីវភាពគ្រួសារ (គ្រួសារខ្លះមានកូនកំពុងរៀនច្រើននាក់នៅក្នុងបន្ទុក) កង្វះទំនាក់ទំនងរវាងឪពុកម្តាយជាមួយ

សាលារៀន និងលោកគ្រូ អ្នកគ្រូ ដែលជាហេតុធ្វើឱ្យ ឪពុកម្តាយមួយភាគធំ ទទួលបានព័ត៌មានមិនគ្រប់គ្រាន់ទាក់ទងទៅនឹងការសិក្សារបស់កូន ឬឪពុកម្តាយចំនួនមិនបានផ្តល់ព័ត៌មានត្រឡប់ទៅសាលាវិញនោះទេ។ បញ្ហាប្រឈមខ្លាំងគឺកង្វះចំណេះដឹងរបស់ឪពុកម្តាយ ។ ឪពុកម្តាយមានការលំបាកផងដែរ ក្នុងការជួយធ្វើកិច្ចការផ្ទះ ឬបង្ហាត់បង្រៀនកូន ដោយសារពួកគាត់ទទួលបានការអប់រំបានតិចតួច តែទោះបីជាពួកគាត់រៀនបានត្រឹមកម្រិតទុតិយភូមិ ឬខ្ពស់ជាងកម្រិតទុតិយភូមិក៏ដោយ ក៏នៅតែជាឧបសគ្គសម្រាប់ពួកគាត់ដដែល។ ស្របជាមួយគ្នានេះដែរ កត្តាកង្វះពេលវេលាក៏ជាឧបសគ្គដែលរាំងស្ទះដល់ដំណើរការចូលរួមដែរ ដោយឪពុកម្តាយខ្លះមានការមមារញឹកក្នុងការបំពេញការងារប្រចាំថ្ងៃ ឬប្រកបរបរផ្សេងៗដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ មិនសូវមានពេលវេលាគ្រប់គ្រាន់ក្នុងការជួយអប់រំបង្ហាត់បង្រៀនកូនបានដែរ។ ប៉ុន្តែទន្ទឹមនឹងនេះ យោងតាមលទ្ធផលនៃសិក្សាស្រាវជ្រាវនេះបង្ហាញឱ្យឃើញថា ឪពុកម្តាយភាគច្រើនយល់ច្បាស់ពីតួនាទីរបស់ខ្លួនក្នុងការចូលរួមចំណែក ចំពោះការអប់រំកូន ចង់ឱ្យកូនបន្តការសិក្សាបានខ្ពស់ ដោយធ្វើការជំរុញ និងលើកទឹកចិត្តកូនឱ្យខិតខំរៀនសូត្រជាប្រចាំ ហើយឪពុកម្តាយក៏បានអប់រំទូន្មានកូន និងប្រាប់ពីសារៈសំខាន់នៃការសិក្សាដល់កូនជាប្រចាំផងដែរ។ ជាមួយគ្នានេះដែរនាយក នាយិកាសាលា លោកគ្រូ អ្នកគ្រូក៏បានយកចិត្តទុកដាក់ និងចូលរួមចំណែកយ៉ាងសកម្ម ព្យាយាមទំនាក់ទំនងដោយផ្ទាល់ ឬដោយប្រយោលជាមួយនិងឪពុកម្តាយសិស្ស ក្នុងការជំរុញ និងលើកទឹកចិត្តដល់ឪពុកម្តាយឲ្យចូលរួមចំណែកចំពោះការអប់រំ និងការសិក្សារបស់កូនពួកគាត់បានជាអតិបរមា។

## ៥.៣ សំណូមពរ

### ១ គណៈគ្រប់គ្រងសាលារៀន និងលោកគ្រូ អ្នកគ្រូ

- គួរបន្តធ្វើការជំរុញ និងលើកទឹកចិត្តដល់ឪពុកម្តាយសិស្ស ឱ្យចូលរួមចំណែកចំពោះការអប់រំ និងការសិក្សារបស់កូនៗបន្តទៀត។
- ផ្តល់ព័ត៌មាន ពីការសិក្សារបស់សិស្សជាប្រចាំ ទៅកាន់ឪពុកម្តាយរបស់ពួកគេ។
- អញ្ជើញឪពុកម្តាយសិស្សឱ្យចូលរួមសកម្មភាពនានារបស់សាលារៀន តាមដែលអាចធ្វើទៅបាន។

- ធ្វើការសហការជាមួយអាជ្ញាធរដែនដី ភូមិ ឃុំ/សង្កាត់ ដើម្បីធ្វើការផ្សព្វផ្សាយ និងជំរុញការចូលរួមចំណែករបស់ឪពុកម្ដាយ ទៅតាមស្ថានភាពជាក់ស្ដែង និងពេលវេលាសមស្រប។
- សាលារៀន គួរតែបង្កើតគណៈកម្មការដែលទទួលបន្ទុកផ្នែកទំនាក់ទំនងជាមួយឪពុកម្ដាយសិស្ស ដើម្បីផ្ដល់ព័ត៌មានជានាការលើកកម្ពស់ ការទំនាក់ទំនងរវាងសាលារៀន និងឪពុកម្ដាយសិស្សឲ្យបានខ្លាំងក្លា និងសកម្ម។

## ២ ឪពុកម្ដាយ ឬអ្នកអាណាព្យាបាល

- ឧស្សាហ៍ទំនាក់ទំនងសាកសួរព័ត៌មានទាក់ទងទៅនឹងការសិក្សារបស់កូន ឱ្យបានទៀងទាត់
- ផ្ដល់ព័ត៌មានត្រឡប់ទៅសាលាវិញ ក្នុងករណីកូនមិនចង់ទៅរៀន ឬចង់បោះបង់ការសិក្សា
- ព្យាយាមជួយកូនធ្វើកិច្ចការផ្ទះ និងបង្ហាត់បង្រៀនទៅតាមលទ្ធភាពជាក់ស្ដែង ពិនិត្យតាមដានការសិក្សា របស់កូនឱ្យបានទៀងទាត់ និងជាប្រចាំ។
- ជួយតាមដានកូន ក្នុងពេលដែលពួកគេ ប្រើទូរស័ព្ទដៃ ឬប្រើកុំព្យូទ័រ ដែលមិនទាក់ទងការសិក្សា (ចៀសវាងការលេងហ្គេមផ្សេងៗ)។

## ៣ សិស្ស

- ចង់ឲ្យឪពុកម្ដាយ ជួយកូនៗឲ្យបានច្រើន លើការសិក្សា ដូចជា ផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុ សម្ភារសិក្សា ឬមធ្យោបាយក្នុងការធ្វើដំណើរទៅសាលារៀន។ល។
- ឲ្យឪពុកម្ដាយ មានពេលវេលាសម្រាប់កូនៗ ដោយជំរុញ និងលើកទឹកចិត្តឲ្យកូនខំរៀនសូត្រប្រឡងជាប់បាននិទ្ទេសល្អ។

➢ ក្រសួងអប់រំ យុវជន និងកីឡា រួមជាមួយ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡាស្រុក ខណ្ឌ សហការគ្នា ដើម្បីកសាងឯកសារគតិយុត្ត ណែនាំដល់ឪពុក ម្ដាយ ឲ្យជួយក្នុងការអប់រំ និងជួយកូនក្នុងការសិក្សាឲ្យបានទូលំទូលាយ។

- ក្រសួងអប់រំ យុវជន និងកីឡា ត្រូវមានគោលការណ៍ជាក់ណាមួយ ដើម្បីបំផុសស្មារតី ឲ្យឪពុក ម្តាយសិស្ស ស្វែងយល់កាន់តែស៊ីជំរៅ និងយកចិត្តទុកដាក់ ចំពោះការសិក្សារបស់កូនៗ ឲ្យបានពេញលេញ។
- ក្រសួងអប់រំ យុវជន និងកីឡា គួរមានកម្មវិធី ផ្សព្វផ្សាយ បំផុសដល់មាតាបិតា ឲ្យចាប់អារម្មណ៍លើវិស័យអប់រំ ឲ្យបានញឹកញាប់ ជាពិសេសឲ្យពួកគាត់ ចេះគិតគូរដល់ការសិក្សារបស់កូនៗ។

## ៥.៤ ការសិក្សាស្រាវជ្រាវបន្ត

ការស្រាវជ្រាវនេះបានធ្វើឡើងតែ ៥វិទ្យាល័យ ដែលត្រូវបានជ្រើសរើសចេញពី៥ខណ្ឌក្នុងចំណោមខណ្ឌ ទាំង១៤ ក្នុងរាជធានីភ្នំពេញតែប៉ុណ្ណោះ។ ការសិក្សានេះធ្វើឡើងក្នុងបរិបទកូវីដ១៩ ដែលមានការឆ្លងរាលដាលមិនមែនជាទ្រង់ទ្រាយធំ ឬឆ្លងចូលក្នុងសហគមន៍នោះដែរ។ ទោះបីយ៉ាងនេះក្តី ក៏នៅមានការលំបាកក្នុងការចុះទៅប្រមូលទិន្នន័យ ដែលជាបញ្ហាប្រឈមនោះគឺឪពុកម្តាយសិស្ស គាត់មិនបានជ្រួតជ្រាបពីគោលបំណងរបស់អ្នកស្រាវជ្រាវ។ ដោយឪពុកម្តាយសិស្សខ្លះបានបដិសេធក្នុងការផ្តល់ចម្លើយទាំងស្រុង ដោយគាត់មិនព្រមសហការជាមួយយើងនោះឡើយ។ កត្តាកូវីដ១៩ ក៏ជាឧបសគ្គចំពោះការចុះប្រមូលទិន្នន័យព័ត៌មានផងដែរ។ តែទោះបីជាមានបញ្ហាបន្តិចបន្តួចយ៉ាងណាក៏ដោយ ក៏អ្នកស្រាវជ្រាវ បានខិតខំពុះពារ ចុះទៅប្រមូលទិន្នន័យបានគ្រប់ចំនួនតាមការគ្រោងទុកដែរ។ អ្នកស្រាវជ្រាវយល់ឃើញថា ភាគសំណាកដែលប្រមូលបាន យកមកវិភាគ និងបកស្រាយនៅក្នុងជំពូកទី៤នេះ មិនបានឆ្លើយតបទាំងស្រុងទៅនឹងបញ្ហាប្រឈម ឬឧបសគ្គ ផ្សេងៗដែលបានកើតឡើង ក្នុងរាជធានីភ្នំពេញទាំងមូលទេ ដូចនេះអ្នកស្រាវជ្រាវទុកលទ្ធភាព ជូនដល់អ្នកសិក្សាជំនាន់ក្រោយ ដើម្បីធ្វើការស្រាវជ្រាវបន្តទៀត ដើម្បីឲ្យវិស័យអប់រំ នៅកម្ពុជាទទួលបានគុណភាពខ្ពស់ តាមស្តង់ដារអន្តរជាតិ ក៏ដូចជាក្នុងក្របខណ្ឌអាស៊ាន។ អ្នកស្រាវជ្រាវសង្ឃឹមថា អ្នកស្រាវជ្រាវបន្ត ដែលបានជ្រើសរើសយកប្រធានបទ ដែលមានខ្លឹមសារប្រហាក់ប្រហែលគ្នានេះ និងខិតខំស្រាវជ្រាវ រកគំនិតថ្មីៗ ដើម្បីកែលម្អ និងមានចក្ខុវិស័យច្បាស់លាស់ ដែលអាចឲ្យមជ្ឈដ្ឋានទូទៅអាចទទួលយកបាន លើស្នាដៃស្រាវជ្រាវរបស់ខ្លួន។

## ឯកសារយោង


- ក្រសួងអប់រំ យុវជន និងកីឡា (២០២១) សេចក្ដីណែនាំប្រតិបត្តិយុទ្ធសាស្ត្រសហគមន៍សាលារៀន។ ដកស្រង់ចេញពីគេហទំព័រ www.moeys.gov.kh រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

- ក្រសួងអប់រំ យុវជន និងកីឡា (២០១៩) *សៀវភៅណែនាំប្រតិបត្តិ ស្ដីពីការគ្រប់គ្រងតាមសាលារៀនសម្រាប់សាលាបឋមសិក្សាសាធារណៈ*។ ដកស្រង់ចេញពីគេហទំព័រ www.moeys.gov.kh រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

- ក្រសួងអប់រំ យុវជន និងកីឡា (២០១៨) *សៀវភៅណែនាំប្រតិបត្តិ ស្ដីពីការគ្រប់គ្រងតាមសាលារៀន*។ ដកស្រង់ចេញពីគេហទំព័រ www.moeys.gov.kh រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

- So Sovannara (2011) Parental Involvement in Children's Educantion in one Primary School.

- ក្រសួងអប់រំ យុវជន និងកីឡា (២០១៩) *ផែនទីបង្ហាញផ្លូវការអប់រំមធ្យមកម្ពុជាឆ្នាំ២០៣០*។ ដកស្រង់ចេញពីគេហទំព័រ www.moeys.gov.kh រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

- ក្រសួងអប់រំយុវជននិងកីឡា (២០២១) *សេចក្ដីណែនាំប្រតិបត្តិយុទ្ធសាស្ត្រសហគមន៍សាលារៀន*។ ដកស្រង់ចេញពីគេហទំព័រ www.moeys.gov.kh រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

- Chhorn Bora (2020) Parental Involvement with child'sEducation in Primary School in Phnom Penh

- រាជរដ្ឋាភិបាលកម្ពុជា (២០០៧) *ច្បាប់ស្ដីពីការអប់រំ*។ ដកស្រង់ចេញពីគេហទំព័រ www.moeys.gov.kh រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

- ប៊ុត សារ៉េង្ស (២០១៩) *មាតាបិតាជាព្រះក្នុងផ្ទះ*។ ដកស្រង់ចេញពីគេហទំព័រ http://5000-years.org/kh/read/1332

- Javarov (2015) Factors Affecting Parental Involvement in Education: The Analysis of Liturature.

- ក្រសួងអប់រំ យុវជន និងកីឡា (២០១៣) *សារៈសំខាន់នៃទំនាក់ទំនងរវាងសាលារៀន និងសហគមន៍។* ដកស្រង់ចេញពីគេហទំព័រ https://www.khsearch.com/qna/1796

- Longbeachunifiedschooldistrict (2017) *ច្បាប់ទាក់ទងការរួមចំណែកពីមាតាបិតា នៅតាមសាលារៀនទទួលជំនួយTitleI* ដកស្រង់ចេញពីគេហទំព័រ https://www.lbschools.net/Asset/Files/BOE/Policies/BP_6020-1-KH.pdf

- S.Wilder (2014) *ឥទ្ធិពលនៃការចូលរួមរបស់មាតាបិតាលើសមិទ្ធផលសិក្សា* ដកស្រង់ចេញពីគេហទំព័រ https://www.lbschools.net/Asset/Files/BOE/Policies/BP_6020-1-KH.pdf

- P.Willems និង Marie F.Doan (2005) *ការពិនិត្យមើលទំនាក់ទំនងរវាងមាតាបិតា ការចូលរួម និងការលើកទឹកចិត្តសិស្ស*

- Fresfnews (2017) *ការបង្កើតទំនាក់ទំនងជាប់លាប់រវាងមាតាបិតាសិស្ស និងគ្រូបង្រៀន ជាកត្តាល្អជួយកែតម្រូវចំណុចខ្វះខាត និងបណ្តុះគំនិតល្អដល់កូនៗ*

- University of Terova (2016) *The Role of Parents in the Education of Children.*

- ខ្មែរអ្នកអប់រំ (២០២២) *លក្ខណៈទាំង១០ របស់ឪពុកម្តាយ ដែលធ្វើឲ្យកូនទទួលបានជោគជ័យ។* ដកស្រង់ចេញពីគេហទំព័រ http://khmereducator.org/post/article/627/

- ASM (2021) *គន្លឹះអប់រំកូនៗរបស់ជនជាតិជប៉ុន ដែលឪពុកម្តាយគ្រប់រូបគួរស្វែងយល់។* ដកស្រង់ចេញពីគេហទំព័រ https://education.ams.com.kh

- National Assembly Human Services (2004). *Parental Involve in Education*

- Healthy Time (2019) *កំហុសឆ្គងទាំង ៦យ៉ាងរបស់ឪពុកម្តាយដែលរាំងភាពជោគជ័យរបស់កូនៗ។* ស្រង់ចេញពីគេហទំព័រ https://healthtime.tips/km/library/article/2056

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ ក

# លិខិតឆានារបស់ក្រសួងអប់រំ យុវជន និងកីឡា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ: ២៣៤១ អយក.វដ

ថ្ងៃ សុក្រ ១៣កើត ខែ ចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ មេសា ឆ្នាំ២០២២

**ជម្រាបជូន**

**លោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត**

**កម្មវត្ថុ៖** ការចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩។

**យោង៖** -បទប្បញ្ញត្តិស្ដីពីការបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រប់អប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

- ផែនការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩និងទី១០ ឆ្នាំសិក្សា២០២១-២០២២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប លោក លោកស្រីប្រធាន ជ្រាបថា៖ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៩ ចំនួន៥៨នាក់ នឹងចុះប្រមូលទិន្នន័យនៅតាមរាជធានីខេត្តនានា ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ពីថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២២។

អាស្រ័យហេតុនេះ សូម លោក លោកស្រីប្រធាន ជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់។

សូម លោក លោកស្រីប្រធាន ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**

- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- អង្គភាពក្រោមឱវាទក្រសួងអយក "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីជន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ វិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ៧៤៦៥ អយក.វគន

## លិខិតឧទ្ទេសនាម

យោង ៖ -បទប្បញ្ញត្តិស្ដីពីការបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ និងទី១០ ឆ្នាំសិក្សា ២០២១-២០២២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជាគ្រូដឹកនាំគោល និងគ្រូដឹកនាំរង សម្រាប់ការសរសេរនិក្ខេបបទរបស់និស្សិតបង់ថ្លៃសេវាសិក្សា ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ ឆ្នាំសិក្សា២០២១-២០២២ ដែលបានទទួលការបណ្ដុះបណ្ដាលនៅវិទ្យាស្ថានជាតិអប់រំ៖

| ល.រ | គោត្តនាម នាម គ្រូដឹកនាំគោល | គោត្តនាម នាម គ្រូដឹកនាំរង | ប្រធានបទនិក្ខេបបទស្រាវជ្រាវ | គោត្តនាម នាម និស្សិត |
|---|---|---|---|---|
| ១ | បណ្ឌិត គួយ សុគាន | លោកស្រី ប៊ុន សុផានី | គុណវុឌ្ឍិគ្រូបង្រៀនផ្នែកអប់រំបច្ចេកទេសជះឥទ្ធិពលដល់ការបង្រៀន និងរៀនលើជំនាញឯកទេសអគ្គិសនី នៅវិទ្យាល័យចំណេះទូទៅ និង បច្ចេកទេស | កែវ សោភ័ណ |
| ២ | លោក ម៉ន មុនិន្ទ | បណ្ឌិត ឈាង សង្វាត | ទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំគ្រប់គ្រង និងការចុះឈ្មោះចូលរៀនរបស់សិស្សនៅកម្រិតបឋមសិក្សាក្នុងរាជធានីភ្នំពេញ | ជា ច័ន្ទសុភ័ក្រ |
| ៣ | បណ្ឌិត ឈូក ច័ន្ទធាយា | ឯកឧត្តមបណ្ឌិត ឌី ខាំបូលី | ទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំរបស់នាយកសាលា ជាមួយនឹងអត្តសញ្ញាណវិជ្ជាជីវៈនិងភាពពេញចិត្តក្នុងការបំពេញការងាររបស់គ្រូ | ថន ឌីណា |
| ៤ | លោក ឌី បុណ្ណា | បណ្ឌិត ឡឹយ សុគា | ស្ថានភាពនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យារបស់គ្រូមានផលជះដល់ដំណើរការសិក្សារបស់សិស្សថ្នាក់វិទ្យាសាស្ត្រពិត នៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តរតនគិរី | ទ្រី វាសនា |

| | | | | |
|---|---|---|---|---|
| ១៧ | បណ្ឌិត ឈិញ នីដា | បណ្ឌិត លី គិមឡុង | ការប្រើប្រាស់វិធីសាស្ត្របែបចម្រុះលើការបង្រៀន និងរៀន នៅកម្រិតមធ្យមសិក្សា | ឡុង សីម៉ា |
| ១៨ | បណ្ឌិត នី វង្ឃា | បណ្ឌិត ឈិញ ស៊ីថា | តួនាទីរបស់មាតាបិតាសិស្សក្នុងការរួមចំណែកការសិក្សារបស់កូនៗនៅវិទ្យាល័យក្នុងខណ្ឌមានជ័យ រាជធានីភ្នំពេញ | អ៊ឹម សៀន |
| ១៩ | បណ្ឌិត ឡឹយ សុគា | បណ្ឌិត អែ សុងហ៊ាង | ការគ្រប់គ្រងគុណភាពការបង្រៀន និងរៀនមុខវិជ្ជាគណិតវិទ្យានៅសាលាមធ្យមសិក្សាបឋមភូមិ | អ៊ុន ម៉ុល |
| ២០ | ឯកឧត្តមបណ្ឌិត ជ័យ សារិន | ឯកឧត្តមបណ្ឌិត សិត សេង | ការដឹកនាំគ្រប់គ្រងថ្នាក់រៀនរបស់គ្រូឧទ្ទេសមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជា នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកណ្ដាល | សុខ ផល្លី |
| ២១ | ឯកឧត្តមបណ្ឌិត សិត សេង | បណ្ឌិត គួយ សូគាន | ទស្សនៈរបស់គ្រូ នាយកវិទ្យាល័យចំពោះផែនការយុទ្ធសាស្ត្រក្នុងការរៀបចំបរិស្ថានសាលារៀនស្របតាមបរិបទការអប់រំថ្មី (ករណីសិក្សា ខេត្តព្រៃវែង) | រឹម សារាត់ |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវទទួលភារកិច្ចអនុវត្តការងារឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហ ១៣រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
- -អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- -ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- -គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- -សាមីខ្លួន "ដើម្បីអនុវត្ត"
- -កាលប្បវត្តិ -ឯកសារ រដអ

## ឧបសម្ព័ន្ធ ខ

## កម្រងសំណួរ

# កម្រងសំណួរសម្រាប់លោកគ្រូ អ្នកគ្រូ

**សូមគោរពជម្រាបសួរ លោក លោកស្រី ដែលជាបុគ្គលិកអប់រំ ជាទីរាប់អាន**!

ខ្ញុំបាទ ឈ្មោះ **អ៊ឹម សៀន** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ នៅវិទ្យាស្ថានជាតិអប់រំ។ ខ្ញុំបាទកំពុងធ្វើការសិក្សាស្រាវជ្រាវ សរសេរនិក្ខេបបទ ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ក្រោមប្រធានបទ **«ទស្សនៈរបស់មាតាបិតាសិស្ស ចំពោះតួនាទីរបស់ខ្លួន ក្នុងការចូលរួមចំណែកជួយការអប់រំ និងការសិក្សារបស់កូនៗ នៅមធ្យមសិក្សាទុតិយភូមិ» (ករណីសិក្សា នៅរាជធានីភ្នំពេញ)។**

អាស្រ័យហេតុនេះសូម លោក លោកស្រី មេត្តាជួយផ្តល់ចម្លើយចំពោះសំណួរខាងក្រោម ដោយអនុគ្រោះ។ រាល់ចម្លើយ និងព័ត៌មានដែលទទួលបានពីលោក លោកស្រី នឹងត្រូវបានរក្សាជាការសម្ងាត់។ ហើយឯកសារនេះត្រូវបានយកមកប្រើតែក្នុងការសិក្សាស្រាវជ្រាវនេះតែប៉ុណ្ណោះ។

ខ្ញុំបាទសូមថ្លែងអំណរគុណ ដល់លោក លោកស្រី ដែលបានជួយសហការ និងចំណាយពេលដ៏មានតម្លៃជាមួយខ្ញុំ ក្នុងការចូលរួមអភិវឌ្ឍការអប់រំនៅវិទ្យាល័យនេះឲ្យទទួលបាននូវប្រសិទ្ធភាពខ្ពស់។

**ផ្នែកទី១៖ ព័ត៌មានទូទៅ**

សូមលោកគ្រូ អ្នកគ្រូ គូសសញ្ញា (√) ក្នុងប្រអប់ ☐ ចម្លើយនៃសំណួរនីមួយៗតាមភាពជាក់ស្តែងរបស់លោកគ្រូ អ្នកគ្រូ ដែលត្រូវជ្រើសរើសដូចខាងក្រោម៖

១- ភេទ៖ ☐១.ប្រុស ☐២.ស្រី

២- អាយុ៖ ☐១.តិចជាង២៥ឆ្នាំ ☐២.ពី២៦-៣០ឆ្នាំ ☐៣.ពី៣១-៣៥ឆ្នាំ

☐៤.ពី៣៦-៤០ឆ្នាំ ☐៥.លើសពី៤០

៣- កម្រិតវប្បធម៌៖ ☐១.ទាបជាងបរិញ្ញាបត្រ ☐២.បរិញ្ញាបត្រ ☐៣.បរិញ្ញាបត្រជាន់ខ្ពស់

៤- បម្រើការនៅ ៖ ▢ ១.វិទ្យាល័យហ៊ុន សែន បុរី១០០ខ្នង ▢២.វិទ្យាល័យជា ស៊ីម បឹងកេងកង

▢៣.វិទ្យាល័យពងទឹក ▢៤.វិទ្យាល័យហ៊ុន សែនចាក់អង្រែ ▢៥.វិទ្យាល័យទឹកល្អក់

៥- បទពិសោធន៍បំពេញការងារ៖.......................ឆ្នាំ

៦- មុខវិជ្ជាកំពុងបង្រៀន៖ ១.ភាសាខ្មែរ▢ ២.គណិត▢ ៣.រូប▢ ៤.គីមី▢ ៥.ជីវៈ▢

៦.ផែនដី▢ ៧.ភូមិ▢ ៨.ប្រវត្តិ▢ ៩.អង់គ្លេស▢ ១០.សីលធម៌▢

៧- កម្រិតថ្នាក់កំពុងបង្រៀន៖ ▢១.ទី១០ ▢២.ទី១១ ▢៣.ទី១២

**ផ្នែកទី២៖ ទស្សនៈរបស់មាតាបិតាលើតួនាទី ក្នុងការចូលរួម និងការសិក្សារបស់កូន**

**សម្គាល់៖ ១.មិនយល់ស្រប ២.យល់ស្របតិចតួច ៣.ពុំមានយោបល់**

**៤.យល់ស្រប ៥.យល់ស្របទាំងស្រុង**

| ល.រ | ខ្លឹមសារ | ១ | ២ | ៣ | ៤ | ៥ |
|---|---|---|---|---|---|---|
| ២.១ ដំណើរការចំពោះតួនាទីក្នុងការចូលរួមចំណែកអប់រំកូនរបស់មាតាបិតា | | | | | | |
| ១ | ខ្ញុំយល់ឃើញថា ឪពុកម្ដាយសិស្សបានចូលរួមជួយកូនច្រើន ក្នុងការសិក្សារបស់ពួកគេ | | | | | |
| ២ | ខ្ញុំតែងតែពិភាក្សាជាមួយឪពុកម្ដាយសិស្ស អំពីការសិក្សារបស់កូន | | | | | |
| ៣ | ខ្ញុំជឿជាក់ថាឪពុកម្ដាយ យល់ដឹងបានច្រើន អំពីសារៈសំខាន់នៃការសិក្សារបស់កូន | | | | | |
| ៤ | សិស្សចូលរៀនបានទៀងទាត់ និងទាន់ពេលវេលា គឺពិតជាមានការជំរុញពីឪពុកម្ដាយជាប្រចាំ | | | | | |
| ៥ | ខ្ញុំតែងតែ ដាក់កិច្ចការឲ្យសិស្សយកទៅធ្វើនៅផ្ទះ និងបានផ្ដាំផ្ញើឲ្យឪពុកម្ដាយ ជួយកូនតាមភាពជាក់ស្ដែង បានញឹកញាប់ណាស់ | | | | | |
